ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ អៀង ធីរិទ្ធ មិនស្គាល់គុណខ្មែរ

◆ អៀង សារី សច្ចា...

# មាតិកា

◆ សំបុត្រៈ អៀង ធីរិទ្ធ មិនស្គាល់កូនខ្មែរ ..................................១

**ផ្នែកឯកសារ**

◆ សេចក្ដីរាយការណ៍អំពីសភាពការណ៍រួម..................................២

◆ កំណត់ហេតុប្រជុំជាមួយគណៈប្រតិភូគមនាគមន៍ចិន......................៤

◆ ការសន្ទនារបស់សមមិត្ត អៀង សារី..................................១១

◆ បញ្ជីឈ្មោះជនរងគ្រោះដែលត្រូវបានកម្ទេចនៅមន្ទីរ ស-២១.......១៦

◆ ទិន្នន័យទីតាំងរួមនៃអំពើប្រល័យពូជសាសន៍............................១៨

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ សម្លេងពីមន្ទីរ ស-២១..................................................១៩

◆ គុកព្រៃស .................................................................. ២៤

**ផ្នែកច្បាប់**

◆ តុលាការនៅទីម័រខាងកើត..................................................៣០

**វេទិកាពិភាក្សាសាធារណៈ**

◆ សុន្ទរកថាថ្លែងដោយឯកឧត្ដម សុខ អាន ..............................៣៦

◆ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ......................៤៣

◆ ការឆ្លុះបញ្ចាំងអំពីវាសនាតុលាការ ........................................៤៤

◆ ការទទឹងរង់ចាំយុត្តិធម៌នៅកម្ពុជា .......................................៤៧

◆ កាលប្បវត្តិៈ ប្រវត្តិនៃការចរចា .........................................៥០

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ថ្ងៃ ២០ ឧសភាៈ នឹកដល់លោកតានិងពូរបស់ខ្ញុំ.........................៥៥

◆ ឪពុកនិងប្អូនរបស់ខ្ញុំស្លាប់ដោយសាររបបខ្មែរក្រហម.....................៥៦

**សិល្បៈខ្មែរក្រហមៈ**

◆ ប្រលោមលោកបដិវត្តៈ ពលិកម្មម៉ែៗយើង..............................៥៩

◆ សោកនាដកម្មស្រុកមោងឬស្សី .................................ក្របក្រោយ



**សមមិត្តនារី អៀង ធីរិទ្ធ នៅប៉ៃលិន**

**(រូបថតដោយៈ ឆាំង យុ)**

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

(រូបថតក្របមុខផ្ដល់អោយដោយ ចូសេហ្វ កុហ្វម៉ាន់)
រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**វាគ្មិនលេខនេះ:** ដេវីដ ឆេនដល័រ, ស៊ូហ្សាណា លីនតុន, ស៊ូសាន យុក, ដេង ពង្សរ៉ាស៊ី, ហ៊ុយ វណ្ណៈ, ឆេង វ៉េង, យិន នាន **អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុផល, ដួង សុភារិទ្ធ **ជំនួយការនិពន្ធនាយកៈ** សាន់ កល្យាណ **និពន្ធនាយករងទី១ៈ** ស្វ ប៊ុនស៊ូ **និពន្ធនាយករងទី២ៈ** សឹម សុរិយ៉ា **អ្នកបកប្រែៈ** អេង កុកថាយ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** សុខ វណ្ណៈ

***សំបុត្រៈ***

# អៀង ធីរិទ្ធ មិនស្គាល់កូនខ្មែរ

នៅលើយន្តហោះមកកាន់ទីក្រុងភ្នំពេញ អៀង ធីរិទ្ធ រអ៊ូរទាំប្រាប់អ្នកកាសែតអាមេរិកាំងម្នាក់ថា រូបខ្ញុំនេះគឺជាក្មេងកំព្រាគ្មានម៉ែគ្មានឪ ហើយថារូបខ្ញុំនេះបានចេញទៅរស់នៅឯបរទេសមុនរបបខ្មែរក្រហមមហាលោតផ្លោះមហាអស្ចារ្យចូលមកដល់ ។ ក្នុងន័យនេះ អៀង ធីរិទ្ធ វិភាគថា ខ្ញុំពុំបានស្គាល់ខ្មែរនិងការពិតនៅក្នុងរបបខ្មែរក្រហមនោះឡើយ ហើយក្មេងកំព្រានេះទៀតសោតគឺជាក្មេងដែលមានអត្តចរិតឆេវឆាវ រឹងរូសនិងក្រអឺតក្រទមទៀតផង ។ ទោះបី អៀង សារី ដែលជាប្តីព្យាយាមឃាត់ការសន្ទនានេះយ៉ាងណាក៏ដោយ ក៏ អៀង ធីរិទ្ធ បន្តចោទប្រកាន់ទៅមនុស្សដទៃទៀតថាបានបំផ្លើសការពិតអំពីរបបខ្មែរក្រហមដែលខ្លួនបានបម្រើក្នុងឋានៈជាកម្មាភិបាលជាន់ខ្ពស់ ។

ខ្ញុំជាកូនខ្មែរ ។ ខ្ញុំជាក្មេងកំព្រាឪពុក ។ ម្តាយរបស់ខ្ញុំនៅមានជីវិតរស់នៅសព្វថ្ងៃ ។ ខ្ញុំកើតនៅសង្កាត់លេខ២ ក្រុងភ្នំពេញ ។ នៅពេលដែលខ្មែរក្រហមចូលមកកាន់កាប់អំណាចនៅឆ្នាំ១៩៧៥ ខ្ញុំមានអាយុ១៨ឆ្នាំ ។ គ្រានោះ ខ្ញុំត្រូវបានជម្លៀសឲ្យទៅរស់នៅក្នុងភូមិត្រពាំងវែង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង តំបន់៥ ។ ខ្ញុំបានឃើញផ្ទាល់នឹងភ្នែកនូវការសម្លាប់មនុស្សយ៉ាងឃោរឃៅដែលធ្វើឡើងដោយកម្មាភិបាលនៃរបបនេះ នៅពីមុខបរិវេណវត្តព្រះនេត្រព្រះ ។ បងស្រីខ្ញុំ ក្លយ ពូ មា មីង និងបងប្អូនរបស់ខ្ញុំ បានស្លាប់បាត់បង់ជីវិតរាប់មិនអស់ ។ ក្រោយរបបខ្មែរក្រហមទើបខ្ញុំបានទៅរស់នៅរដ្ឋតិចសាស់ សហរដ្ឋអាមេរិក ។

ខ្មែរក្រហមបានបំបែកក្មេងចេញពីឪពុកម្តាយដើម្បីអប់រំបំប៉នមនោគមវិជ្ជា រហូតដល់ក្មេងទាំងនោះហ៊ានលះបង់ជីវិតខ្លួនដើម្បីបុព្វហេតុតូចតាចក៏មាន ។ ក្មេងទាំងនោះអនុវត្តន៍សកម្មភាពដែលពុំមែនជាមនុស្សតាមបញ្ជាអង្គការដោយការភ័យព្រួយនិងបាក់ស្បាត ។ ប៉ុន្តែក្មេងខ្លះទៀតដែលជាកូនចៅកម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហមបានប្រព្រឹត្តអំពើសាហាវព្រៃផ្សៃយ៉ាងអំណួត ។

អៀង ធីរិទ្ធ បានស្គាល់ពីភាពរឹងប៉ឹងរបស់ខ្ញុំ ប៉ុន្តែភាពរឹងប៉ឹងរបស់ខ្ញុំគឺបានមកពីការថ្នាក់ថ្នមស្រឡាញ់របស់ម្តាយខ្ញុំនិងការពិតដែលខ្ញុំបានសិក្សារៀនសូត្រ មិនមែនបានមកពីការអប់រំបំប៉នមនោគមវិជ្ជារបស់អង្គការបដិវត្តន៍ខ្មែរក្រហមនោះទេ ។

មកទល់នឹងថ្ងៃនេះ ខ្ញុំនៅតែមានចេតនាពិតប្រាកដចង់ជួប អៀង ធីរិទ្ធ និងមេដឹកនាំខ្មែរក្រហមដទៃទៀត នៅចំពោះមុខតុលាការយុត្តិធម៌មួយ ។

**ឆាំង យុ**

# សេចក្តីរាយការណ៍អំពីសភាពការណ៍រួម ប្រជុំថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៦

## (សំណៅដើមនៃឯកសារកម្ពុជាប្រជាធិបតេយ្យ លេខ D ៦៩៩)

### ១) អំពីសភាពការណ៍រួមៈ

ការដាក់ចំណងទាក់ទងទូតជាមួយប្រទេសភូមា ម៉ាឡេស៊ីយ៉ា សិង្ហបូរី ហ្វីលីពីន បានធ្វើឲ្យគេចាប់អារម្មណ៍ពីបដិវត្តយើងថែមទៀត ។ ប៉ុន្តែប្រតិកម្មវៀតណាមតាមរយៈសេចក្តីថ្លែង-ការណ៍លោកស្រី ង្វៀង ធីបិញ ទៅភ្នាក់ងារសារពត៌មាន អា អេហ្វ ប៉េ ថ្ងៃទី៧ ខែឧសភានេះ ឃើញថាមិនសូវរីករាយទេ ។ យើងបន្តការទាក់ទងទូតជាមួយប្រទេសអឺរ៉ុបខ្លះទៀត ។

ភ្នាក់ងារសារពត៌មាន អា អេហ្វ ប៉េ ថ្ងៃទី៨ ខែឧសភា បាននិយាយពីរឿងគ្រួសារ ហួត សម្បត្តិ រត់ពីប៉ៃលិនក្រាតទៅប្រទេសបារាំង ប៉ុន្តែវិទ្យុបរទេសដែលយើងចាប់បាន គ្មានលើករឿងនេះទេ ។ ប៉ុន្តែរឿងអា ពេច លឹមឃួន ពួកខ្មាំងវាយកចិត្តទុកដាក់ ។ តាមវិទ្យុកងអាកាសអាមេរិកផ្សាយថ្ងៃទី៩ ខែឧសភា វេលាម៉ោង៩:៣០ បានឲ្យដឹងថា មានអ្នកបច្ចេកទេស ចិន ២០០ នាក់ កំពុងសង់វាលយន្តហោះយោធាមួយខាងជើងភ្នំពេញ ប្រហែល២៥០០ម៉ែត្រ សម្រាប់យន្តហោះមិច២១ចុះហើយ ថាមានពួកបច្ចេកទេសចិនមួយចំនួនទៀតកំពុងជួសជុល កប៉ាល់ និងបង្រៀនបើកបរកប៉ាល់នៅកំពង់ផែកំពង់សោម ។ ប៉ុន្តែវិទ្យុសម្លេងសហរដ្ឋអាមេរិកឥតមានផ្សាយរឿងនេះទេ ។ ដូចនេះខ្មាំងវានឹងតាមដានរឿងនេះ ។ ខាងយើងពុំចាំបាច់មានប្រតិកម្មអ្វីទេ ។

កាលដែលឯកអគ្គរដ្ឋទូតចិនជូនសារតាំងកាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧៦ នាំឲ្យបរទេសចាប់អារម្មណ៍តាមដាន ។ ជាទស្សនៈគោលជំហរ តាំងពីចាត់តាំងអគ្គការរដ្ឋមក អត្តិភាពរបស់យើងចេះតែឡើង ទោះបីខ្មាំងវាមួលបង្កាច់ ឃោសនាប្រឆាំងយើងយ៉ាងណាក្តី ។

### ២) ព្រឹត្តិការណ៍នៅអាស៊ីៈ

ក) នៅវៀតណាម ឆ្លងតាមលទ្ធផលនៃការបោះឆ្នោតនិងតាមការពិនិត្យមើលសភាពការណ៍ សភាតំណាងប្រជាជនដែលមានតំណាងកម្មករ៨០នាក់ កសិករ១០០នាក់ យុទ្ធជន៥៤នាក់ បញ្ញាជន៩៨នាក់ កម្មាភិបាលនយោបាយ៤១នាក់ អ្នកកាន់សាសនា១៣នាក់ និងសិប្បករ៦នាក់ ឃើញថាធាតុបដិវត្តវៀតណាមខុសពីបដិវត្តយើង ។

តាមទីភ្នាក់ងារសារពត៌មាន អា អេហ្វ ប៉េ ថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦ រដ្ឋមន្ត្រីក្រសួងការបរទេសវៀតណាមខាងត្បូង ង្វៀង ធីបិញ បានធ្វើសម្ភាសន៍ជាមួយកាសែត “ឡឺម៉ុងដ៍” ស្តីអំពីអាជីវកម្មប្រេងកាតក្នុងឈូងសមុទ្រថៃ ។ ក្នុងនោះវៀតណាមសុខចិត្តសហការជាមួយក្រុមហ៊ុនបរទេសទាំងអស់មានក្រុមហ៊ុនអាមេរិក “សែល” និងហុល្លង់អយជាដើម ដើម្បីជីករកប្រេងកាតនៅក្នុងសមុទ្រវៀតណាម ។ ក្នុងរឿងនេះឃើញថា មានបញ្ហាធំខាងប្រេងកាត ហើយកំពុងទាក់ទាញក្រុមហ៊ុនបារាំងផង ក្រុមហ៊ុនអាមេរិកផង ដើម្បីឲ្យវាប្រជែងគ្នាក្នុងទិសដៅចង់ជីករកប្រេងកាតក្នុងសមុទ្រ ហើយនិងបានជំនួយពីអាមេរិក ។ រឿងនេះទាក់ទងជាមួយដែនសមុទ្រយើង ព្រោះក្រុមហ៊ុនប្រេងកាតបារាំងមានឯកសារពីការជីកប្រេងកាតក្នុងឈូងសមុទ្រថៃ ។ វិធានការយើងគឺស្នើឲ្យមិត្តដែលកាន់ផ្នែកអឺរ៉ុប ធ្វើការស្រាវជ្រាវអំពីក្រុមហ៊ុនប្រេងកាតបារាំងដែលបានជីករកប្រេងកាតនៅក្នុងដែនដីយើងពីមុនមក ។

ខ) ព្រឹត្តិការណ៍នៅម៉ាឡេស៊ីយ៉ា ចលនាតស៊ូរបស់ប្រជាជនបានផុលផុសគ្រប់ទីកន្លែងរហូតដល់ទីក្រុង ។ ចលនាតស៊ូរបស់ប្រជាជនថៃឈានឡើងដោយមានប្រជាជនថៃ១ម៉ឺននាក់នៅជិតព្រំដែនថៃ-ម៉ាឡេស៊ីយ៉ា បានធ្វើបាតុកម្មប្រឆាំងនឹងការទម្លាក់គ្រាប់បែកនៃកងទ័ពម៉ាឡាយូ ។ ចលនានេះធំ រួមផ្សំដោយការតស៊ូដោយអាវុធធ្វើឲ្យពួកកាន់អំណាចថៃ-ម៉ាឡេស៊ីយ៉ា ស្ទន់ស្ទោរហូតដល់រុះរើកិច្ចព្រមព្រៀងសហការយោធានៅព្រំប្រទល់ប្រទេសទាំងពីរ ។ ភ្នាក់ងារសារពត៌មាន អា អេហ្វ ប៉េ ថ្ងៃទី១០ ខែឧសភា បានផ្សាយថា រដ្ឋមន្ត្រីការបរទេសថៃនិងម៉ាឡេស៊ីយ៉ាបានជួបគ្នានៅបាងកកកាលពីថ្ងៃទី៩ ខែឧសភា ហើយព្រមព្រៀងគ្នាសើរើកិច្ចព្រមព្រៀងសហការនៅព្រំប្រទល់

ថៃ-ម៉ាឡេស៊ីយ៉ា ។

វិភាគព្រឹត្តិការណ៍ខាងលើនេះឃើញថា ចលនាតស៊ូប្រជាជននៅអាស៊ី-អាគ្នេយ៍មានកម្រិតខ្ពស់ នាំឲ្យបំផុសប្រទេសទាំងនេះ និងនាំឲ្យវណ្ណៈកាន់អំណាចចាប់អារម្មណ៍ ខំសម្របសម្រួលនយោបាយ វារកឥទ្ធិពលពីមហាអំណាចក្រៅមកទប់ទល់សង្កត់ចលនាតស៊ូនេះ ។ ក្នុងទិសដៅតស៊ូនេះដែរ លី គ្វាន់យូ ទៅធ្វើទស្សនកិច្ចនៅប៉េកាំង ហើយ ម៉ាកូស ទៅធ្វើទស្សនកិច្ចនៅម៉ូស្គូ ។

គ) ក្នុងសេចក្តីថ្លែងការណ៍រួមសូវៀតនិងលាវ គេអំពាវនាវថាឲ្យប្រទេសមិនចូលបក្សសម្ព័ន្ធនិងប្រទេសសង្គមនិយម សាមគ្គីគ្នាជិតស្និទ្ធទើបប្រទេសមិនចូលបក្សសម្ព័ន្ធដណ្តើមយកជ័យជម្នះបាន ។ សេចក្តីថ្លែងការណ៍រួមសូវៀត-លាវ ថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៦ ។

ព្រឹត្តិការណ៍លោកស្រី ឥណ្ឌៀរ៉ា គន្ធី ទៅធ្វើទស្សនកិច្ចនៅម៉ូស្គូ ខែមិថុនាខាងមុខនេះ ។

ព្រឹត្តិការណ៍លោកស្រី បានដារ៉ា ណៃកេ ទៅធ្វើទស្សនកិច្ចនៅម៉ូស្គូចុងខែឧសភានេះ ។

ទីភ្នាក់ងារ អា អេហ្វ ប៉េ ថ្ងៃទី១២ ខែឧសភា ផ្សាយថា ផ្មៀង ធីបិញ នឹងទៅធ្វើទស្សនកិច្ចនៅឥណ្ឌាចុងខែឧសភានេះ ដើម្បីពិភាក្សាអំពីសន្និសីទកំពូលប្រទេសមិនចូលបក្សសម្ព័ន្ធនៅកូឡុំបូ ហើយនឹងបន្តដំណើរទស្សនកិច្ចទៅស្រីលង្កាទៀត ។

វិភាគឃើញថា ពួកសេរីនិងដៃជើងកំពុងដំណើការអូសទាញរៀបចំសន្និសីទកូឡុំបូ ។ វិធានការឃើញថាចាំបាច់ បង្កើនសកម្មភាពយើងនៅអាស៊ី ហើយរៀបចំសន្និសីទកូឡុំបូឲ្យបានសកម្មថែមទៀត ដោយបញ្ជូនគណៈប្រតិភូយើងទៅអាស៊ីខ្លះ ។

ឃ) ព្រឹត្តិការណ៍ផ្សាយដោយវិទ្យុជប៉ុនថ្ងៃទី១២ ខែឧសភា ពីគណៈប្រតិភូឥណ្ឌាទៅប៉ាគីស្ថាន ។ វិភាគឃើញថា ឥណ្ឌាប្រញាប់ប្រញាល់ដោះស្រាយរឿងទាក់ទងជាមួយប៉ាគីស្ថាន ព្រោះចង់ដើរតួនៅក្នុងសន្និសីទកំពូលកូឡុំបូ ។

ង) ប៉ាគីស្ថាននិងថៃបានធ្វើសកម្មភាពទូតដើម្បីរៀបចំដាក់បេក្ខភាពជាអ្នកសង្កេតការណ៍នៅសន្និសីទកំពូលកូឡុំបូ ។ ប្រទេសអាស៊ីទាំងពីរនេះ ក៏គិតគូររៀបចំសន្និសីទកំពូលកូឡុំបូ ដោយសកម្មដែរ ។ ចំពោះប៉ាគីស្ថាន បើចូលជាអ្នកអង្កេតការណ៍ក៏ចំណេញដល់យើង ។ ឯថៃ យើងយកអាកប្បកិរិយាមិនប្រឆាំងនឹងបេក្ខភាព តែយើងមិនចេញមុខគាំទ្រដែរ ។

### ៣) ព្រឹត្តិការណ៍នៅអាហ្វ្រិកនិងមជ្ឈិមបូព៌ាៈ

ក) ព្រឹត្តិការណ៍នៅលីបង់ៈ ក្រោយពីរើស អេលីយ៉ា សាគីស ដែលមាននិន្នាការស្តាំ ជាប្រធានាធិបតេយ្យថ្មីឃើញថា ចក្រពត្តិអាមេរិកក្តាប់បញ្ហាលីបង់នេះបានមួយកម្រិត ។ ក្នុងការដោះ-ស្រាយទំនាស់ផ្ទៃក្នុងនៃប្រទេសលីបង់ ចក្រពត្តិអាមេរិកនិងប្រទេសសេរី ឯកភាពគ្នាក្នុងការទប់ទល់សកម្មភាពពួកឆ្វេងដែលមានសូវៀតនៅពីក្រោយ ។ ឯអង្គការសេរីកា ប៉ាឡេស្ទីន ដូចជាព្រងើយក្នុងរឿងនេះ ។

ខ) សន្និសីទកំពូលប៉ារីសរវាងបារាំងនិងប្រទេសអាហ្វ្រិក ១៩ប្រទេសៈ

បារាំងបានរៀបចំសន្និសីទនេះដើម្បីប្រមែប្រមូលប្រទេសអាហ្វ្រិកខ្លះដែលវាធ្លាប់គ្រប់គ្រង ដើម្បីទប់ទល់ឥទ្ធិពលសូវៀត អាមេរិក ចិន ហើយនិងរក្សាទីតាំងរបស់វា ។ ក្នុងនេះវាមានគោលបំណងដើរតួជាស្ពានកណ្តាល បន្តការជិះជាន់លើអាណានិគមនិយមចាស់គំរិលរបស់វា ។ ក្នុងប្រទេសអាហ្វ្រិកដែលបានបញ្ជូនគណៈប្រតិភូទៅប៉ារីស បារាំង គ្មានឥទ្ធិពលប៉ុន្មានទេ ។ មហិច្ឆតាបារាំងធំលើសសមត្ថភាពនិងលទ្ធភាពរបស់វា ។

គ) សន្និសីទណៃរ៉ូប៊ីនៅសន្និសីទនេះមានការប្រណាំងប្រជែងរវាងចក្រពត្តិអាមេរិកនិងសេរីរើសូវៀតយ៉ាងខ្លាំង ។ ចក្រពត្តិអាមេរិកចង់បង្វែរចលនាតស៊ូប្រទេសតតិយលោកដោយបង្កើតមូលនិធិ១០០០លានដុល្លារសម្រាប់ទិញវត្ថុធាតុដើមដ្កុកទុកដើម្បីរក្សាតម្លៃឲ្យមានការនឹងន ។

បារាំងខ្វែងពីចក្រពត្តិអាមេរិកត្រង់ថា សព្វថ្ងៃនេះមិនបាច់បង្កើតមូលនិធិថ្មីទៀតទេ ពីព្រោះមានមូលនិធិអន្តរជាតិរួចហើយ ។ បារាំងគាំទ្រគំនិតដែលថា ត្រូវពិនិត្យតម្លៃវត្ថុធាតុដើមនីមួយៗតាមការជាក់ស្តែង ។

រឿងនេះសូវៀតប្រទាញប្រទង់ឲ្យតតិយលោកធ្វើសហការជាមួយប្រទេសសង្គមនិយម ដើម្បីយកជ័យឲ្យបាន ។ ឯប្រទេសតតិយលោក ជារួម តស៊ូការពារសេចក្តីសម្រេចនៅសន្និសីទម៉ានិល ។

# កំណត់ហេតុប្រជុំជាមួយគណៈប្រតិភូគមនាគមន៍ចិន

## (សំណៅដើមនៃឯកសារកម្ពុជាប្រជាធិបតេយ្យ លេខៈ D ២០៤៤៨)

### ថ្ងៃទី២៦-៦-១៩៧៧ ពីម៉ោង១៤ដល់ម៉ោង១៧

**ខាងកម្ពុជាៈ** បងវ៉ាន់, ស.ម អន, រិត, សីលា

**ខាងមិត្តចិនៈ** ស.ម ស៊ុន ហាវ, ជាង ភួង, ម៉ា សី សមាជិកប្រតិភូពីរនាក់ អ្នកបកប្រែពីររូប ។

ជាដំបូងបងវ៉ាន់ថ្លែងអំណរគុណ ហើយជូនសម្តីដល់មិត្តចិន ស.ម ជាង ភួង ចែកជាបីផ្នែកៈ

១) ពិធីសារ

២) គ្រប់គ្រងអាជីវកម្ម

៣) បណ្តុះបណ្តាលនាវិក

**១) ពិធីសារបានជូនហើយ**

◆ ពិភាក្សា ពន្យល់ អត្ថាធិប្បាយ ស្នើធ្វើរបៀបណា ។

◆ អាជីវកម្មនិងបណ្តុះបណ្តាល មិនចាំបាច់និយាយទេ លើបញ្ហាសំខាន់ៗ ។

**មាត្រា១ៈ** សញ្ញាបត្រនៃកប៉ាល់អន្តរជាតិ បើដាក់ទង់ប្រទេសណាគឺជារបស់ប្រទេសនោះ ។ បើសិនជាចូលដៃនៅប្រទេសណាក៏ដោយ ត្រូវមានអង្គការពិសេសមួយដើម្បីពិនិត្យ ហើយគេចេញសញ្ញាបត្រឲ្យទើបដើរបាន ។ ត្រូវមានជាង១០មុខ ។

១) សញ្ញាបត្របញ្ជាក់សញ្ជាតិ

២) សញ្ញាបត្របញ្ជាក់ចំនួនតោន

៣) សញ្ញាបត្របញ្ជាក់របនាចសម្ព័ន្ធនិងសន្តិសុខ

៤) សញ្ញាបត្របញ្ជាក់បរិក្ខាកប៉ាល់

៥) សញ្ញាបត្របញ្ជាក់សន្តិសុខវិទ្យុទាក់ទង

៦) សញ្ញាបត្របញ្ជាក់ដាក់ឥវ៉ាន់ប៉ុន្មានតោន

◆ នៅប្រទេសចិនមានមន្ទីរមួយសម្រាប់ពិនិត្យបញ្ជីនេះ មានការទាក់ទងជាមួយប្រទេសដទៃ ។

◆ ប្រទេសនីមួយៗមានសញ្ញាផ្សេងៗពីគ្នា

◆ បារាំង PV

◆ អង់គ្លេស LIX

◆ កប៉ាល់នេះដាក់ទង់ជាតិចិន ត្រូវប្រទេសចិនពិនិត្យទាំងអស់ ។

◆ ខាងក្រៅជារបស់ចិន ខាងក្នុងជារបស់កម្ពុជា ។

**មាត្រា២ៈ**

◆ វិក័យបត្រ

◆ តម្លៃដឹកជញ្ជូន

◆ ធានារ៉ាប់រងក្រុមហ៊ុនដឹកជញ្ជូន សុំធានារ៉ាប់រងពីប្រទេសចិន

ក) បញ្ជាក់ការដឹកទំនិញអ្វីៗទុកជាប័ណ្ណដែលមានតម្លៃ ចេញពីកប៉ាល់ទើបយកឥវ៉ាន់បាន ។ មានចុះហត្ថលេខាពីប្រធានកប៉ាល់ ឬតំណាងក្រុមហ៊ុននាវាចរណ៍ បើដឹកឥវ៉ាន់ទៅហើយបាត់ទំនិញ ម្ចាស់ទំនិញយកវិក័យបត្រទៅតាមទារទំនិញចេញពីក្រុមហ៊ុនរបស់កប៉ាល់ ។ យ៉ុង ខាង នៅក្នុងក្របខ័ណ្ឌក្រុមហ៊ុននាវាសមុទ្រ ត្រូវក្រុមហ៊ុនចេញឲ្យ ។

ខ) តម្លៃដឹកជញ្ជូន មានបីផុនៈ ១) ឈ្នួលនៃកប៉ាល់នេះទុកជាតម្លៃដឹកឥវ៉ាន់ ជួលរយៈពេលយូរ ជួលក្នុងមួយជើងៗ ។ ២) ក្រុមហ៊ុនកំណត់តម្លៃតាមប្រភេទទំនិញ ។ យ៉ុង ខាង ក្រុមហ៊ុនប្រទេសចិនកំណត់តារាងតម្លៃពីកន្លែងមួយ ទៅកន្លែងមួយ ។ ៣) មានតម្លៃពិសេសសម្រាប់ប្រទេស៤ៈ កូរ៉េ ស្រីលង្កា អាល់បានី តង់ហ្សានី ។

◆ យ៉ុង ខាង ប្រើតារាងតម្លៃនេះ (សូមជូនតារាងតម្លៃដឹកជញ្ជូន) ។ បើដឹកទំនិញ ប្រទេសណាក៏ដោយ ក៏ត្រូវអនុវត្តតាមតារាងតម្លៃនេះទាំងអស់ ។

◆ តារាងនេះកំណត់រវាងចិននិងកម្ពុជា ។

◆ ប្រទេសដទៃត្រូវបន្ថែមតម្លៃ១០ឬ២០ភាគរយ ។

◆ តារាងតម្លៃប្រទេសចិនគិតពីប្រទេសចិន ។

◆ យ៉ុង ខាង ចេញពីកន្លែងផ្សេង មានហុងកុង និងកំពង់សោម ។

គ) អំពីធានារ៉ាប់រងៈ នាវាដើរលើផ្ទៃសមុទ្រអាចជួបឧបសគ្គ

ដែលមិនអាចស្មានបាន ការបុកគ្នាតាមផ្លូវឬនៅកំពង់ផែ ។ វាង ពីផ្លូវដើរទៅគៀងនៅកន្លែងផ្សេង ។ ព្រឹត្តិការណ៍នេះនាំឲ្យខូចខាតកប៉ាល់និងទំនិញក្នុងកប៉ាល់ ។

◆ ដើម្បីធានាចំពោះឧបទ្ទវហេតុណាមួយ ត្រូវទៅសុំពីក្រុមហ៊ុនធានារ៉ាប់រង ។

◆ យ៉ុង ខាង ទៅសុំធានារ៉ាប់រង ឧបមាដាក់តម្លៃ១.៦៥០.០០០ដុល្លារអាមេរិកទៅប្រទេសចិន ។ ក្រុមហ៊ុនមិនត្រូវចែកទៅឲ្យក្រុមហ៊ុនបារាំងឬអង់គ្លេស ។

◆ របៀបសុំធានាមានច្រើនប្រភេទៈ

១) ខូចខាតតិចតួចត្រូវគេសង

២) ខូចខាតទាំងមូលឲ្យគេសង

◆ យ៉ុង ខាង សុំធានាទាំងមូល ហើយតិចតួចសុំជួសជុលខ្លួនឯង ។ ធ្វើតាមរបៀបទី២ចេញឈ្នួលតិច ។ ចេញឈ្នួលច្រើន គេសងក៏ច្រើនដែរ ។ បញ្ហានេះទាក់ទងដល់នាវិកថែទាំម៉ាស៊ីន បើព្យាយាមថែទាំ ចេញឈ្នួលតិច បើធ្វេសប្រហែសចេញឈ្នួលច្រើន ។

◆ យើងសុំធានាចំពោះការខូចខាតទាំងមូល ។

◆ បើសិនបុកខូចខាតតិចតួច ត្រូវចេញថ្លៃដោយខ្លួនឯង ។

◆ បើដើរទៅគៀងកន្លែងណាជួលគេទាញ ក្រុមហ៊ុនធានារ៉ាប់រងចេញថ្លៃឲ្យ ។

◆ កប៉ាល់បុកគ្នា ខាងអន្តរជាតិទៅពិនិត្យ បើយើងបុកគេក្រុមហ៊ុនធានារ៉ាប់រងចេញសងគេ ខ្លួនឯងជួសជុលខ្លួនឯង ។

◆ បញ្ហាសង្គ្រាម គេមិននិយាយតម្លៃសងទេ ។

◆ "១"ប៉ុន្មាននេះ ១ឆ្នាំត្រូវចេញតម្លៃ១០.៨១៨ដុល្លារអាមេរិកជូនក្រុមហ៊ុនធានារ៉ាប់រងចិន ។

◆ បើជួបឧបទ្ទវហេតុណាក៏ដោយ

◆ កប៉ាល់នេះដាក់ទងជាតិចិន ត្រូវទៅសុំធានារ៉ាប់រងភ្លាម ។

**មាត្រា៥ៈ** ទុន១០០.០០០ដុល្លារអាមេរិកសម្រាប់ចល័តអាជីវកម្ម ។

◆ ត្រូវ Assurance (ធានារ៉ាប់រង) មួយភាគ៣

◆ គ្រឿងបន្លាស់ ថ្នាំលាប ខ្សែពួរផ្សេងៗ

◆ ចូលផែត្រូវចេញឈ្នួល ទិញទឹកសាប លើកដាក់ឥវ៉ាន់ត្រូវចេញតម្លៃឲ្យគេ ។

◆ ដឹកទំនិញហើយ ទើបចេញឈ្នួលថ្លៃដឹកទំនិញ ។

◆ ចាប់ពីថ្ងៃទី១២.៥.១៩៧៧ដល់១៧.៦.១៩៧៧អស់តម្លៃជាង៩.០០០០ដុល្លារអាមេរិកទៅហើយ ទៅផែដជប៉ុនអស់៤០.០០០ដុល្លារអាមេរិកទៀត ។ រួចទារថ្លៃដឹកជញ្ជូន ។

◆ ទុកជាសហគ្រាសមួយ ក្រៅពីដើមទុនត្រូវមានទុនចល័ត ។

◆ ចំពោះទុនចល័តជាកម្មសិទ្ធរបស់កម្ពុជា ។ ដល់ធ្វើអាជីវកម្មទៅជារបស់កម្ពុជា ។

**មាត្រា៦ៈ** បញ្ជាក់ប្រាក់ខែ របបជីវភាពតាមថ្នាក់ (ក) ប្រាក់ខែនាវិកចិនៈ

◆ តាមការកំណត់នៃក្រសួងគមនាគមន៍ចិន កម្មាភិបាលនិងនាវិកមានថ្នាក់ខុសគ្នា ។

◆ ប្រធានកប៉ាល់ចែកជាបីថ្នាក់តាមចំណាត់នៃឆ្នាំកម្រិតបច្ចេកទេសថ្នាក់ទី១ ទី២ ទី៣ ។ ទី១ៈ រិន មិន បី ៣៨០យាន់ ៣៥០យាន់ ២៨០យាន់ (ឧបមា)

◆ យ៉ុង ខាង ត្រូវគិតតាមមធ្យមភាគនៃតម្លៃខាងលើ ។

◆ អ្នកធ្វើការនៅ យ៉ុង ខាង គិតជាមធ្យម គិតមួយនាវិក ១៣៧យាន់ ។

◆ ត្រូវមានសម្លៀកបំពាក់ឯកសណ្ឋាន សុខុមាលភាពគិតទៅត្រូវ២០១.៦៨យាន់ ។

◆ នាវិកនិងអ្នកធ្វើការត្រូវមានថ្ងៃសម្រាក១ឆ្នាំ ២ខែ ចែកវេនគ្នា ។ ត្រូវបន្ថែមបុគ្គលិកធ្វើការ៣៥ភាគរយ ។

◆ ប្រាក់ខែអ្នកជំនួសត្រូវគិតដូចបុគ្គលិកមែនទែន គិតមធ្យម ១ខែត្រូវ ២៧២យាន់ មួយនាក់ៗ ។

◆ ចែកប្រាក់ខែមែនទែនតាមបុគ្គលិកមួយនាក់ៗ ។

◆ មិត្តកម្ពុជាប្រាក់ខែគិតកម្រិតដូចគ្នា ។ សោហ៊ុយដើម ធ្វើតារាងជូនកម្ពុជា ។

◆ កម្ពុជាធ្វើបានប៉ុន្មាន ត្រូវគិតគូរនិងចែក ។

◆ នាវិកដើរលើសមុទ្រអន្តរជាតិត្រូវបានប្រាក់កម្រៃជារូបិយប័ណ្ណ ។ កំណត់បណ្តោះអាសន្នមួយថ្ងៃ ២,៥០យាន់ ឲ្យតែចេញពីកំពង់ផែចិន បើចូលគ្មានប្រាក់បំណាច់ទេ ។

◆ តើមិត្តកម្ពុជាធ្វើការលើកប៉ាល់ មានប្រាក់បំណាច់ឬទេ? ស្រេចមិត្តកម្ពុជា ។

◆ នាវិកចិនកំណត់របបហូបបាយ១ថ្ងៃ ២,៨០យ៉ាន់ ។ គិតជាមធ្យមតាមតម្លៃទំនិញមួយថ្ងៃសាច់ប៉ុន្មាន បន្លែ អង្ករ ។ តម្លៃទៅតាមកន្លែងនីមួយៗ សរុបទៅបានជាមានតម្លៃខាងលើ ។

◆ ប្រាក់តាមទន្លេ សមុទ្រជិត សមុទ្រឆ្ងាយ មានការខុសគ្នា ។

**មាត្រា៧:** បញ្ជាក់មុខងារបុគ្គលិកមួយនាក់ៗ:

◆ បុគ្គលិកចិនម្នាក់ៗសុទ្ធតែមានអត្តសញ្ញាបត្ររបស់ខ្លួនដូចជាលិខិតឆ្លងដែន បញ្ជាក់ថាជានាវិកចិន ។

◆ នៅ យ៉ុង ខាង ក្រសួងគមនាគមន៍ចិនចេញឲ្យចំពោះនាវិកចិន ។

◆ ចំពោះមិត្តកម្ពុជាធ្វើការនៅ យ៉ុង ខាង ត្រូវកម្ពុជា ចេញឲ្យ បញ្ជាក់ថា ជានាវិកសញ្ជាតិកម្ពុជា ។

◆ ក្រៅពីអត្តសញ្ញាបត្រ ត្រូវមានសញ្ញាបត្របញ្ជាក់មុខងាររបស់ខ្លួន ។

◆ នាវិកធម្មតាកម្ពុជា រដ្ឋាភិបាលកម្ពុជាចេញឲ្យ ។

◆ បើកម្មាភិបាលឬអ្នកបច្ចេកទេស ត្រូវប្រទេសចិនចេញឲ្យ ។

◆ បើខបទ្វេហេតុកើតឡើង សញ្ញាបត្រនេះ វាបញ្ជាក់ពីសមត្ថភាពធ្វើការ ។

◆ បើគ្មានសញ្ញាបត្រទុកជាក្រៅច្បាប់ បើធ្វើត្រូវក៏ទុកជាខុសដែរ ។

**មាត្រា១០:** អំពីអង្គការទាក់ទងគ្នា:

◆ ខាងចិន: ក្រុមហ៊ុនទូទៅនៅប្រទេសចិនជាអ្នកទាក់ទង តើប្រទេសកម្ពុជា អង្គការណាជាអ្នកទាក់ទង ។

◆ ត្រូវមានអង្គការស្របគ្នា ដើម្បីទាក់ទងគ្នាបាន ។

◆ កប៉ាល់ត្រូវដើរមួយឆ្នាំ ត្រូវបូករួម បូកសរុប ដើម្បីដឹងសភាពការណ៍ ។

◆ អង្គការទាំងពីរត្រូវទាក់ទងគ្នា ដើម្បីដោះស្រាយបញ្ហា ។

◆ ឯកសារត្រូវឯកភាពគ្នា ដើម្បីដំណើរការឲ្យបានល្អ ។

◆ កប៉ាល់ យ៉ុង ខាង នេះជាសំខាន់សម្រាប់ពាណិជ្ជកម្មបរទេសរបស់កម្ពុជា ។ បញ្ហាដឹកជញ្ជូនតាមផ្លូវណាត្រូវសាកសួរគ្នាជាញឹកញាប់ ។

◆ ស្នើស.មខបនាយកបញ្ជាក់អង្គការមួយសម្រាប់ទាក់ទងគ្នា ។

◆ របៀបទាក់ទងគ្នា: ទូរលេខ ទូរស័ព្ទ សំបុត្រទាក់ទងគ្នាទៅវិញទៅមក ។

**មាត្រា១១:** ឥឡូវក្រុមហ៊ុនចិនធ្វើអាជីវកម្ម ក្រុមហ៊ុនចិនត្រូវយកឈ្នួលពាក់កណ្តាលនៃអាជីវកម្ម ។

◆ បើធម្មតាត្រូវយកពី៣ទៅ៥ភាគរយ ។

◆ គ្រប់គ្រងកប៉ាល់ត្រូវមានបុគ្គលិក ។ កប៉ាល់នីមួយៗត្រូវមានបុគ្គលិកដោយឡែកពីគ្នា ។

◆ ក្រុមហ៊ុនតាវ៉ាចរចិនបើមានទាក់ទងទូរលេខត្រូវក្រុមហ៊ុនចេញឲ្យ ។

◆ ត្រូវមានសោហ៊ុយគ្រប់គ្រងកប៉ាល់ ។

◆ ចំពោះពិធីសារនេះត្រូវបញ្ជាក់ជូនតាមសេចក្តីរាយការណ៍ខាងលើ ។

**ខាងយើង:** ក្រុមហ៊ុនដឹកជញ្ជូនតាមសមុទ្រ អមក្រសួងពាណិជ្ជកម្មក្រៅប្រទេសកម្ពុជាប្រជាធិបតេយ្យ (អង្គការរបស់យើង) តំណាងក្រុមហ៊ុននេះ ដំណើរការបានដើម្បីទាក់ទង ។

**មិត្តចិន:** ស្នើកំណត់ការជួបគ្នា ទាក់ទងក្រសួងនេះ ឬក្រសួងផ្សេងៗ ។

**ខាងយើង:** ៦ខែបាន ឬទេ?

**មិត្តចិន:** បើគ្មានបញ្ហាពិសេស មួយឆ្នាំជួបគ្នាម្តង ។ ពេលធម្មតាដឹកជញ្ជូនអ្វីខ្លះ ទាក់ទងទូរលេខទៅក្រុមហ៊ុនណា? ទូរលេខទាក់ទងគ្នា?

**ខាងយើង:** បម្រុងចាត់ចែងទូរលេខសម្រាប់ទាក់ទងគ្នាដែរ ។ សព្វថ្ងៃតាមទូតយឺតណាស់ដោយច្របូកច្របល់គ្នា ។

**មិត្តចិន:** យ៉ុង ខាង តាំងពីដំណើរការមកមានទាក់ទងទៅហុងកុងច្រើនណាស់ ។ ភាគីកម្ពុជាចង់ដាក់ទំនិញអ្វីត្រូវប្រាប់ទៅចិន ។ បើទាក់ទងមិនស្រួលនាំឲ្យអាក់រអួល ។ មធ្យោបាយទាក់ទងគ្នាត្រូវឲ្យឆាប់រហ័ស ។

**ស.ម ម៉ា:** បើទូរលេខទាំងអស់នៅតាមស្ថានទូត មានការលំបាក ។ អ្នកធ្វើការមានកម្រិតដែរ ។ តាមរយៈស្ថានទូតគឺយឺត

ពេល ។ មួយថ្ងៃទាក់ទងតែ២-៣ដងទេ មិនជាប់ ។

**មិត្តចិនៈ** បញ្ហាទាក់ទងត្រូវប្រញាប់ ព្រោះ យ៉ុង ខាង ដំណើរការហើយ ។

**ខាងយើងៈ** កំពុងធ្វើ ត្រូវទាមទារមួយរយៈ ។ យើងខ្ញុំកំពុងប្រឹងប្រែង ។ បញ្ហាទាក់ទងមិនទាន់ឆ្លើយ ស្នើទាក់ទងតាមទូត ។ មួយឆ្នាំយើងជួបគ្នាមួយដង ។

**ស.មចិនៈ** បើអត់មានបញ្ហាទេ មួយឆ្នាំជួបគ្នាមួយដង ប៉ុន្តែបើបញ្ហាពិសេស ជួបពិសេស ។ សំខាន់បញ្ហាទូរលេខ ត្រូវដោះស្រាយបន្ទាន់ ។

**ខាងយើងៈ** យល់ព្រមតាមបទខទ្ទេសនាមហើយ ។

**មិត្តចិនៈ** ចង់បានមតិពីកម្ពុជា ។

**ខាងយើងៈ** បញ្ហាទី១-២ ជាបញ្ហាបច្ចេកទេសទេ ។ ស្នើមិត្តចិនកាន់កាប់ មើលបញ្ហានេះផង ។ ខាងយើងយកបញ្ហាគោលជំហរនយោបាយ សតិអារម្មណ៍ជាសំខាន់ បើបញ្ហាបច្ចេកទេសខ្វះខាតខ្វះៗ ។

**មិត្តចិនៈ** យល់ស្របតាមបងវ៉ាន់ ។ ខាងចិន ក៏យកបញ្ហានយោបាយ សតិអារម្មណ៍ជាសំខាន់ ។ បច្ចុប្បន្ន បើយកបច្ចេក-ទេសខ្វះខ្ពស់ជាងប្រធានកប៉ាល់ទៅទៀត ។ សតិអារម្មណ៍ម្នាក់ៗចេះតែប្រែប្រួល ត្រូវពិនិត្យបន្តបន្ទាប់ ។ មិត្តកម្ពុជាមុនជ្រើសរើសនាវិក តើកម្រិតនយោបាយដែរឬទេ?

**ខាងយើងៈ** ជ្រើសរើសពីយោធា នេសាទសមុទ្រដែលស្គាល់សមុទ្រខ្វះៗហើយ ។

--*--

**បញ្ហាគ្រប់គ្រងនិងថែទាំៈ**

◆ ភារកិច្ចដើរសមុទ្រឆ្ងាយមានដូចតទៅៈ

១) បំរើពាណិជ្ជកម្មក្រៅប្រទេសរបស់ខ្លួន ភារកិច្ចជំនួយបរទេស សេដ្ឋកិច្ចគោរពនយោបាយ ។

២) ប្រមូលសន្សំទុនសម្រាប់ជាតិ ពង្រីកផលិតកម្ម ។

៣) ភារកិច្ចបណ្តុះបណ្តាលសតិអារម្មណ៍ នយោបាយ និងបច្ចេកទេស

◆ មានជួរបច្ចេកទេសល្អ ទើបបម្រើសេដ្ឋកិច្ចបាន ។

◆ កប៉ាល់ យ៉ុង ខាង បម្រើពាណិជ្ជកម្មក្រៅប្រទេសកម្ពុជាប្រជាធិបតេយ្យគ្រប់គ្រងដំបូងត្រូវគិតគូរដល់បញ្ហានេះ ។

◆ ពិភាក្សាទាក់ទងដល់បញ្ហានេះ ។

◆ ខិតខំមួយឆ្នាំៗ ត្រូវរកចំណេញដែរ ។

◆ បើគ្រប់គ្រងល្អមុខជាមានចំណេញខ្វះ ។

ស្នើមតិខ្វះដើម្បីអាជីវកម្មបានល្អៈ

◆ មានកប៉ាល់មួយ ហើយទុកជាឧបករណ៍ផលិតកម្ម កុំឲ្យផ្អាកដំណើរ ។ មួយនាទីសុទ្ធតែចំណេញទាំងអស់ ។

◆ មិនចេះតែដើរទេ ត្រូវមានអ្វីដឹក ។

◆ គិតគណនេយ្យត្រួសៗដូចតទៅៈ

● យ៉ុង ខាង ផ្អាកមួយថ្ងៃត្រូវអស់១៥៥២ដុល្លារអាមេរិក

● បើសិនដើរមួយថ្ងៃអស់៣.១៨០ដុល្លារអាមេរិក

● យកមួយថ្ងៃគុណនឹងមួយឆ្នាំ ឃើញខាតប៉ុន្មាន? បើមិនដំណើរការមួយឆ្នាំខាតជាង៥០០.០០០ដុល្លារ ។

◆ ត្រូវគិតគ្រប់មធ្យោបាយឲ្យកប៉ាល់នេះធ្វើដំណើរចុះឡើងៗជានិច្ច ។

◆ កប៉ាល់ធ្វើដំណើរម្តងឲ្យពេញបន្ទុកជាការល្អ វៀរលែងតែទឹកកាន់តែពេញកាន់តែល្អ មួយជើងឈប់មួយកន្លែងកាន់តែល្អ ច្រើនកន្លែងកាន់តែខាត ។ ចូលផែគេសោហ៊ុយធ្ងន់ណាស់ ។

◆ កប៉ាល់ យ៉ុង ខាង នៅវ៉ាំងពូ ត្រូវអស់តម្លៃ១៨.៦២៤ ដុល្លារអាមេរិក(ចំនួន១២ថ្ងៃ) ។

◆ នៅកំពង់ផែ KOBE (ជប៉ុន) ១៣ថ្ងៃត្រូវអស់២០.១៧៦ ដុល្លារអាមេរិក ។

◆ ដាក់ទំនិញនៅវ៉ាំពូ ដាក់ទំនិញនៅជប៉ុន ៣.៦០០តោន បានប្រាក់៣.០០៨ដុល្លារអាមេរិក(ចំណេញសុទ្ធ) ។

◆ យ៉ុង ខាង ទៅដឹកទំនិញនៅជប៉ុន បើទៅទទេខាតជាង ៨០.០០០ដុល្លារអាមេរិក ។ ដល់ដឹកទំនិញទៅបានចំណេញខាងលើ ។ ទៅដឹកឥវ៉ាន់១៩០តោន បានប្រាក់ឈ្នួលតែ ៥.០០០ដុល្លារអាមេរិក ។ សោហ៊ុយដើមជាង១០.០០០ ដុល្លារអាមេរិក បានន័យថាខាត៥.០០០ដុល្លារអារមេរិក ។

◆ ដំណើរទាំងមូល ចិន-ជប៉ុន ផែពីរសិង្ហបូរី ចំណេញខ្វះដែរ បើចេញទទេខាត ។ នៅផែជប៉ុន ដឹកទំនិញតិចពេកក៏ខាតដែរ ។



# សមមិត្ត

# អៀង សារី



◆ និយាយបញ្ហានេះ មុននឹងទៅដឹកទំនិញនៅផែនីមួយៗ ត្រូវគិតចំនួនទម្ងន់ៗ ផែនីមួយៗត្រូវឲ្យដឹកយ៉ាងតិចពី៤០០ទៅ ៥០០តោន បើតិចខាត ។

◆ តម្លៃដឹកជញ្ជូនខ្ពស់ទាប ខុសគ្នាច្រើន ។

◆ បើដឹកក្រួសថ្ម ប្រាក់ឈ្នួលបានតិច ។ បើដឹកក្រណាត់ សំពត់ ប្រាក់ឈ្នួលបានថ្លៃ ។

◆ កប៉ាល់ដឹក ត្រូវមានទំនិញច្រើនឲ្យបានតម្លៃច្រើន ។

◆ បើចំនួនតិច របស់គ្មានតម្លៃ យើងចំណេញតិច ។

◆ យ៉ុង ខាង នេះថ្ងៃក្រោយដឹកទំនិញបម្រើពាណិជ្ជកម្មក្រៅប្រទេសកម្ពុជាប្រជាធិបតេយ្យមិនអីទេ ត្រូវគិតចំណេញខ្លះ ។

◆ ត្រូវគិតដើរសមុទ្រណា ។

◆ តាមកិច្ចព្រមព្រៀងនេះ ដើរវាងចិន-កម្ពុជា អាស៊ី-អាគ្នេយ៍ ប៉ុន្តែផ្លូវទៅជប៉ុនក៏មិនអីដែរ ។ ស្នើកំណត់ក្របខ័ណ្ឌតាមពិធីសារ ។

◆ មិត្តកម្ពុជាទិញឥវ៉ាន់តាមផែមួយឲ្យប្រមូលផ្តុំឥវ៉ាន់ច្រើន ។

◆ រឿងទិញទំនិញនៅជប៉ុនមានផែពីរមិនប្រមូលផ្តុំ យើងខាតច្រើនណាស់ ។

◆ កប៉ាល់ចេញដំណើរមួយជើងកុំឲ្យឈប់ច្រើនផែពេកនាំឲ្យខាត ។ លើកនេះ ចិន-ជប៉ុន-ហុងកុង-សិង្ហបុរី បូកសរុបបានតែ៣០០០តោន ។ បើដាក់ទំនិញ៥០០០តោនក្នុងផែទាំងបួន យើងចំណេញ ។

◆ កប៉ាល់ យ៉ុង ខាង គិតឲ្យរួមផ្សំការងារជាមួយកប៉ាល់ចិនល្អជាង ។

◆ ខាងចិនត្រូវការដឹកឥវ៉ាន់មកកម្ពុជាច្រើនដែរ ។

◆ ត្រូវមានគ្រោងការនិងផែនការហ្មត់ចត់ជាមុន ទៅផែណាខ្លះ ដឹកឥវ៉ាន់ប៉ុន្មាន?

◆ បើយើងខ្ញុំដឹងផែនការជាមុនដើម្បីដឹកឥវ៉ាន់ ផែណាត្រូវចូល ផែណាមិនត្រូវចូល ត្រូវគិតដែរ ។

◆ បើឧបមាថាត្រូវទៅផែជប៉ុន មិនចំណេញកុំទៅឲ្យប្រមូលមកហុងកុងវិញ ចំណេញជាង ។

◆ យ៉ុង ខាង មួយគ្រឿង ពុំអាចបម្រើពាណិជ្ជកម្មក្រៅប្រទេសកម្ពុជាបានទេ ត្រូវរួមផ្សំនឹងកប៉ាល់ចិន ។

◆ ត្រូវដឹកឥវ៉ាន់អ្វីខ្លះ ចំនួន ខ្នាត ត្រូវដឹងជាមុន ទម្ងន់ហួសសមត្ថភាពជងសន្ទូច ។

◆ ក្នុងទំនិញ ចំណោមទំនិញមានគ្រោះថ្នាក់ដែលអាចឲ្យឆេះ ឬផ្ទុះ ទំនិញមានកុងត្រាលេខប៉ុន្មាន?

◆ តាមពិសោធន៍លើកទី១ បញ្ហាទាំងប៉ុន្មានខាងលើមិនច្បាស់ ។

◆ កប៉ាល់មួយដឹកឥវ៉ាន់សុទ្ធតែវិទ្យាសាស្ត្រដែរ ។

◆ ភារកិច្ចប្រធានកប៉ាល់ ដាក់ឥវ៉ាន់ក្នុងកប៉ាល់ឲ្យសមហេតុសមផល ដូចម្តេចហៅថា សមហេតុសមផល?

◆ ទំនិញដាក់ដោយគ្មានគ្រោះថ្នាក់ ។

◆ នាវាដើរឲ្យនឹងនរ ខាងក្រោមស្រាលខាងលើធ្ងន់ពុំអាចដើរស្រួលទេ ក្នុងបាតឥវ៉ាន់ធ្ងន់ ខាងលើស្រាល ឬផ្ទុយ វាអាចរលាក់ ទំនិញចល័តចុះឡើង ។

◆ ប្រធានកប៉ាល់ត្រូវគិតកត្តាទាំងនេះ ដើម្បីផ្ទុកទំនិញ ។

◆ បើមានទំនិញមានគ្រោះថ្នាក់ ត្រូវចាត់វិធានការពិសេស មានតែដាក់ក្រោមទឹក វាមិនងាយឆេះ ។

◆ មានរបស់ខ្លះមិនអាចដាក់ក្នុងឃ្លុប ត្រូវដាក់ខាងលើ បើមានគ្រោះថ្នាក់ ងាយបោះចោល ។

◆ បើត្រូវការដើរច្រើនខែ ត្រូវគិតសភាពការណ៍ជាមុន ។

◆ ផែណាត្រូវដឹកមុន ផែណាដឹកក្រោយ ទាក់ទងការលើកដាក់ចុះឡើង ប៉ះពាល់ច្រើន ។

◆ កប៉ាល់ យ៉ុង ខាង មានឃ្លុបទឹកកក ប្រាក់ឈ្នួលថ្លៃជាងគេ មានបុគ្គលិកម្នាក់សម្រាប់ថែទាំឃ្លុបនេះ ។ ម៉ាស៊ីនឃ្លុបត្រជាក់ត្រូវប្រើញឹកញាប់ បើមិនប្រើអាចខូច ផ្អាកមួយឆ្នាំ ត្រូវជួសជុលម្តងទៀត ។ ឃ្លុបត្រជាក់ត្រូវតែមានឥវ៉ាន់ដាក់ ។ ចេញពីកំពង់សោម ដឹកត្រី បង្កង ត្រូវមានឃ្លុបត្រជាក់មកពីហុងកុង មិនបាច់ប្រើទេ ។ ទំនិញធម្មតាមិនត្រូវដាក់ក្នុងឃ្លុបទឹកកកទេ បើស្អុយទៀត ថ្ងៃក្រោយពុំអាចដាក់អ្វីទៀតបាន បើធ្ងន់ពេក ក៏មិនបាន អាចងាយខូច ។ ធ្វើយ៉ាងម៉េចប្រើឃ្លុបទឹកកកនេះឲ្យបានសមហេតុផល ។

បញ្ឈប់ការខទ្វេសនាមនៅម៉ោង១៧ ខាងយើងស្នើសួរពីបញ្ហាបណ្តុះបណ្តាលនាវិកកប៉ាល់ ។ មិត្តចិនៈ សព្វថ្ងៃសុទ្ធតែនាវាចិនទាំងអស់ ។ នឹងរាយការណ៍ថ្ងៃស្អែក ២៧ មិថុនាទៀត ។

# ការសន្ទនារបស់សមមិត្ត អៀង សារី នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៧៦


អៀង សារី

នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៧៦ ឧបនាយករដ្ឋមន្ត្រី អៀង សារី ទទួលជួបសន្ទនាជាមួយសមមិត្ត ផាន ហៀន អនុរដ្ឋមន្ត្រីក្រសួងការបរទេសសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ។ ចូលរួមនៅក្នុងពេលនោះដែរ ខាងភាគីកម្ពុជាមាន សមមិត្ត មុត សមមិត្ត តូច សមមិត្ត ផន និងសមមិត្ត កង់ ។ ខាងភាគីវៀតណាមមាន សមមិត្ត ផៀង ស៊ីង សមមិត្ត ផៀង ធឿង សមមិត្ត ផាំ ទ្រុង ហ៊ីវ និងសមមិត្ត គីវ មិញ ។

ក្រោយពីសំណេះសំណាលបន្តិចមក សមមិត្ត ផាន ហៀន បានខទ្មេសនាមដូចតទៅៈ

យើងខ្ញុំបានទទួលភារកិច្ចពីបងទ្រិញ ដែលផ្តាំសួរសុខទុក្ខចំពោះបង ។ គាត់សូមជូនពរស័ព្ទសាធុការ សូមបងមានសុខភាពបរិបូណ៌ ដឹកនាំកិច្ចការបរទេសប្រកបតែជ័យជម្នះ ។ បងឡេ ដឹកថ ក៏បានផ្តាំសួរសុខទុក្ខចំពោះបង ។ បងទ្រិញ ក៏បានផ្តាំសួរសុខទុក្ខតាមរយៈបង ដល់បណ្តាមិត្តដែលធ្វើការនៅក្នុងក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ ។ បងទ្រិញ ក៏សូមឲ្យខ្ញុំជូនពរដល់បងមួយចំនួន ។ ឈរលើស្មារតីបក្សយើងទាំងពីរ រដ្ឋអំណាចយើងទាំងពីរ ប្រជាជនយើងទាំងពីរជាបងប្អូន យើងខ្ញុំសង្ឃឹមថាមានសហប្រត្តិបត្តិការដ៏ស្និទ្ធស្នាលរវាងក្រសួងការបរទេសទាំងពីរ និងសង្ឃឹមថានឹងបានជូនដំណឹងគ្នាទៅវិញទៅមកជារឿយៗ ។ នៅលើសមរភូមិទូតក៏ដូចលើសមរភូមិឯទៀត យើងខ្ញុំតែងតែជូនដំណឹង ឬតាមទូតកម្ពុជានៅហាណូយ ឬតាមទូតវៀតណាមទាំងពីរនៅកម្ពុជា ។

ក្នុងការសន្ទនានេះ ផាន ហៀន បានជម្រាបជូនលោកឧបនាយករដ្ឋមន្ត្រី អៀង សារី នូវចំណុចបីៈ ទី១) សភាពការណ៍នៅវៀតណាមអំពីការបោះឆ្នោតទូទៅ ទី២) សន្និសីទប្រទេសមិនចូលបក្សសម្ព័ន្ធ និង ទី៣) អន្តការអាស៊ាន ។

***អំពីការបោះឆ្នោតទូទៅៈ***

ក្នុងការបោះឆ្នោតទូទៅនេះ ផាន ហៀន បានលើកឡើងថា«ពេលដែលបងហាយ បងណាំ ទទួលយើងខ្ញុំ យើងខ្ញុំបានជម្រាបពត៌មានខ្លះៗហើយ ។ បង ស៊ុន ធុយ មានបំណងចង់ឲ្យខ្ញុំជូនដំណឹងអំពីការនេះដល់បងណាស់ ពីព្រោះគាត់នៅក្នុងគណៈអន្តប្រធានរៀបចំបោះឆ្នោត ។ ការបោះឆ្នោតទូទៅថ្មីៗនេះជាមហាជ័យជម្នះរបស់យើងខ្ញុំ ។ តាមពិត នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៧៦ ការបោះឆ្នោតត្រូវបានប្រព្រឹត្តទៅពីម៉ោង៧ព្រឹក ដល់ម៉ោង៧ល្ងាច ។ តែកន្លែងខ្លះមានការបោះឆ្នោតរួចស្រេចនៅម៉ោង១២ៈ០០ ។ ដល់ម៉ោង១៥ៈ០០ ទូទាំងប្រទេសបោះឆ្នោតសម្រេចហើយ ។ មណ្ឌលបោះឆ្នោតមាននៅក្នុងខេត្តទាំង៣៥ និងក្រុងទាំង៣ ដែលមជ្ឈិមគ្រប់គ្រងផ្ទាល់ ។ ក្នុងប្រជាជន១០០០០នាក់ មានតំណាង១នាក់ តំណាងទាំងអស់មាន៤៩២នាក់ ខាងត្បូងមានតំណាង២៤៣នាក់ ខាងជើងមានតំណាង២៤៩នាក់ ។ នៅខាងជើងបោះឆ្នោតមានសណ្តាប់ធ្នាប់គ្មានស្មុគស្មាញទេ ពីព្រោះធ្លាប់ធ្វើមកហើយ ។ នៅខាងត្បូងពួកទាហានចាស់ ពួករដ្ឋអំណាចចាស់ ទាល់តែមានអំណាច ឃុំស្មើហើយថ្នាក់ស្រុកយល់ព្រម ទើបមានសិទ្ធិបោះឆ្នោត ។ មានកន្លែងខ្លះមានការតវ៉ាថា ហេតុអ្វីបានជាមិនបានបោះឆ្នោត ។ ករណីរបៀបនេះមានតម្លៃណាស់នៅវៀតណាមខាងត្បូង ។ ដូច្នេះបាន

ជាក្រោយពេលបោះឆ្នោត មានអ្នកខ្លះដើរទិញប័ណ្ណនេះ ។ ក្នុងនេះក៏មានអ្នកសមាសភាពមិនល្អ ចង់បានប័ណ្ណនេះដែរ ។ យើងឃើញការនេះទាន់ពេលវេលា ។»

ផាន ហៀន បានលើកឡើងទៀតថា «បេក្ខជននៅភាគខាងជើង ត្រូវបានឧទ្ទេសនាមឡើងដោយរណសិរ្សមាតុភូមិវៀតណាម នៅខាងត្បូងដោយរណសិរ្សជាតិសេរីភា ។ អ្នកចូលរួមបោះឆ្នោតមានភាគច្រើនលើសលប់ ។ កន្លែងណាក៏លើសពី៩៥ភាគរយ ។ ការបោះឆ្នោតបានប្រព្រឹត្តទៅទូទាំងប្រទេសដោយសន្តិសុខល្អ ។ សម្លេងប្រមូលផ្តុំទៅលើអ្នកដឹកនាំ ។ និយាយរួម អ្នកដឹកនាំបានសន្លឹកឆ្នោតជាង៩០ភាគរយ ។ ពួកកម្លាំងទី៣ និងបក្ខជនវ័យក្មេងបានសន្លឹកឆ្នោតពី៦០ ទៅ៧០ភាគរយ ។»

ផាន ហៀន បានបញ្ជាក់ថា «ការបោះឆ្នោតប្រព្រឹត្តទៅក្នុងបរិយាកាសរីករាយដូចបុណ្យធំ គួរឲ្យរំភើបណាស់ ។ អ្នកយកព័ត៌មានបរទេសបានសុំចូលទៅពិនិត្យការបោះឆ្នោតច្រើនណាស់ មានអ្នកមកពីប្រទេសសង្គមនិយមក៏មាន មូលធននិយមក៏មាន ។ គេសុំចូលមកច្រើនណាស់ តែលទ្ធភាពទទួលយើងខ្ញុំមានកម្រិត ។ បងប្អូនទទួលខុសត្រូវខាងព័ត៌មានរាយការណ៍មកថា មានអ្នកចេះតែចូលដោយឥតច្បាប់ ដូចជាលោកឆត្រយោង ។ អ្នកខ្លះឡើងយន្តហោះមកតែម្តង ទូតបរទេសប្រចាំនៅវៀតណាមសូមឲ្យជនជាតិខ្លួនបានចូលមកច្រើន ។ ភាគច្រើននៃអ្នកចូលមក សុំទៅភាគខាងត្បូង ពីព្រោះគេចង់ដឹងថាតើមានកើតហេតុអ្វីទេ ។ តែគេសប្បាយណាស់ ពីព្រោះយើងខ្ញុំធ្វើបានល្អ ។»

ផាន ហៀន បានបញ្ជាក់ទៀតថា «ការបោះឆ្នោតបានប្រព្រឹត្តទៅដោយជ័យជម្នះធំ ។ នេះសឲ្យឃើញថា ប្រជាជនភាគទាំងពីរមានឯកភាពគ្នាខាងនយោបាយ ។ នេះក៏ធ្វើឲ្យយើងឃើញច្បាស់ថា ប្រជាជនខាងត្បូងមានសំណូមពរឯករាជ្យ សន្តិភាព និងសង្គមនិយម ។ នេះជាបរាជ័យយ៉ាងធំរបស់ពួកប្រតិកិរិយាដែលនៅសេសសល់ ។ ពួកវាមានគម្រោងធ្វើយ៉ាងណាឲ្យបានចូលក្នុងគណៈកម្មការបោះឆ្នោត ។ ប៉ុន្តែចុងក្រោយបំផុតពួកវាបរាជ័យទាំងស្រុង ។»

ផាន ហៀន បានបញ្ជាក់បន្ថែមថា «ក្នុងរយៈពេល៦០ ថ្ងៃក្រោយបោះឆ្នោត រដ្ឋសភាយើងខ្ញុំនឹងប្រជុំដើម្បីជ្រើសតាំងរដ្ឋាភិបាលរួមនៃប្រទេសជាតិទាំងមូល និងពិនិត្យសេចក្តីព្រាងរដ្ឋធម្មនុញ្ញថ្មី ។ ដូច្នេះ បងៗយើងខ្ញុំត្រូវប្រជុំដើម្បីរៀបចំជ្រើសតាំងរដ្ឋាភិបាលរួម និងការងារទាំងឡាយ ។ កន្លងទៅ ការនេះជាការធំដែលសូមជូនជ្រាប ។»

មុននឹងឈានចូលដល់ចំណុចទី២ ស្តីអំពីសន្និសីទនៅបណ្តាប្រទេសមិនចូលបក្សសម្ព័ន្ធ ផាន ហៀន បានបញ្ជាក់ថា «ខាងសេដ្ឋកិច្ចយើងខ្ញុំកំពុងគិតគូររកស្បៀងអាហារ វត្ថុធាតុដើម និងគ្រឿងបន្លាស់សម្រាប់ឲ្យរោងចក្រដើរ ។ សេចក្តីព្រាងផែនការ៥ឆ្នាំ យើងខ្ញុំកំពុងត្រៀមរៀបចំ ហើយនិងយកទៅរាយការណ៍ជូនមហាសន្និបាតដើម្បីអនុវត្ត ។»

**អំពីសន្និសីទនៅបណ្តាប្រទេសមិនចូលបក្សសម្ព័ន្ធ**

ផាន ហៀន បានជម្រាបជូនសមមិត្តឧបនាយករដ្ឋមន្ត្រី អៀង សារី ថា «ដូចបងជ្រាបហើយ ខែសីហា នៅកូឡុំបូនឹងមានសន្និសីទកំពូលប្រទេសមិនចូលបក្សសម្ព័ន្ធ ។ យើងខ្ញុំយល់ថាតាំងពីប្រជុំនៅអាល់ស៊េរីមក ចលនាមិនចូលបក្សសម្ព័ន្ធបានក្លាយជាកម្លាំងមួយថ្មីប្រឆាំងនឹងចក្រពត្តិនិយមនិងអាណានិគមនិយមចាស់-ថ្មី ហើយក្រោយពីសន្និសីទលីម៉ា ចលនានេះកាន់តែមាននាទីសំខាន់ក្នុងជីវភាពអន្តរជាតិ ។ បងផុង ដែលបានចូលរួមនៅលីម៉ា ក៏បានជ្រាបច្បាស់លាស់ណាស់ ។»

ផាន ហៀន បានបន្តទៀតថា «ការដែលគួរឲ្យយកចិត្តទុកដាក់ គឺតាំងពីឆ្នាំ១៩៧៣ មានបញ្ហាប្រេងឥន្ធនៈ ។ សមរភូមិសេដ្ឋកិច្ច ក៏ជាសមរភូមិមួយយ៉ាងក្តៅប្រឆាំងនឹងចក្រពត្តិនិយម ។ ជារួម មួយថ្ងៃទៅមួយថ្ងៃ ចលនានេះរីកចម្រើននាំឲ្យអំណោយផលដល់ការប្រឆាំងចក្រពត្តិ ។ ប៉ុន្តែចលនានេះក៏មានការខ្សោយរបស់វា និងមានការស្មុគស្មាញ ។ ក្រៅពីបណ្តាប្រទេសសង្គមនិយមដូចយើងទាំងអស់គ្នា ភាគច្រើនជាប្រទេសដែលនាយទុនក្តាប់អំណាច ។ គេជាប្រទេសរណបនាយទុនដែលរីកចម្រើនហើយ ។ មានប្រទេសមួយចំនួនតិច ក៏ត្រូវខាងចក្រពត្តិវាសង្កត់ខាងនយោបាយនិងសេដ្ឋកិច្ច ។»

ផាន ហៀន បញ្ជាក់ថា «សន្និសីទកូឡុំបូនឹងប្រព្រឹត្តទៅនៅក្នុងសភាពការណ៍អន្តរជាតិអនុគ្រោះ ពិសេសក្រោយជ័យជម្នះវៀតណាម កម្ពុជា លាវ ។ មហាជ័យជម្នះដ៏មហិមានៅ

វៀតណាម កម្ពុជា លាវ កំពុងតែជំរុញយ៉ាងខ្លាំងដល់ចលនានេះ ដែលយើងពុំទាន់ប៉ាន់ប្រមាណអស់ទេ ។ តែទៅថ្ងៃអនាគត មុខជាមានបញ្ហាស្មុគស្មាញច្រើន ។ ចក្រពត្តិអាមេរិកកំពុងបំបែកសាមគ្គីនិងបំផ្លាញចលនានេះ ។»

ដាន ហៀន បានក៏បញ្ជាក់ដែរថា «ចំពោះតំបន់អាស៊ី-អាគ្នេយ៍និងប៉ាស៊ីហ្វិក អាមេរិក បានបញ្ចេញទ្រឹស្តីហ្វ័រដ៍ ។ ពួកវាកំពុងឆ្លៀតប្រើអង្គការអាស៊ាន ដើម្បីប្រមូលកម្លាំង ។ យើងខ្ញុំសន្យាថា ប្រទេសដែលពីដើមមានទាទីក្នុងចលនា កំពុងធ្វើសកម្មភាពខ្លាំងក្លា ។ ស្រីលង្កាជាម្ចាស់ផ្ទះកំពុងជួបប្រទះការលំបាកសេដ្ឋកិច្ចនិងផ្ទៃក្នុង ដោយទទួលឥទ្ធិពលបរទេស ។ ប្រទេសជាច្រើនដូចជាឥណ្ឌា អាល់ហ្សេរី យូហ្គោស្លាវី កំពុងធ្វើសកម្មភាពរៀបចំដែរ ។ ហ្វីលីពីន ថៃ ឥណ្ឌូណេស៊ី កំពុងធ្វើសកម្មភាព ។ ហេតុនេះនៅក្នុងសន្និសីទខាងមុខ បញ្ហាតំបន់អាស៊ី-អាគ្នេយ៍ជាបញ្ហាមួយសំខាន់ណាស់ដែរ ។»

ភាគីវៀតណាមយកចិត្តទុកដាក់ជាខ្លាំងដល់ការចូលរួមប្រាស្រ័យក្នុងសន្និសីទប្រទេសមិនចូលបក្សសម្ព័ន្ធលើកនេះ ។ ពេលនោះពិតជានឹងមានគណៈប្រតិភូមួយរបស់វៀតណាមចូលរួម ។ តែត្រង់សមមិត្តណាចូលរួម វៀតណាមមិនទាន់បញ្ជាក់ឲ្យដឹងនៅឡើយទេ ។ ពេលនោះគឺខែសីហា វៀតណាម បានឯកភាពគ្នាហើយ ។ ដូច្នេះមានគណៈប្រតិភូតែមួយ ។

វៀតណាមប្រុងជាស្រេចនឹងចូលរួមជាមួយប្រទេសជឿនលឿនក្នុងគោលបំណងដូចខាងក្រោមៈ

១) ធ្វើសកម្មភាពយ៉ាងសកម្មដើម្បីបង្កើនសាមគ្គីភាពជាមួយប្រទេសមិនចូលបក្សសម្ព័ន្ធ និងឆ្លៀតដណ្តើមសមានចិត្តនិងការគាំទ្រពីប្រទេសទាំងនោះចំពោះបដិវត្តវៀតណាម ។

២) គាំទ្រយ៉ាងសកម្មដល់ចលនាឯករាជ្យជាតិ និងជំរុញនិន្នាការប្រឆាំងចក្រពត្តិ ។ ពង្រីកសាមគ្គីភាពបណ្តុំកម្លាំងប្រឆាំងនឹងចក្រពត្តិ ។ រួមវិភាគទានដើម្បីសម្រេចផលនិងចលនារីកចម្រើន ។ វៀតណាមនឹងប្រមូលកម្លាំងជាមុខព្រួញប្រឆាំងនឹងចក្រពត្តិនិយមអាណានិគមនិយមថ្មី-ចាស់ ពិសេសចក្រពត្តិអាមេរិក វៀតណាមនឹងបរិហារពីនយោបាយជ្រៀតជ្រែក និងឈ្លានពានរបស់អាមេរិកនៅអាស៊ី-អាគ្នេយ៍ បរិហារទ្រឹស្តីហ្វ័រដ៍ពិសេសទាមទារឲ្យបំបាត់មូលដ្ឋានសឹកនៅបរទេស ទាមទារឲ្យកម្លាំងឈ្លានពានរបស់អាមេរិកដកចេញផុតពីប្រទេសទាំងឡាយពិសេសនៅអាស៊ី-អាគ្នេយ៍ ។ គាំទ្រប្រជាជនកូរ៉េ ទាមទារឲ្យកងទ័ពអាមេរិកចេញផុតពីកូរ៉េខាងត្បូង ។ គាំទ្រការតស៊ូប្រជាជននៅអាស៊ី អាហ្វ្រិក អាមេរិកឡាទីន ដើម្បីដណ្តើមយកនិងការពារសិទ្ធិជាតិជាមូលដ្ឋាន ។ វៀតណាមក៏រួមចំណែកក្នុងការតស៊ូរបស់ប្រទេសមិនចូលបក្សសម្ព័ន្ធ ដើម្បីការពារធនធានធម្មជាតិ និងសេដ្ឋកិច្ចជាតិប្រឆាំងនឹងការប្លន់ភោគទ្រព្យទាំងនេះពីសំណាក់ចក្រពត្តិអាមេរិក ។

អំពីការចាត់តាំងបញ្ចូលសមាជិកថ្មីនោះ វៀតណាមប្តេជ្ញាការពាររក្សាលក្ខណៈសម្បត្តិ ៥«៦» ដើម្បីបញ្ចូលសមាជិកថ្មីពិសេស«៧»ដែលថា មិនឲ្យចូលបក្សសម្ព័ន្ធយោធាណារបស់ចក្រពត្តិ និងមិនទុកឲ្យចក្រពត្តិបោះមូលដ្ឋានយោធានៅប្រទេសខ្លួនឡើយ ។

អំពីការបង្កើនសាមគ្គីភាពក្នុងចំណោមប្រទេសមិនចូលបក្សសម្ព័ន្ធ វៀតណាមខិតខំយ៉ាងណាតស៊ូបំបាត់ឬបន្ថយឲ្យនៅតិចបំផុត រាល់កត្តាដែលនាំឲ្យបែកសាមគ្គីគ្នា និងប្រទាញប្រទង់គ្នារវាងប្រទេសមិនចូលបក្សសម្ព័ន្ធ ។

វៀតណាមខិតខំបង្កើនសាមគ្គីគ្នារវាងប្រទេសមិនចូលបក្សសម្ព័ន្ធនិងប្រទេសសង្គមនិយម ។ វៀតណាមខិតខំធ្វើកុំឲ្យមានកត្តាបច្ច័យដល់សន្និសីទ ដូចជាយកបញ្ហាដែលមិនស្រុះស្រួលគ្នារវាងប្រទេសសង្គមនិយមចូលទៅក្នុងសន្និសីទ ។

ដាន ហៀន បានបញ្ជាក់នូវបំណងរបស់ខ្លួនថា «យើងខ្ញុំចង់ឲ្យមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងប្រទេសមិនចូលបក្សសម្ព័ន្ធនិងប្រទេសសង្គមនិយម និងរវាងវៀតណាមកម្ពុជា លាវ គុយបា កូរ៉េ ។ រវាងវៀតណាមនិងកម្ពុជា មានប្រពៃណីតែងជួបគ្នា ។ សំខាន់បំផុតនៅលីម៉ា បងថុង ក៏បានជួបយើងខ្ញុំ ។ យើងខ្ញុំគិតថានៅកូឡុំបូ ចំពោះមុខសភាពការណ៍យ៉ាងនេះ ការជួបសន្ទនារវាងគណៈប្រតិភូយើងទាំងពីរចាំបាច់ណាស់ ។ ចំពោះបញ្ហាចូលរួមប្រាស្រ័យក្នុងសន្និសីទក្នុងពេលរៀបចំនេះ យើងខ្ញុំសង្ឃឹមថានឹងមានការពិគ្រោះគ្នារវាងវៀត-ណាមនិងកម្ពុជា ដើម្បីត្រៀម ។»

ដាន ហៀន បានបញ្ជាក់ដែរថា «មានបញ្ហាមួយពិសេស

ដែលទាក់ទងវៀតណាម កម្ពុជា លាវ គឺបញ្ហាមូលនិធិដើម្បីជួយវៀតណាម កម្ពុជា លាវ។ សេចក្តីសម្រេចអំពីបញ្ហានេះនៅលីម៉ា មានអត្ថន័យនយោបាយ ដើម្បីបង្កើនសាមគ្គីភាពរវាងប្រទេសមិនចូលបក្សសម្ព័ន្ធ ។»

វៀតណាមចង់ឲ្យសេចក្តីសម្រេចចិត្តនេះមានការអនុវត្ត ។ តែអនុវត្តយ៉ាងណាត្រូវមានការព្រមព្រៀងគ្នារវាងប្រទេសទាំងឡាយនិងការយល់ស្របរបស់ប្រទេសកម្ពុជានិងលាវផង ។ ចំពោះបញ្ហានេះ វៀតណាមយល់ថា ចាំបាច់ត្រូវផ្លាស់ប្តូរមតិគ្នារវាងប្រទេសទាំងបី វៀតណាម កម្ពុជា លាវ ដោយឈរលើស្មារតីសាមគ្គីភាព គោរពគ្នា ដើម្បីឲ្យមានវិធីអនុវត្តប្រសើរបំផុតនិងដើម្បីឲ្យសន្និសីទឃើញថាប្រទេសទាំងបីរួមសាមគ្គីគ្នាល្អ ។ ដោយចង់ឆ្លៀតយកសេចក្តីអនុមតិយ៉ាងល្អបំផុតនៅសន្និសីទ បានជាវៀតណាមចង់ឲ្យភាគីកម្ពុជាមានមតិអំពីបញ្ហានេះ ។

ដាន ហៀន បានបញ្ជាក់ចំពោះសន្និសីទនេះថា «តាមការពិត របៀបវារៈនៃសន្និសីទវែងណាស់ ។ ថ្ងៃក្រោយអ្នកបច្ចេកទេសនឹងពិនិត្យពិចារណា ។ សន្និសីទប្រព្រឹត្តទៅនៅស្រីលង្កានៅក្នុងតំបន់យើង ។ បើប្រព្រឹត្តទៅល្អ នោះនឹងមានឥទ្ធិពលល្អដល់យើង ។»

### អំពីបញ្ហា «អាស៊ាន»

ដាន ហៀន បានរាយការណ៍ថា «ការប្រជុំអាស៊ានថ្មីៗនេះបានឲ្យយើងដឹងជាច្រើនអំពីអង្គការនេះ ។ ក្នុងពេលនោះ នៅអាមេរិកនិងប្រទេសអាស៊ាន មានកាសែតនិងសេចក្តីថ្លែងការណ៍ជាច្រើនដែលមួលបង្កាច់តវិយាបថវៀតណាមចំពោះអាស៊ាន ។ វាថាវៀតណាមអំពាវនាវឲ្យចលនាបដិវត្តងើបឡើងក្នុងប្រទេសអាស៊ាន ។ ការពិត យើងខ្ញុំរក្សានិងគោរពគោលជំហរយើងខ្ញុំជានិច្ច មុនក៏ដូចក្រោយ ចំពោះអាស៊ាន ។ យើងខ្ញុំបានដឹងច្បាស់ថា អាស៊ានបានកើតឡើងដើម្បីប្រឆាំងវៀតណាម លាវ និងកម្ពុជានៅឆ្នាំ១៩៦៧ ។ មានប្រទេសមួយចំនួនបានបញ្ជូនកងទ័ព និងប្រទេសមួយចំនួនជាមូលដ្ឋានកងទ័ពឧបត្ថម្ភដល់កងទ័ពអាមេរិក ឲ្យដៃឲ្យអាមេរិកឈ្លានពានយើង ។ ខាងការទូត នៅឆ្នាំ១៩៧០ ពួកគេបានជួយអាមេរិកក្នុងសន្និសីទយ៉ាកាតា ដើម្បីគាំទ្រ លន់ ណុល ។ នៅឆ្នាំ១៩៧២ ពួកគេបានស្នើកិច្ចដោះស្រាយមួយអំពីបញ្ហាវៀតណាម សមស្របតាមផលប្រយោជន៍របស់អាមេរិក ។ ក្រោយជ័យជម្នះ វៀតណាម កម្ពុជា លាវ ពួកគេភិតភ័យតក់ស្លុតចំពោះឥទ្ធិពលនៃបដិវត្តយើង ។ ប្រទេសមួយចំនួនបានទុកដែនដីគេឲ្យអាមេរិកដើម្បីប្រឆាំងយើង ។ ម្យ៉ាងទៀត គេរកគ្រប់វិធី និងឧបាយកល ដើម្បីប្រឆាំងនឹងយើងរាំងរាចលនាបដិវត្តនៅប្រទេសគេ និងរាំងរាចលនាសន្តិភាពឯករាជ្យ អព្យាក្រឹត ដែលកំពុងផុសផុលក្នុងតំបន់នេះ ។»

ដាន ហៀន បានបន្តថា «សន្និសីទអាស៊ានថ្មីៗនេះ នៅខែកុម្ភៈ ឆ្នាំ១៩៧៦ បាននិយាយអំពីសន្តិភាព និងអព្យាក្រឹត ប៉ុន្តែមិនបានទាមទារឲ្យកងទ័ពអាមេរិកដកចេញទេ ។ គេនិយាយតែពីសហការខាងសេដ្ឋកិច្ច ។ ប៉ុន្តែគេពិភាក្សាដោយលួចលាក់អំពីសហប្រតិបត្តការខាងសន្តិសុខ ។ គេចេះតែប្រកែកថាពុំមានបញ្ហាអ្វីពីអាមេរិកទេក្នុងកិច្ចការរបស់គេ ។ ប៉ុន្តែការពិតក្រោយពី ហ៊្វរដ៍ ទៅទស្សនាតំបន់នេះ វាបានបញ្ចេញទ្រឹស្តីហ៊្វរដ៍ ។ វាបញ្ចេញនេះក្រោយពីវាទៅហ៊ីលីពីននិងឥណ្ឌូនេស៊ី ហើយក្រោយពីបានប្រជុំជាមួយគ្នា ។»

ដាន ហៀន បានបញ្ជាក់ថា «ក្នុងទ្រឹស្តីហ៊្វរដ៍ ក៏បាននិយាយពីអាស៊ានថា អាស៊ានជាមិត្តរបស់អាមេរិក ហើយអាមេរិកនឹងឧបត្ថម្ភអាស៊ានតទៅទៀត ។ តពីនោះ ហ៊្វរដ៍ ក៏បានបន្ថែមជំនួយដល់ឥណ្ឌូនេស៊ី ។ ហេតុនេះហើយបានជាយើងខ្ញុំឃើញថា អាមេរិកមិនទាន់លះបង់ចោលគោលបំណងឈ្លានពានរបស់វានៅតំបន់នេះទេ ។ ដោយវាបរាជ័យនៅវៀតណាម កម្ពុជា លាវ វាកំពុងរករូបភាពថ្មី ដើម្បីបន្តកម្លាំង ប្រើដៃជើងវាប្រឆាំងនឹងប្រទេសយើងនៅឥណ្ឌូចិន ។ ប៉ុន្តែយើងខ្ញុំដឹងថា ផ្ទៃក្នុងអាស៊ានមានទំនាស់ច្រើន ។ ពួកគេមានការលំបាកច្រើនក្នុងការប្រឆាំងចលនាជឿនលឿនក្នុងប្រទេស ។ រវាងប្រទេសអាស៊ានមានទំនាស់គ្នាខាងសេដ្ឋកិច្ចជាតិជាងខាងសាសនា ។ មានប្រទេសខ្លះចង់ដើរតួលើសគេ ដូចជាឥណ្ឌូនេស៊ីនិងថៃ ។ ដូច្នេះទំនាស់គ្នា គោលការណ៍យើងខ្ញុំចំពោះអាស៊ាន យើងខ្ញុំបានប្រកាសជាច្រើនលើក ។»

ចំពោះអាស៊ាន វៀតណាមបានប្រកាសថាៈ

ទី១) យើងខ្ញុំបន្តជ្រោងទង់ប្រឆាំងចក្រពត្តិ អាណានិគមថ្មីចាស់ ពិសេសចក្រពត្តអាមេរិក នៅតំបន់នេះ ។

ទី២) យើងខ្ញុំប្តេជ្ញាគាំទ្រទាំងស្រុងដាច់ខាតនូវការតស៊ូប្រឆាំងនឹងអាមេរិកដើម្បីឯករាជ្យ សន្តិភាព អព្យាក្រឹត និងវឌ្ឍនភាពសង្គមក្នុងតំបន់នេះ ។ យើងខ្ញុំគាំទ្រនិន្នាការឯករាជ្យ សន្តិភាព អព្យាក្រឹត នៅតំបន់នេះ ។

ទី៣) យើងចង់ទាក់ទងជាមួយប្រទេសទាំងនេះដោយឈរលើគោលការណ៍រួមរស់ដោយសន្តិភាព ។ ដោយមានគោល-ការណ៍ចង់ទាក់ទងជាមួយប្រទេសទាំងនេះ យើងខ្ញុំមានសម្តែងជាក់ស្តែងចំពោះថៃនិងហ្វីលីពីន ។ លើមូលដ្ឋាននៃលក្ខការណ៍ទាំងនេះ យើងអាចមានការទាក់ទងផ្ទាល់ទ្វេភាគីជាមួយប្រទេសអាស៊ាន ។ យើងមិនចង់ស្គាល់មេត្រីនឹងអង្គការអាស៊ានទេ ។ ផ្ទុយទៅវិញ យើងខ្ញុំវែកមុខវា ។ នយោបាយរបស់យើងខ្ញុំចំពោះអាស៊ី-អាគ្នេយ៍ បានផ្អែកលើមូលដ្ឋានមួយដ៏ត្រឹមត្រូវគឺសាមគ្គីភាពមិនអាចរង្គោះរង្គើរវាងវៀតណាមនិងកម្ពុជា រវាងវៀតណាមនិងលាវ និងរវាងប្រទេសទាំងបី ។ ការចូលរួមសាមគ្គីរវាងប្រទេសទាំងបីមានបច្ច័យសំខាន់ចំពោះប្រទេសនៅអាស៊ី-អាគ្នេយ៍ ។ នៅលើមូលដ្ឋានគោលនយោបាយរួមចំពោះអាស៊ី-អាគ្នេយ៍ និងអាស៊ានយ៉ាងនេះ នៅសន្និសីទកូឡុំបូ យើងក៏មានអាកប្បកិរិយាចំពោះអាស៊ាននិងមានការស្នើចំពោះបញ្ហាការចូលរួមប្រាស្រ័យក្នុងសន្និសីទ ។

ផាន ហៀន បានបញ្ជាក់ទៀតថា “ចំពោះថៃ និយាយដោយឡែក ការទាក់ទងរបស់យើងខ្ញុំគ្មានអ្វីប្រែប្រួលទេ ដូចបងថុង ជ្រាប ។ ថ្មីៗនេះមានប្រកាសថាមានការទាក់ទងល្អ ។ តាំងពីបង្កើតរដ្ឋាភិបាលថ្មី គេថា កាសែតនិងវិទ្យុវៀតណាមមិនទិតៀនគេដោយប្រហែលមកពីវៀតណាមឃើញគេបន្តទាមទារឲ្យអាមេរិកដក ហេតុនេះបានជាវៀតណាមមិនទិតៀន ។ ការពិតការទាក់ទងរវាងវៀតណាមនិងថៃនៅដដែល គ្មានប្រែប្រួលអ្វី ។ កាលណាគេនិយាយប៉ះពាល់ដល់វៀតណាម យើងខ្ញុំតបវិញ ។ ឥឡូវយើងខ្ញុំចាំមើល ។ ដូចបងថុងជ្រាបស្រាប់ អ្នកនយោបាយថៃគេនិយាយម្យ៉ាង គេធ្វើម្យ៉ាងទៀត ។ បើគេមានអាកប្បកិរិយាទៀងទាត់ បើគេមានបំណងទាក់ទងល្អជាមួយប្រទេសជិតខាង យើងមិនប្រកែកទេ ។ ថៃជាប្រទេសជិតខាង ដូច្នេះយើងត្រូវយកចិត្តទុកដាក់ ។”

ផាន ហៀន បានបញ្ចប់បណ្តាំរបស់សមមិត្ត ទ្រិញ ថា “ឥណ្ឌូនេស៊ីគ្មានប្រែប្រួលទេ ។ អាដាំម៉ាលិច មាននិយាយជាច្រើន ម្តងយ៉ាងនេះ ម្តងយ៉ាងនោះ ។ បក្សនិងរដ្ឋាភិបាលយើងខ្ញុំយកចិត្តទុកដាក់ចំពោះប្រទេសអាស៊ី-អាគ្នេយ៍ ។ ពីព្រោះវាទាក់ទងផ្ទាល់នឹងវៀតណាម ហើយពីព្រោះជាកត្តាមួយដ៏សំខាន់ដល់ការកសាងសង្គមនិយម ។”

សមមិត្ត អៀង សារី មានប្រសាសន៍ថាៈ

“ជាដំបូង យើងខ្ញុំសូមសម្តែងអំណរគុណក្នុងនាមបក្សរដ្ឋាភិបាល និងប្រជាជនកម្ពុជា ចំពោះគណៈប្រតិភូវៀតណាមដែលបានធ្វើការនៅកម្ពុជា បានលទ្ធផលជាទីគាប់ចិត្ត ។ ក្នុងពេលស្នាក់អាស្រ័យរបស់សមមិត្ត យើងខ្ញុំខំអស់សមត្ថភាពដើម្បីឲ្យគណៈប្រតិភូដំណើរការបានល្អ ។ ប៉ុន្តែដោយយើងខ្ញុំទើបចេញពីសង្គ្រាម យើងខ្ញុំមានការខ្វះខាត ។ ដូច្នេះសូមសមមិត្តអធ្យាស្រ័យ ។ ព្រមជាមួយគ្នានេះ យើងខ្ញុំសូមបញ្ជាក់ដូចសមមិត្តលេខាយើងខ្ញុំថា សមមិត្តមកនេះជាប្រតិភូមែន ប៉ុន្តែអញ្ជើញមកផ្ទះបងប្អូន ។ ដូច្នេះយើងឥតប្រកែប្រកាន់ យើងគ្មានពិធីការ ។ ដោយស្មោះយើងធ្វើយ៉ាងណាពង្រឹងសាមគ្គីភាពមិត្តភាពមួយកម្រិតថែមទៀត ។ តាមសេចក្តីរាយការណ៍របស់គណៈប្រតិភូយើងខ្ញុំឃើញថា ការចរចាបានលទ្ធផលគួរជាទីគាប់ចិត្ត ។ ពីព្រោះថាក្នុងសភាពទើបចេញពីសង្គ្រាមមានការច្របូកច្របល់ ហើយបដិវត្តប្រទេសណាក៏ដោយ ក៏ត្រូវឆ្លងកាត់ការច្របូកច្របល់ ។ ថ្ងៃនេះយើងបានជួបគ្នា ឃើញច្បាស់នូវសាមគ្គីភាពនិងមិត្តភាពយើងទាំងពីរនិងសន្ទានចិត្តគ្នាទៅវិញទៅមក នេះជាលទ្ធផលល្អប្រសើរ ។ យើងជជែកគ្នាបានយល់គោលជំហរគ្នារៀងៗខ្លួន ។ ដូច្នេះការយោគយល់ យល់ដឹងគ្នា វានាំឲ្យយើងកាន់តែជិតស្និទ្ធគ្នាថែមទៀត ។ បើគ្មានការប្រជុំគ្នានោះគឺមិនយល់គ្នា ជាហេតុនាំឲ្យមានបច្ច័យអាក្រក់ ។ ទុកជាយើងមិនបានសម្រេចលទ្ធផលជាធំដុំ ប៉ុន្តែដោយជួបជុំគ្នា យើងយោគយល់គ្នា នេះជាការសំខាន់ នេះជាខ្លឹមសារយ៉ាងជ្រាលជ្រៅ ។ យើងឃើញថាសាមគ្គីភាពមិត្តភាពរវាងប្រទេសទាំងពីរជាការចាំបាច់ ។”

**(នៅមានត)**

**ឌួង សុភារិទ្ធ**

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

រៀបចំនិងចងក្រងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | ឈ្មោះដើម | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច | ផ្សេងៗ |
|---|---|---|---|---|---|---|
| ២៤៩ | សុម សូត្រ | មន្ទីរ គ-១៣ | បឹងត្របែក | ?? | ១៥-៥-៧៦ | |
| ២៥០ | ម៉ុម ម៉ាន់ ហៅ រ៉ុង | មន្ទីរ គ-១៣ | បឹងត្របែក | ?? | ១៥-៥-៧៦ | |
| ២៥១ | ដា ដៃ | ប្រធានមន្ទីរ អ.ក | បឹងត្របែក | ?? | ១៥-៥-៧៦ | |
| ២៥២ | ហង់ ឈុនហេង | រទេះភ្លើង | មុខកំពូល | ១៣-២-៧៦ | ១៥-៥-៧៦ | ឈឺស្លាប់ |
| ២៥៣ | ណុប សារុំ (ស្រី) | កម្មករ | តម្បាញ គ-៥ | ៥-៤-៧៦ | ១៥-៥-៧៦ | |
| ២៥៤ | ឆេង ដូនសឿន | ប្រពន្ធកម្មករ | អគ្គិសនីផ្សារតូច | ៥-៤-៧៦ | ១៥-៥-៧៦ | |
| ២៥៥ | ឯម ផល | ទាហានកាប៉ូរ៉ាល់ | កំពង់ស្ពឺ | ១៣-១-៧៦ | ១៥-៥-៧៦ | |
| ២៥៦ | ហ៊ុន វឿង | កម្មករ | តម្បាញ គ-៥ | ១៣-១-៧៦ | ១៥-៥-៧៦ | |
| ២៥៧ | ម៉ៅ សាម៉ាលី | កម្មករ | តម្បាញ គ-៥ | ១៣-១-៧៦ | ១៥-៥-៧៦ | |
| ២៥៨ | ត្រាំង វី | កម្មករឡានទឹក | កំពង់ស្ពឺ | ២២-១-៧៦ | ១៥-៥-៧៦ | |
| ២៥៩ | ឆេង រិន | កម្មករ | អគ្គិសនីផ្សារតូច | ៦-៤-៧៦ | ១៥-៥-៧៦ | |
| ២៦០ | ម៉ែន ទូច | កម្មករ | អគ្គិសនីផ្សារតូច | ៦-៤-៧៦ | ១៥-៥-៧៦ | |
| ២៦១ | ឡាយ ប៊ុនលី | កម្មករ | អគ្គិសនីផ្សារតូច | ៦-៤-៧៦ | ១៥-៥-៧៦ | |
| ២៦២ | លី សុផេង | គ្រូបង្រៀន | ?? | ១៣-៤-៧៦ | ១៥-៥-៧៦ | |
| ២៦៣ | អេង លាងហុង | និស្សិត | ?? | ២០-២-៧៦ | ១៥-៥-៧៦ | |
| ២៦៤ | នាក់ ដាបឡេង | យុទ្ធជន | ?? | ២២-៣-៧៦ | ១៥-៥-៧៦ | |
| ២៦៥ | ប្រឹក រស់ | ?? | កសិដ្ឋានតំបន់២៥ | ១៣-២-៧៦ | ១៥-៥-៧៦ | |
| ២៦៦ | អ៊ុំ ចាន់ថា | ប្រជាជន | ?? | ២៤-២-៧៦ | ១៥-៥-៧៦ | |
| ២៦៧ | គង់ សារិន | កម្មករ | រោងចក្រទឹកក្រូច | ២៣-២-៧៦ | ១៥-៥-៧៦ | |
| ២៦៨ | សុខ ស្រ៊ាង | ពេទ្យ | ?? | ២២-៣-៧៦ | ១៥-៥-៧៦ | |
| ២៦៩ | ម៉ី ចុល | កម្មករកៅស៊ូ | ?? | ២៣-១-៧៦ | ១៥-៥-៧៦ | |
| ២៧០ | មួរ រ៉េន | កម្មករ | អគ្គិសនីផ្សារតូច | ៦-៤-៧៦ | ១៥-៥-៧៦ | |
| ២៧១ | គាម ពុយ | កម្មករ | អគ្គិសនីផ្សារតូច | ៦-៣-៧៦ | ១៥-៥-៧៦ | |
| ២៧២ | គង់ លីយឿន | ទាហានពលទោ | ?? | ១៣-៤-៧៦ | ១៥-៥-៧៦ | |
| ២៧៣ | ចាប ផន | យុទ្ធជនសេដ្ឋកិច្ច | មុខកំពូល | ២១-៣-៧៦ | ១៥-៥-៧៦ | |
| ២៧៤ | ញ៉ឹក សារឿន | បុគ្គលិកប្រៃសណីយ៍ | ?? | ២២-៤-៧៦ | ១៥-៥-៧៦ | |
| ២៧៥ | ថាយ សុវណ្ណា | កម្មករ | អគ្គិសនីផ្សារតូច | ២៣-២-៧៦ | ១៥-៥-៧៦ | |
| ២៧៦ | ប៉ុក កាណែល | ពេទ្យស៊ីវិល | ?? | ២៣-៣-៧៦ | ១៥-៥-៧៦ | |
| ២៧៧ | វង សាន | កម្មករ | ថ្មពិល ថ-១ | ២៤-៤-៧៦ | ១៥-៥-៧៦ | |
| ២៧៨ | សំ ហម | ទាហានពលទោ | រ៉ាវរទេះភ្លើង | ?? | ១៨-៥-៧៦ | |

| | | | | | | |
|---|---|---|---|---|---|---|
| ២៧៩ | សេង ប៊ុនធឿន | ពាណិជ្ជកម្ម | ?? | ?? | ១៨-៥-៧៦ | |
| ២៨០ | ចាប ប៊ុនធឿន | ពាណិជ្ជកម្ម | ?? | ?? | ១៨-៥-៧៦ | |
| ២៨១ | ហាស់ សាន់ | ជនជាតិក្អែក | តំបន់២៥ | ?? | ១៨-៥-៧៦ | |
| ២៨២ | អ៊ូវ សេង ហៅ សាញ់ | គណៈធ-៥៦ | តំបន់២២ | ?? | ១៨-៥-៧៦ | |
| ២៨៣ | គល់ ថៃ ហៅ វង់ | ដឹកជញ្ជូន | បឹងត្របែក | ?? | ១៨-៥-៧៦ | |
| ២៨៤ | អ៊ូ ថេង ហៅ ស៊ីថុន | ជាងកាំភ្លើង | បឹងត្របែក | ?? | ១៨-៥-៧៦ | |
| ២៨៥ | គុញ ទន ហៅ សំអាត | ដឹកជញ្ជូន | បឹងត្របែក | ?? | ១៨-៥-៧៦ | |
| ២៨៦ | ពេជ សាមុត | ម-៥ បច្ចេកទេសតេអូ | បឹងត្របែក | ?? | ១៨-៥-៧៦ | |
| ២៨៧ | ជុំ លី ហៅ យ៉ាង | ម-៥ ធ្វើគ្រាប់បែក | បឹងត្របែក | ?? | ១៨-៥-៧៦ | |
| ២៨៨ | ជិន ឆឹង ហៅ កឿង | ម-៥ ជាងកាំភ្លើង | បឹងត្របែក | ?? | ១៨-៥-៧៦ | |
| ២៨៩ | សាច យែម ហៅ ខាន់ | ម-៥ ជាងតេអូ | បឹងត្របែក | ?? | ១៨-៥-៧៦ | |
| ២៩០ | ចក់ អែត ហៅ សឿន | ម-៥ យាមឃ្លាំង | បឹងត្របែក | ?? | ១៨-៥-៧៦ | |
| ២៩១ | ម៉ក់ យី | ម-៥ ជាងកាំភ្លើង | បឹងត្របែក | ?? | ១៨-៥-៧៦ | |
| ២៩២ | គោ កួន | ម-៥ ជាងកាំភ្លើង | បឹងត្របែក | ?? | ១៨-៥-៧៦ | |
| ២៩៣ | យ៉ាង យុន | ម-៥ ជាងកាំភ្លើង | បឹងត្របែក | ?? | ១៨-៥-៧៦ | |
| ២៩៤ | ព្រាប កប ហៅ គី | ម-៥ ជាងកាំភ្លើង | បឹងត្របែក | ?? | ១៨-៥-៧៦ | |
| ២៩៥ | សំ សារុន | ម-៥ ជាងវិទ្យុទូរស័ព្ទ | បឹងត្របែក | ?? | ១៨-៥-៧៦ | |
| ២៩៦ | ផាន់ ចែត ហៅ អ៊ុត | ម-៥ យាមឃ្លាំង | បឹងត្របែក | ?? | ១៨-៥-៧៦ | |
| ២៩៧ | អៀង ម៉ាន | យុទ្ធជន ១៨២ | តំបន់២៥ | ៣-១-៧៦ | ១៨-៥-៧៦ | ឃើស្លាប់ |
| ២៩៨ | សោម ឌឹម | ប្រធានរោងចក្រអារឈើ | តំបន់២៥ | ២៣-១២-៧៥ | ១៨-៥-៧៦ | ឃើស្លាប់ |
| ២៩៩ | អ៊ុម ស៊ីនឿន | កម្មកររោងចក្រកង់ឡាន | ព្រះនេត្រព្រះ | ២៧-៣-៧៦ | ១៨-៥-៧៦ | ឃើស្លាប់ |
| ៣០០ | ខៀវ យុកសោ | យុទ្ធជន | ពោធិចិនតុង | ២៣-៣-៧៦ | ១៨-៥-៧៦ | ឃើស្លាប់ |
| ៣០១ | ហួត ហាំ | យុទ្ធជន | ផ្សារចាស់ | ២៣-៣-៧៦ | ១៨-៥-៧៦ | ឃើស្លាប់ |
| ៣០២ | ឈាង ថៃ ហៅ ដឹណា | និស្សិតពេទ្យ | ភ្នំស្រុក | ១៣-២-៧៦ | ១៨-៥-៧៦ | ឃើស្លាប់ |
| ៣០៣ | កូវ ភិរិន | អគ្គិសនីចាក់អង្រែ | តំបន់២២ | ២២-២-៧៦ | ១៨-៥-៧៦ | ឃើស្លាប់ |
| ៣០៤ | យ៉ាន គឹមស៊ុន | គ្រូបង្រៀន | អូររាំងឪ | ២៩-១-៧៦ | ២០-៥-៧៦ | |
| ៣០៥ | ប្រាក់ សាវ | កម្មករ | រោងចក្រកង់ឡានក-១ | ៩-៥-៧៦ | ២០-៥-៧៦ | ឃើស្លាប់ |
| ៣០៦ | អ៊ីង សុផាលី ហៅ សុ សូផាវី | កម្មករ | ព្រះនេត្រព្រះ | ១៣-២-៧៦ | ២០-៥-៧៦ | ឃើស្លាប់ |
| ៣០៧ | ទេស ជិនកេង | ប៉ុស្តិខ្សែលួស | ភ្នំស្រុក | ១៧-២-៧៦ | ២០-៥-៧៦ | ឃើស្លាប់ |
| ៣០៨ | យិន សាវុធ | គ្រូបង្រៀន | តំបន់២៥ | ១៨-១២-៧៥ | ២០-៥-៧៦ | |
| ៣០៩ | នួន ពិសិត ហៅ នួន យ៉ុម | គ្រូបង្រៀន | តំបន់២៥ | ២១-១២-៧៥ | ២០-៥-៧៦ | |
| ៣១០ | ទាន វឿង | គ្រូបង្រៀន | មុខកំពូល | ២១-១២-៧៥ | ២០-៥-៧៦ | |
| ៣១១ | អេង លាងហេង | គ្រូបង្រៀន | មុខកំពូល | ២១-១២-៧៥ | ២០-៥-៧៦ | |
| ៣១២ | សោម សាវុធ ហៅ ម៉ក | គ្រូបង្រៀន | តំបន់១៥ | ២១-១២-៧៥ | ២០-៥-៧៦ | |
| ៣១៣ | ម៉ុម ទី | គ្រូបង្រៀន | មុខកំពូល | ២១-១២-៧៥ | ២០-៥-៧៦ | **(នៅមានត)** |

# ទិន្នន័យទីតាំងរួមនៃអំពើប្រល័យពូជសាសន៍

## ការធ្វើផែនទីវាលពិឃាតនៃប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៥-២០០០

(តចប់)

| ល.រ | ល.រទីតាំង | ឈ្មោះទីតាំង | ទិន្នន័យរណ្ដៅនិងជនរងគ្រោះ តាមជាក់ស្ដែង | | ទិន្នន័យរណ្ដៅនិងជនរងគ្រោះ តាមរបាយការណ៍ | | របាយការណ៍ ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|
| | | | ប៉ាន់ស្មានរណ្ដៅ | ប៉ាន់ស្មានជនរងគ្រោះ | ប៉ាន់ស្មានរណ្ដៅ | ប៉ាន់ស្មានជនរងគ្រោះ | |
| ៤៥៥ | ០៤០៤១០ | ត្រពាំងតាឃ្លោក | ៤០-៤៥ | ១៥០-២០០ | ជាង៤០ | ១៥០-២០០ | ២០០០ |
| ៤៥៦ | ០៨១១០១ | ត្រពាំងអារ៉ែងកំពួច | គ្មានស្នាកស្នាម | ៨០-១០០ | គ្មាន | ៨០-១០០ | ២០០០ |
| ៤៥៧ | ១២០១០៣ | មន្ទីរពេទ្យវិកលចរិត | ១៣០តូចៗ | ជាង១៣០ | ជាង១៣០ | ជាង១៣០ | ២០០០ |
| ៤៥៨ | ១២០១០៣ | ផ្ទះលេខ១៣៨ | ១ | ជាង១០ | ១ | ជាង១០ | ២០០០ |
| ៤៥៩ | ១៨០២១០ | ភ្នំក្រោល | គ្មាន | ៥ម៉ឺន | គ្មាន | ៥០០០០ | ២០០០ |
| ៤៦០ | ២០០៤០៧ | ព្រៃស្វឹក | ៤០០-៥០០ | ៥០០០ | ៤០០-៥០០ | រាប់ពាន់ | ២០០០ |
| ៤៦១ | ២០០៤០៨ | វាលស្វាយ | គ្មាន | ជាង១០០ | គ្មាន | ជាង១០០ | ២០០០ |
| ៤៦២ | ២១០២០១ | វត្តសូរភី | គ្មាន | គ្មាន | គ្មាន | គ្មាន | ២០០០ |
| ៤៦៣ | ២១០២០២ | វត្តសូរភី | ជាង១០០០ | ប្រហែល២ម៉ឺន | រាប់ពាន់ | ២ម៉ឺន | ២០០០ |
| ៤៦៤ | ២១០២០៣ | វត្តទ្រព្យគរ | គ្មាន | ប្រហែល២០០ | ៧៦ | ៣ម៉ឺន-៤ម៉ឺន | ២០០០ |
| ៤៦៥ | ២១០២០៤ | ត្រពាំងស្វង | ៧៦ | ជាង១ម៉ឺន | ៧៦ | ជាង៧០គ្រួសារ | ២០០០ |
| ៤៦៦ | ២១០២០៥ | ត្រពាំងប្រទាង | រាយប៉ាយ | ប្រហែល១០០ | គ្មាន | គ្មាន | ២០០០ |

តួលេខដែលចុះផ្សាយក្នុងលេខនេះសម្រាប់ខេត្ត កំពង់ឆ្នាំង កណ្ដាល ភ្នំពេញ ស្វាយរៀង និងតាកែវ ។

◆ ចំពោះពត៌មានមានដែលដាក់ថា "គ្មាន" មានន័យថាពុំមានសាក្សីឬតួលេខ ប៉ុន្តែវត្តមានទីតាំងបានមកពីប្រភពផ្សេងៗ ។

◆ ចំពោះពត៌មានជាក់ស្ដែងនិងពត៌មានតាមរបាយការណ៍មានន័យខុសគ្នាត្រង់ថា ពត៌មានជាក់ស្ដែងគឺបានមកពីសាក្សីដែលបញ្ជាក់ប្រាប់នៅទីតាំងកើតហេតុ ។ ពត៌មានតាមរបាយការណ៍មានន័យថា សាក្សីផ្សេងទៀតដែលប្រាប់តួលេខអំពីទីតាំងដដែល ។

កិច្ចការស្រាវជ្រាវនិងធ្វើផែនទីរណ្ដៅសាកសពជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យឬរបបខ្មែរក្រហម មិនទាន់ត្រូវបានបញ្ចប់នៅត្រឹមឆ្នាំ២០០០នៅឡើយទេ ។ ចាប់តាំងពីដើមឆ្នាំ២០០១មកទល់នឹងឆ្នាំ២០០២នេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបាននិងកំពុងស្រាវជ្រាវរកឃើញនូវទីតាំងប្រល័យពូជសាសន៍បន្ថែមមួយចំនួនទៀតនៅក្នុងខេត្តកំពង់ចាមមានចំនួន១៣ទីតាំង ខេត្តកំពង់ស្ពឺមានចំនួន១០ទីតាំង ខេត្តតាកែវមានចំនួន៧ទីតាំង ខេត្តកំពង់ធំមានចំនួន៤ទីតាំង ខេត្តកណ្ដាលមានចំនួន៣ទីតាំង និងខេត្តស្វាយរៀងមានចំនួន១ទីតាំង ។ ចំនួនទីតាំងសរុបទាំង៣៨ខាងលើនេះគឺជាទិន្នន័យដែលមជ្ឈមណ្ឌលឯកសារកម្ពុជាមានលទ្ធភាពចងក្រងបានតាមប្រព័ន្ធផ្កាយរណប ដែលបង្ហាញនូវរយៈទទឹងនិងចំណុចខ្សែស្របនៃភូមិសាស្ត្រក្នុងប្រទេសកម្ពុជា ។ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងធ្វើការងារនេះបន្តទៀត រហូតដល់ការស្រាវជ្រាវត្រូវបានរកឃើញថាគ្មានទីតាំងណាមួយដែលនៅសេសសល់និងមិនទាន់ត្រូវបានចុះទៅស្រាវជ្រាវឡើយ ។

**ផេង ពងរ៉ាស៊ី**




## សម្លេងពីមន្ទីរ ស-២១

### វគ្គទី៥: បង្ខំឱ្យឆ្លើយ

### ដោយសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ

**(តពីលេខមុន)**

ទោះបីជា «ការធ្វើនយោបាយ» មានមុខងារសំខាន់យ៉ាង នេះក៏ដោយ ក៏ទារុណកម្មនៅតែមាន ហើយ«ការធ្វើនយោបាយ» ជួនកាលអាចត្រូវបានមើលរំលង ។ វាពិបាកណាស់ក្នុងការសម្រេចថាតើការបញ្ជាយ៉ាងនេះចេញមកដោយសុទ្ធចិត្តនិងដាក់ឲ្យអនុវត្តជាប្រព័ន្ធ ឬក៏គេចង់លាក់បាំងអំពើរបស់ ឌុច និងកូនចៅតាមរយៈការិយាធិបតេយ្យ ប្រសិនបើ «បងៗថ្នាក់លើ» រកឃើញថាមានការលើសលោះក្នុងការអនុវត្តអំពើទារុណកម្ម ឬធ្វើឲ្យអ្នកទោសសំខាន់ណាម្នាក់ស្លាប់ដោយសារកំហឹងឬការធ្វើជ្រុលជ្រួសនោះ ។

សៀវភៅកំណត់ហេតុនេះបន្តទៀតថា «បន្ក្រាបវាដោយការឃោសនា ឬដោយការធ្វើទារុណកម្ម ប៉ុន្តែកុំឲ្យវាងាប់ ។ កុំឲ្យវាខ្សោយរហូតដល់យើងមិនអាចសួរវាបាននោះ...ការពារខ្មាំងកុំឲ្យ(អ្នកទោស)ងាប់ ។ កុំឲ្យពុកពីមួយទៅមួយ» ។

២ឆ្នាំក្រោយមក ចាន់ បានសរសេររបៀបដូចគ្នានេះដែរថា «សរសេររបាយ-ការណ៍វា មើលទឹកមុខវា ។ គាបវាខាងនយោបាយនិងវាយឲ្យទាល់តែចេញ ។ គិតតែពីធ្វើទារុណកម្មដូចជាដើរផ្នែកនយោបាយ(ដើម្បីយើងអាច) ដើរជើងពីរបាន» ។

បានសេចក្តីថា ការសួរចម្លើយដែលត្រូវបានប្រដូចទៅនឹង «ការដើរជើងម្ខាង» គឺនៅតែប្រើនៅឡើយទេ ។ នៅប្រហាក់ប្រហែលពេលជាមួយគ្នានេះដែរ ប៉ុន បានកត់សម្គាល់ថា «បញ្ហា» នៅមន្ទីរស-២១ មាន«ការវាយដំដែលធ្វើឲ្យកម្លាំងរបស់ខ្មាំងចុះខ្សោយ»និង«បញ្ហាធ្វើទារុណកម្មនៅតែធ្ងន់ធ្ងរពេកដដែល» ។ ប៉ុន បន្តរិះគន់អ្នកសួរចម្លើយម្នាក់ចំៗថា «វានិយាយថាវាវៃ(អ្នកទោស)តិចៗ តែតាមការពិតវៃខ្លាំងណាស់» ។

ទំនាស់នៅក្នុងការគិតរបស់ខ្មែរក្រហមដែលប៉ះពាល់ដល់ការអនុវត្តដាក់ស្តែងនៅមន្ទីរស-២១ កើតឡើងរវាងគំនិត «ឯករាជ្យម្ចាស់ការ»ដែលលើកឡើងដោយមោទកភាពរបស់របបកម្ពុជាប្រជាធិបតេយ្យ ជាមួយនឹងតម្រូវការរបស់អ្នកដើរតាមអង្គការដោយមិនបានគិតពិចារណាទៅលើតម្រូវការនេះ ។ «ឯករាជ្យម្ចាស់ការ»ប្រហែលជាមានន័យថា ផ្តាច់ចំណងដ៏គួរឲ្យគោរពពីអ្នកគាំទ្របដិវត្តន៍ ។ ដំណើរការនេះនាំដល់ការផ្តល់អំណាចទៅតាមឯករាជ្យភាពរបស់បុគ្គល ដោយសារថានេះជាតម្រូវការរបស់វិន័យបដិវត្តន៍ ។ ប្រជាជនត្រូវបានរំដោះចេញពីការពឹងពាក់ទៅជាការសាមគ្គីរបស់បក្ស ។ បុរសស្ត្រីដែលត្រូវបានផ្តល់អំណាចរួចហើយ បានក្លាយជាឧបករណ៍តំណាងឲ្យឆន្ទៈរបស់ប្រជាជន ពោលគឺចង់និយាយដល់អ្នកបម្រើបក្ស ។ ចំណុចលម្អិតនេះ ត្រូវបានធ្វើឲ្យបាត់បង់ដោយសារអ្នកចំណូលថ្មីដែលយល់ថាការងារធ្វើទារុណកម្មទៅលើ«សត្រូវ»របស់អង្គការ ឬ«អ្នកដែលមានទោសកំហុស» គឺមិនមែនជាការចាត់តាំងទេ ប៉ុន្តែចាត់ទុកថាជាសិទ្ធិទៅវិញ ។ នៅក្នុងករណីទាំងនេះ អំពើឃោរឃៅក្នុងការផ្តល់អំណាចបានបង្អាក់ដល់ការគោរពបញ្ជាដាច់ខាតរបស់បក្ស ។ ប៉ុន្តែស្ថិតក្រោមចំហាយរបស់បដិវត្តន៍ ការបែក«ឆ្វេង» មានពាក់ព័ន្ធជាមួយ«ខ្មាំង» ត្រូវបានធ្វើមិនដឹងមិនឮជារឿយៗ ។

### ទោសនៃការគោរពបញ្ជា

ឃ្លាសង្ខេបគោលការណ៍នៅមន្ទីរស-២១ ខុសពីពាក្យទំនឹមទំនៀមដ៏ល្បីល្បាញរបស់តាឡឺរ៉ាន់ ។ ឃ្លានេះប្រហែលជាមានន័យថា «ជាពិសេស(បង្ហាញពី)យតិភាពខ្លាំងហួសពេក» ។ ដូចដែលសៀវភៅកំណត់ហេតុឆ្នាំ១៩៧៦ បានសរសេរយ៉ាងដូច្នេះថា «ត្រូវចៀសវាងបញ្ហារួញរាឬស្ទាក់ស្ទើរក្នុងការធ្វើទារុណកម្ម ។ ធ្វើរបៀបនេះពិតជាមិនអាចយកចម្លើយពីខ្មាំងបានទេ...ត្រូវប្រកាន់ជំហរកុំរួញរាឬស្ទាក់ស្ទើរ ។ យើងត្រូវតែដាច់ខាត» ។

តើអ្នកណានឹងធ្វើការសម្រេច ហើយតើមានបញ្ហាអ្វីចំពោះអ្នកសួរចម្លើយនៅពេលដែល «ភាពដាច់ខាត» ប្រែក្លាយជា «ជ្រុលលើសលោះនោះ»?

អំពើឃោរឃៅយង់ឃ្នងធ្វើឡើងនៅមន្ទីរស-២១ និងនៅវាលពិឃាតជើងឯក ដូចគ្នាទៅនឹងអ្វីដែល ឃេលមែន និង ហាមីលតុន ហៅថា «ទោសនៃការគោរពបញ្ជា»។ ឃេលមែន និង ហាមីលតុន បានទាញសេចក្ដីសន្និដ្ឋាននេះ តាមស្នាដៃនិពន្ធរបស់ ស្ដេនលី មីលហ្គ្រាម និងអ្នកដទៃទៀត។ អ្នកសួរចម្លើយនៅមន្ទីរស-២១ ដែលធ្វើទារុណកម្មលើអ្នកទោស និងអ្នកដែលត្រូវបានចោទថាបានធ្វើឲ្យអ្នកទោសស្លាប់ ឆ្លើយថាមកពីបញ្ជាអ្នកដែលខ្លួនទទួលអំណាចហើយមិនបានសួរនាំ មួយផ្នែកមកពីការដែលថា បើហ៊ានសួររដ្ឋអំណាចនោះ ខ្លួននឹងស្លាប់ជាមិនខាន។ ហ្សីម៉ាន់ បូមែន ដែលសរសេរអំពីការសម្លាប់រង្គាលរបស់ណាហ្ស៊ីទៅលើជនជាតិជ្វីហ្វ បញ្ជាក់ថា «ការទប់ចិត្តមិនធ្វើអំពើឃោរឃៅចេះតែរេចរឹលទៅៗ» នៅពេលដែលអំពើឃោរឃៅទទួលបាននូវអនុញ្ញាតត្រឹមត្រូវនិងត្រូវគេធ្វើឲ្យទៅជាទម្លាប់ទៅហើយ និងនៅពេលដែលជនរងគ្រោះត្រូវបានបំបាត់ភាពជាមនុស្សអស់គ្មានសល់។ តួដួរៗ ក៏មានទស្សនៈប្រហាក់ប្រហែលគ្នានេះដែរ។ ជាងនេះទៅទៀត នៅពេលបង្កការឈឺចាប់និងសម្លាប់អ្នកទោស អ្នកសួរចម្លើយជាច្រើននៅមន្ទីរស-២១ និងពេជ្ឈឃាតនៅជើងឯក គិតថាខ្លួនគេបានឆ្លើយតបទៅនឹងថ្នាក់លើថាខ្លួនមានសីលធម៌និងវិន័យខ្លាំងជាងអ្វីដែលខ្លួនបានជួបប្រទះកន្លងមកទៅទៀត។ ដោយស្ថិតឯកោ ស្ថិតនៅជុំគ្នា និងប្រកបដោយការភ័យខ្លាច តែមិនទាន់ត្រូវបានគេផ្ដល់អំណាចឲ្យនោះមិនយូរប៉ុន្មាន យុវជនវ័យក្មេងទាំងនេះក៏បានក្លាយទៅជាឧបករណ៍ដ៏គួរឲ្យរន្ធត់។ ការសប្បាយដែលយុវជនវ័យក្មេងទាំងនេះបានមកពីការប្រព្រឹត្តអំពើឃោរឃៅ ក្នុងករណីខ្លះបានជួយផ្ដល់កម្លាំងចិត្តក្នុងការរស់នៅក្នុងគុក និងទទួលបាននិងកាន់កាប់ការអនុញ្ញាតរបស់ចៅហ្វាយនាយទៀតផង។

ភាគច្រើននៃយុវជនវ័យក្មេងទាំងនោះ មានចិត្តរីករាយក្នុងការបម្រើបដិវត្តន៍តាមការបញ្ចុះបញ្ចូលរបស់មេកើយខ្លួននិង «បងៗថ្នាក់លើ»ដែលមិនដែលឃើញមុខ។ នៅពេលក្លាយជា «អ្នកឯកទោស» ហើយ យុវជនវ័យក្មេងទាំងនេះ បើតាមពាក្យប្រធានម៉ៅនៃប្រទេសចិនថា គឺនៅ«ក្រហមឆ្អៅ» ជានិច្ច។ យុវជនទាំងនេះប្រហែលជាយល់ស្របជាមួយឆ្នាំក្រហមចិនដែលសរសេរថា «វាយមនុស្សស្លាប់គឺជារឿងតូចតាចប៉ុណ្ណោះ សំខាន់ត្រូវធ្វើបដិវត្តន៍បង្ក្រាបការងើបបះបោរនិងរក្សាភាពក្រហមឆ្អិនឆ្អៅឲ្យនៅគង់វង្ស»។

ចំពោះរឿងកម្ពុជាវិញ ចុងក្រោយបដិវត្តន៍ក៏ត្រូវដួលរលំ



«ការបះបោរ»ងើបឡើងនៅគ្រប់ទិសទី ហើយ«ភាពក្រហមឆ្អិនឆ្អៅ»ក៏ត្រូវបានបរិហារ។ ប៉ុន្មានឆ្នាំក្រោយ យើងក៏ដូចជាអ្នកនៅរស់រានមានជីវិត ត្រូវបានបន្សល់ទុកឲ្យនូវសម្លេងនិងស្រមោលនៃ«អំពើឃោរឃៅដ៏ច្រើនលើសលប់»។ យើងបានឃើញហេតុការណ៍ទាំងអស់នេះនៅពេលយើងបើកមើលឯកសារចម្លើយសារភាពមួយសន្លឹកម្ដងៗ ឬនៅពេលយើងថតចម្លងរូបថតពាក់កណ្ដាលខ្លួនរបស់អ្នកដែលសុំក្ដីមេត្តាឬខឹងនឹងអ្នកដែលកំពុងតែថតយករូបខ្លួន ហើយក្រោយពីខ្លួនត្រូវបានសម្លាប់អស់ពេលយ៉ាងយូរមក អ្នកទាំងនេះក៏បែរមកសម្លឹងហើយខឹងនឹងយើងម្ដង។ ឯកសារដែលនៅសេសសល់ទាំងនេះមានដូចជារូបថត កំណត់ហេតុរំពុក បញ្ជីឈ្មោះ ស្ថិតិ និងចម្លើយសារភាព បានបង្ហាញនូវការរីករាយ ការឈឺចាប់ និងភាពច្របូកច្របល់ដ៏អសោច ដែលក្លាយទៅជាវប្បធម៌និងភាពគួរឲ្យព្រឺព្រួចរៀងរាល់ថ្ងៃនៅមន្ទីរស-២១។

## រូបភាពមន្ទីរស-២១

យើងអាចខិតចូលកាន់តែជិតថែមទៀត ដើម្បីរកអ្វីដែល

"កើតឡើងជាក់ស្តែង"នៅពេលយើងចូលទៅទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ ចាត់ឌី លីដ្ឋវូដ ដែលធ្វើការនៅទួលស្លែងអស់ជាច្រើនខែក្នុងគម្រោងថតចម្លងម៉ៃក្រូហ្វីលខរណែល បានសរសេរថា "ពេលវេលាចេះតែរំកិលទៅមុខ អ្នកនឹងឃើញរូបភាពកាន់តែលម្អិត ។ ជាក់ស្តែងនៅកន្លែងឈប់សំចតនៅតាមជណ្តើរនានា មានប្រហោងដែលគេចោះជញ្ជាំងដើម្បីចាក់ទឹកសម្អាតតាមជណ្តើរនិងបង្កាន់ដៃ ។ នៅពីក្រោមកន្លែងចំហនៅផ្នែកខាងក្រៅ យើងនៅឃើញឈាមហូរធ្លាក់ចុះមកនៅឡើយដូចជាអគារហ្នឹងបង្ហូរឈាមខ្លួនឯងអ៊ីចឹង" ។

នៅពេលដើរចូលទៅកាន់តែជិតតាមច្រករបៀងយ៉ាងដូច្នេះ យើងកាន់តែជិតបាន"អាន"នូវអ្វីដែលកើតឡើងប្រចាំថ្ងៃនៅទីនេះ ។ ពេលយើងអានឯកសារមួយចំនួន វាបានទាញយើងឲ្យខិតទៅរកឯកសារផ្សេងទៀត ។ ឃ្លាប្រយោគត្រង់នេះមួយកន្លែង ត្រង់នោះមួយកន្លែង សំណេរក្រវេមក្រវាមរបស់អ្នកសួរចម្លើយ ឬទឹកមុខរបស់អ្នកទោសក្នុងរូបថតពាក់កណ្តាលខ្លួន អាចឆ្លុះបញ្ចាំងយ៉ាងច្បាស់នូវបទពិសោធន៍ទាំងស្រុងរបស់គុក ទោះបី



ជា"ការឆ្លុះបញ្ចាំង"បែបនេះមានភាពខុសៗគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតយ៉ាងណាក៏ដោយ ។ ចំពោះខ្ញុំវិញ សម្តីរបស់ ញ៉ែម អេន បានបញ្ជាក់ពីភាពព្រឺព្រួចជាប្រចាំដែលកើតឡើងនៅក្នុងគុក ។ នៅពេល ដូហ្វាស នីវិន សួរថា "តើអ្វីដែលគួរឲ្យរន្ធត់កើតឡើងនៅមន្ទីរស-២១ ដែល អេន នៅចងចាំបានដល់សព្វថ្ងៃ?" អេន ឆ្លើយថា "អ្វីដែលធ្វើឲ្យខ្ញុំព្រឺមែនទែននោះគឺនៅពេលខ្ញុំឃើញគេដឹកមនុស្សទាំងឡានៗចូល ហើយរុញទម្លាក់ចេញពីឡានដួលផ្ងាល់នឹងដី ។ កាលនោះខ្ញុំនៅក្មេងនៅឡើយ ដូច្នេះពេលឃើញហេតុការណ៍បែបនេះ ខ្ញុំខ្លាចខ្លាំងណាស់ ។ អ្នកទាំងនោះត្រូវគេរុំមុខជិត ហើយចងស្លាបសេក" ។

ដុយមកវិញ នៅពេលអ្នកទោសត្រូវដឹកចេញពីមន្ទីរស-២១ យកទៅសម្លាប់ចោល គេបានលើកអ្នកទោសម្តងមួយៗដាក់លើឡានដូចសត្វឆ្មាឬកូនក្មេងអ៊ីចឹង ។ ដូចដែល ហ៊ឹម ហ៊ុយ បាននិយាយទៅកាន់ ភីតធ័រ ម៉ាឃៀរ ថា "អ្នកទោសឡើងឡានមិនរួចទេ ពីព្រោះឡានខ្ពស់ពេក" ។

ការសម្លាប់ស្ទើរតែទាំងអស់ត្រូវបានធ្វើឡើងដោយសម្ងាត់និងនៅពេលយប់ ។ គក ស្រស់ បានរំឭកឡើងវិញថា នៅឆ្នាំ១៩៧៦ អ្នកទោសដែលគេចងមុខជិត ត្រូវយកទៅសម្លាប់ចោលនៅបរិវេណខាងលិចដោយសំពងនឹងព្រនង់ដែក ។ ស្លាប់កន្លែងណា កប់កន្លែងហ្នឹង ។ ចំណែកឯរណ្តៅនោះរាក់ទេមានជម្រៅប្រមាណតែ១ម៉ែត្រកន្លះប៉ុណ្ណោះ ។ ទោះបីជាការសម្លាប់មិនដែលត្រូវបានពិភាក្សាជាចំហក៏ដោយ ក៏ក្លិនសាកសពដែលស្អុយរហ៊ុមលាយឡំជាមួយនឹងក្លិនលាមកនិងទឹកនោមមិនអាចលាក់ជិតបានឡើយ ។

## "ការកម្ទេចខ្មាំង" នៅជើងឯក

នៅក្នុងអំឡុងឆ្នាំ១៩៧៧ នៅពេលដែលវិសុទ្ធកម្មមានសភាពកាន់តែខ្លាំងឡើងៗ គុកនៅមន្ទីរស-២១ឡើងពេញព្រៀបហើយកន្លែងកប់ខ្មោចនៅជិតនោះក៏ពេញទាំងអស់ ។ នៅពេលមួយក្នុងឆ្នាំ១៩៧៧ ម៉ុងខ្មោចចិននៅជិតភូមិជើងឯកដែលស្ថិតនៅភាគនិរតីទីក្រុងភ្នំពេញ ចម្ងាយ១៥គីឡូម៉ែត្រ ត្រូវបានយកមកប្រើជាវាលពិឃាត ។ ចំណែកឯអ្នកទោសសំខាន់ៗនៅតែបន្តសម្លាប់ចោលនៅក្នុងបរិវេណគុកដដែល ។ ទីតាំងនេះស្ថិតនៅជិតកន្លែងជំនាញការសេដ្ឋកិច្ចរបស់ចិនស្នាក់នៅ ។ គុកនិងមន្ទីរស-២១មានបំពាក់ភ្លើងអគ្គិសនីដើម្បីប្រតិបត្តិការផ្សារសម្លាប់មនុស្ស និងឲ្យឆ្មាំគុកអាននិងចុះហត្ថលេខាលើបញ្ជីឈ្មោះអ្នកទោសដែលត្រូវយកទៅសម្លាប់ចោល ។ កន្លែងនេះហើយជាកន្លែងដែល ញ៉ែម អេន ឃើញគេយកអ្នកទោសទៅ"កម្ទេច" ឬ "បោះចោល" ។ ក្រោយរកឃើញនៅឆ្នាំ១៩៨០ ទីតាំងនេះក៏ត្រូវបានប្រែក្លាយទៅជាកន្លែងទេសចរណ៍ក្រោមការដឹកនាំរបស់

វៀតណាម ។ កាលនោះ នៅមានកម្ទេចឆ្អឹងនិងសម្លៀកបំពាក់នៅជិតរណ្តៅដែលទើបគាស់ខ្មោចថ្មីៗនៅឡើយ ។

គក ស្រស់ និង ហ៊ឹម ហ៊ុយ មានមតិផ្ទុយគ្នាក្នុងការចងចាំរបស់ខ្លួនលើការសម្លាប់នេះ ។ គក ស្រស់ និយាយថា គាត់មិនដែលទៅជើងឯកទេ ។ ចំណែកឯ ហ៊ឹម ហ៊ុយ វិញ និយាយថាបានបើកឡានដឹកអ្នកទោសពេញៗទៅកាន់កន្លែងនោះជាញឹកញយ ហើយបានសម្លាប់មនុស្សដោយផ្ទាល់ដៃ«ពីរបីដង»ទៀតផង ។

តាម គក ស្រស់ និងញ៉ែម អេន ដែលត្រូវបានធ្វើសម្ភាសន៍ប៉ុន្មានខែក្រោយមកទៀត បានឲ្យដឹងថា នៅឆ្នាំ១៩៧៨ ហ៊ឹម ហ៊ុយ គឺជាអ្នកសម្លាប់ខ្លាំងជាងគេ ជាមនុស្សសំខាន់នៅក្នុងគុកនិងសកម្មជននៅក្នុងដំណើរការសម្លាប់មនុស្ស ។ វ៉ាន់ ណាត ដែលបានបង្ហាញរូបថតគាត់នៅឆ្នាំ១៩៩៦បានយល់ស្រប ចំពោះការអះអាងនេះ ។ គក ស្រស់ និយាយថា នៅឆ្នាំ ១៩៧៨ ហ៊ឹម ហ៊ុយ បានជ្រើសរើសក្រុមសម្លាប់ជាញឹកញាប់ ដែលក្រុមទាំងនោះ មាន «បុរសដែលអាចធ្វើអ្វីៗគ្រប់យ៉ាង» ។ អ្នកដែលមិនធ្លាប់មានបទពិសោធន៍សម្លាប់មនុស្សពីមុនមក គាត់មិនយកទេ ហើយពេជ្ឈឃាតមិនដែលនិយាយអំពីការសម្លាប់មនុស្សទេ ។ ជាញឹកញាប់ គក ស្រស់ បាននាំយកអ្នកទោសពីបន្ទប់តូចមកចំណុចប្រមូលផ្តុំនៅក្រៅរបងតែម្តង ។ គក ស្រស់ បញ្ជាក់ថា «នៅពេលអ្នកទោសឮថាគេមកយកខ្លួនទៅ អ្នកទោសបានព្យាយាមបំបាក់សោហើយតដៃជាមួយឆ្មាំគុក» ។ បន្តិចក្រោយមក សន្តិសុខក៏ចាប់ដាក់ឡាន ហើយយកទៅទិសខាងលិចដែលតាមទេវកថាខ្មែរហៅថា «ទិសមរណៈ» ។

ការរៀបរាប់ម្តងអឺចេះម្តងអឺចុះរបស់ ហ៊ឹម ហ៊ុយ អំពីការសម្លាប់នៅជើងឯក គឺគ្រាន់តែជាពត៌មានដំបូងដែលតែប៉ុណ្ណោះដែលយើងមានមកទល់ពេលនេះ ។ ពត៌មានបន្ទាប់មកទៀតគឺដកស្រង់ចេញពីកិច្ចសម្ភាសន៍ទាំងនេះ ដែលធ្វើឡើងនៅអំឡុងឆ្នាំ១៩៨៧និង១៩៩៧ ។

អ្នកទោសដែលត្រូវបានសម្លាប់នៅជើងឯករាល់ថ្ងៃមានចំនួនខុសគ្នា ជួនកាលមានរាប់សិបនាក់ ជួនកាលឡើងដល់៣០០នាក់ ។ ចំនួន៣០០នាក់នេះត្រូវបានកត់ត្រានៅក្នុងបញ្ជីនៅខែឧសភា ឆ្នាំ១៩៧៨ នៅពេលដែលការបោសសម្អាតភូមិភាគបូព៌ាឡើងដល់កម្រិត ។ ជាធម្មតា ក្នុងមួយខែប្តីសប្តាហ៍ម្តង មានរថយន្តដឹកមនុស្ស២ទៅ៣រថយន្តពីមន្ទីរស-២១ទៅជើងឯក ។ រថយន្តនីមួយៗមានឆ្មាំជិះ៣ទៅ៤នាក់និងមានអ្នកទោសពី២០ទៅ៣០នាក់ដែលញ័រខ្លួនចំប្រប់និងស្ងាត់មាត់ដូចគេចុក ។ នៅពេលរថយន្តមកដល់ទីតាំង ហ៊ុយ និយាយថា អ្នកទោសត្រូវបានប្រមូលផ្តុំមួយកន្លែងនៅផ្ទះតូចមួយដែលមានបញ្ជីរាយឈ្មោះអ្នកត្រូវសម្លាប់ហើយជាស្រេច ។ ឈ្មោះទាំងអស់នេះ សួស ធី ជាអ្នករៀបចំ ។ សួស ធី ជាប្រធានខាងធ្វើឯកសារ ។ បញ្ជីឈ្មោះសម្លាប់មួយចំនួនតូចនៅសល់រហូតដល់សព្វថ្ងៃ ។ ក្រោយមកគេបំបែកអ្នកទោសជាក្រុមតូចៗ បណ្តើរទៅកាន់ប្រឡាយនិងរណ្តៅដែលអ្នកប្រចាំការនៅជើងឯកបានជីកទុករួចជាស្រេច ។ ហ៊ឹម ហ៊ុយ បន្តរៀបរាប់យ៉ាងលម្អិតនិងស្ទើរតែមិនលម្អៀងថា «គេឲ្យអ្នកទោសលុតជង្គង់ចុះនៅមាត់រណ្តៅ ។ ដៃចងស្ពាយសេក ។ អ្នកទោសត្រូវបានវាយដោយដែកគោលរទេះត្រង់កញ្ចឹងក ជួនកាលវាយមួយដង ជួនកាលពីរដង... ។ ហ៊ឹ ជាអ្នកត្រួតពិនិត្យការសម្លាប់ទាំងនេះ និងជាអ្នកចុះឈ្មោះ ។ យើងយកឈ្មោះទៅឲ្យ សួស ធី វិញ ។ មិនមានបាត់ឈ្មោះអ្នកណាម្នាក់ឡើយ» ។

ហ៊ឹម ហ៊ុយ នឹកឃើញសំឡេងអ្នកទោសស្រែកយំ «សូមកុំសម្លាប់ខ្ញុំអី!» បន្ទាប់មកឮសម្រែក «អ៊ូយ» ។ ហ៊ឹម ហ៊ុយ បាននិយាយថា គាត់ធ្លាប់បានប្រាប់អ្នកទោសម្នាក់ថា បើខ្ញុំមិនសម្លាប់ឯងតាមគេបញ្ជាទេ គេច្បាស់ជាសម្លាប់ខ្ញុំវិញមិនខាន ។ នៅពេលសួរថាតើមាន«ភាពក្រៀមក្រំឬភ័យខ្លាចដែរឬទេ» ពេលនៅជើងឯក ហ៊ឹម ហ៊ុយ បានឆ្លើយតបវិញថា «ទេ ប៉ុន្តែជួនកាលខ្ញុំគិតថា តើគួរតែរត់ចេញពីទីនេះ តែបើរត់តើរត់ទៅណា តើទៅណាកើតបើគ្មានអាវុធផង? ប្រសិនបើខ្ញុំមានអាវុធនិងមានអីជិះវិញ ម៉្លេះ... ។ ខ្ញុំគិតដល់រឿងនេះច្រើនណាស់កាលនោះ» ។

ការសម្លាប់អ្នកដែលធ្លាប់ធ្វើការជាមួយពិតជាពិបាកណាស់សម្រាប់ ហ៊ឹម ហ៊ុយ ហើយមុនពេលអ្នកទាំងនោះស្លាប់ ហ៊ឹម ហ៊ុយ និយាយថា ជនរងគ្រោះទាំងនេះពិតជាបាន «ឃើញខ្ញុំមុខស្រពោនដល់កម្រិតណាជាមិនខាន» ។ ហ៊ឹម ហ៊ុយ នៅចាំបានថា មានពេលមួយ នៅពេលអ្នកទោសស្លាប់ហើយ សាកសពមួយចំនួនត្រូវដោះខោអាវដែលមានតម្លៃយកអស់ ។ ចំណែកឯសាកសពស្ត្រីវិញ

មិនមានអ្នកណាដោះយកទេ ។

នៅពេលយើងជួបវិប្បកម្មនៅមន្ទីរស-២១ វាដូចជាចង់តែធ្វើការវិនិច្ឆ័យភ្លាមៗ ប៉ុន្តែមកដល់ភ្លាមកាត់សេចក្តីអ្នកសួរចម្លើយឆ្នាំគុកឬអ្នកសម្លាប់ភ្លាមហាក់ដូចជាឆាយពេកហើយ ។ បើគ្មានបទពិសោធន៍ការទប់ចិត្តនិងការគាបសង្កត់ប្រហាក់ប្រហែលនេះទេ យើងមិនអាចនិយាយថាតើយើងគួរតែធ្វើយ៉ាងដូចម្តេច ប្រសិនបើយើងជាអ្នកសួរចម្លើយដែលត្រូវបានចាក់សោនៅក្នុងបន្ទប់តូច ជួបនឹងក្លិនអស់សង្ឃឹម និង«ខ្មាំង»ដែលត្រូវគេដកហូតតម្លៃអស់រលីងព្រមជាមួយនឹងអ្នកធ្វើការជាមួយពីរនាក់ដែលអ្នកទាំងពីរនេះនឹងរាយការណ៍ទៅអាជ្ញាធរថាមិនបានធ្វើទារុណកម្ម ឬមានការរួញរា«ប្រឆាំងនឹងបដិវត្តន៍» ។ ស្រដៀងគ្នានេះដែរ យើងមិនអាចនិយាយនូវអ្វីដែលយើងអាចនឹងធ្វើនៅដើងឯកទេ ប្រសិនបើមេកើយយើងហុចដែកក្រៅរទេះឲ្យមកវាយបំបែកលលាដ៍ក្បាលជនរងគ្រោះដែលកំពុងតែលុតជង្គង់ចាំនៅមាត់រណ្តៅនោះ ។ ប្រឈមមុខនឹងការគំរាមកំហែងនិងភាពមិនប្រាកដប្រជាជាច្រើន តើអ្នកធ្វើទារុណកម្មនិងអ្នកសម្លាប់មានការរួញរា ចេះតែរំលោភទៅ ឬធ្វើការជ្រើសរើសទៅតាមករណីមួយៗផ្សេងៗពីគ្នា? ការបដិសេធមិនព្រមធ្វើទារុណកម្មឬសម្លាប់អ្នកទោស មិនមាននិយាយនៅក្នុងបណ្ណសារឡើយ ។ នៅពេលបុគ្គលិកគុកចាប់ផ្តើមធ្វើទារុណកម្ម វាហាក់ដូចជាថា អ្នកសួរចម្លើយមានភាពឥតមេត្តាជ្រុលពេក ហើយត្រូវបានប្រមូលផ្តុំគ្នាផ្តល់អំណាចឲ្យ ឬភ័យខ្លាំងរហូតមិនអាចបញ្ឈប់ ឬឆ្ងល់នូវអ្វីដែលខ្លួនកំពុងតែធ្វើ ។ កំហិតមួយចំនួនកើតចេញមកពីអ្នកនៅពីលើខ្លួនមកពីជនរងគ្រោះ ឬពីអ្នកដទៃទៀតដែលនៅក្នុងក្រុមរបស់ខ្លួន ។ ភាពគួរឲ្យព្រឺព្រួចពិតៗដែលកើតឡើងនៅមន្ទីរស-២១ អាចជាអំពើហិង្សាក្រៅក្របខ័ណ្ឌ ដោយសារភាពធ្វើមិនអើពើរបស់អ្នកគ្រប់គ្រងគុកផ្ទាល់ និងភាពព្រងើយកន្តើយរបស់មជ្ឈិមបក្សចំពោះអ្វីដែលគេកំពុងតែធ្វើចំពោះមនុស្សផ្សេងទៀត ។ ក្នុងន័យម្យ៉ាងយើងអាចនិយាយបានថា អ្នកដែលត្រូវទទួលរងទារុណកម្មនៅទួលស្លែងអាចមានសំណាងដែលមិននៅរស់នេះប្រសិនបើយើងគិតពីផលប៉ះពាល់ក្រោយពីហេតុការណ៍និងភាពតក់ស្លុតដែលបណ្តាលមកពីទារុណកម្មដែលកើតឡើងចំពោះជនរងគ្រោះជាច្រើននិងដែលធ្វើឲ្យអ្នករស់រានមានជីវិតជាច្រើនពីជំរំណាហ្ស៊ីបន្ទុំចិត្តសម្លាប់ខ្លួនក្រោយពេលគេដោះលែងឲ្យមានសេរីភាពវិញ ។ ភាពក្រៀមក្រំចុងក្រោយ ហេតុការណ៍ប្រហាក់ប្រហែលគ្នានេះដែរកើតឡើងចំពោះអ្នកដែលត្រូវបានធ្វើឲ្យអាម៉ាស់មុខនិងវាយប្រហារនៅក្នុងបដិវត្តន៍វប្បធម៌ចិន ។ ជនដៃដល់នៅទីនោះកាន់តែឥតធម៌មេត្តាជាងនេះទៅទៀត ។

សូមលើកឧទាហរណ៍ជាក់ស្តែងចំនួនពីរដែលបានមកពីជនរងគ្រោះ ។ ហ្សង់ អាមេរី ជាបញ្ញវន្តជនជាតិជ្វីហ្វដ៏សំខាន់នៅអឺរ៉ុបក្រោយពេលសង្គ្រាម និងជាអ្នករស់រានមានជីវិតម្នាក់ពីជំរំមរណៈអ៊ូស្វ៊ីត ។ អ្នកទាំងពីរបានធ្វើអត្តឃាតនៅឆ្នាំ១៩៧៨ ។ មួយទសវត្សរ៍ក្រោយមក មិត្តភក្តិរបស់ អាមេរី នៅជំរំមរណៈអ៊ូស្វ៊ីត ឈ្មោះ ព្រីម៉ូ បានលោតទម្លាក់ខ្លួនពីលើបន្ទប់នៅតំបន់ទូរីន ។ នៅក្នុងសៀវភៅខ្លីមួយមានចំណងជើងថា «ដែនកំណត់នៃចិត្ត» អាមេរី អាចទាយទុកមុនអំពីមរណភាពរបស់លោកផ្ទាល់ និងរៀបរាប់អំពីអំពើទារុណកម្មដូចតទៅនេះ «អ្នកដែលត្រូវបានធ្វើទារុណកម្មហើយនៅតែទទួលរងទារុណកម្មទៀត...អ្នកដែលទទួលរងនូវអំពើទារុណកម្មហើយមិនអាចរស់នៅស្រួលក្នុងពិភពលោកយើងនេះបានទេ ។ អំពើកម្ទេចមនុស្សដ៏គួរឲ្យស្អប់ខ្ពើមនេះមិនមានអ្នកណាធ្វើឲ្យរលត់បានឡើយ ។ សេចក្តីទុកចិត្តទៅលើមនុស្សជាតិដែលមានភាពប្រេះស្រាំរួចទៅហើយដោយការទះចំមុខមួយដៃ និងដែលលុបបំបាត់ដោយទារុណកម្មនោះ គឺមិនអាចយកមកវិញបានឡើយ» ។ **(នៅមានត)**

## ពាក្យស្លោកខ្មែរក្រហម

◆ **ឈរលើគោលជំហរឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួនជាមូលដ្ឋាន ត្រូវខិតខំសាមគ្គីជាមួយបក្សម៉ាក្ស-លេនីន ជាមួយកម្លាំងបដិវត្ត កម្លាំងចម្រើន ស្នេហាឯករាជ្យ ស្នេហាយុត្តិធម៌ទាំងអស់លើសកលលោក ប្រឆាំងនឹងចក្រពត្តិនិយម ខាតទីនិយម លេបទឹកដីពូជសាសន៍និយម និងប្រតិកិរិយាទាំងអស់ ដើម្បីឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ សមភាព យុត្តិធម៌ និងសេចក្តីចំរុងចម្រើនសង្គមពិតប្រាកដ។**

*(ឯកសារ D១៣៧៩២)*

# គុកព្រៃស

គុកព្រៃសគឺជាមន្ទីរឃុំឃាំងដែលស្ថិតនៅសង្កាត់ព្រៃសខណ្ឌដង្កោ រាជធានីភ្នំពេញ ។ ខ្មែរក្រហមបានប្រើប្រាស់គុកព្រៃសជាជំរំលត់ដំអ្នកទោសដែលត្រូវបានចាត់ទុកថាមានប្រវត្តិរូបមិនស្អាតស្អំ ជាប់និន្នាការខ្មាំង និងបានធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍ ។ នៅក្នុងអំឡុងពេលដែលខ្មែរក្រហមកាន់អំណាច គុកព្រៃសមានឈ្មោះថា «មន្ទីរស-២១ឃ» ឬ «មន្ទីរ២៤» ។ មន្ទីរស-២១ឃ គឺជាសាខាមួយរបស់មន្ទីរស-២១ ។ មន្ទីរស-២១ឃ មានតួនាទីធ្វើស្រែដើម្បីផ្គត់ផ្គង់ដល់មន្ទីរ-២១និងសាខាទាំងអស់របស់មន្ទីរស-២១ ។

មន្ទីរស-២១ឃ ស្ថិតនៅក្រោមការមើលការខុសត្រូវយ៉ាងជិតដល់របស់ នុន ហ៊ុយ ហៅ ហ៊ុយស្រែ ។ យូ ប៉េងគ្រី ហៅ ម៉ុន ជាអនុប្រធានមន្ទីរស-២១ឃ ។ នៅក្នុងតួនាទីជាប្រធានមន្ទីរស-២១ឃ ហ៊ុយស្រែ បានបំពេញការងារសំខាន់ៗជាច្រើនជូនបក្ស ទាំងការងារបង្កបង្កើនផល នយោបាយបក្ស និងកម្ទេចខ្មាំងបដិវត្តន៍ ។

នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៦ ហ៊ុយស្រែ បានចូលរួមប្រជុំជាមួយលេខាកងពលភ័ស្តុភារកងពលនិងលេខាកងវរសេនាធំ ។ របៀបវារៈនៃអង្គប្រជុំបានលើកឡើងអំពីៈ សភាពការណ៍ខ្មាំង ការងារបង្កបង្កើនផល បញ្ហាទឹកជំនន់ បញ្ហាសុខភាព ស្បៀងអាហាររបស់កងពលនីមួយៗ និងសភាពការណ៍បក្សខាងសតិ-អារម្មណ៍ នយោបាយ ចាត់តាំង ។ ទាក់ទិននឹងសភាពការណ៍ខ្មាំង ហ៊ុយស្រែ បាននិយាយទៅកាន់ សុន សេន (បង៨៩) និងអង្គប្រជុំទាំងមូលថា «ក្នុងមួយខែកន្លងទៅ គ្មានអ្វីចោទសំខាន់ទេ គឺមានតែរត់ បំផុសទំនាស់ ទាមទារមិនធ្វើការ និងទាមទារស៊ីចុកគ្រប់គ្រាន់ ។ (បញ្ហាយុទ្ធជន) រត់មានជាបន្តបន្ទាប់ តែទប់ទល់បានជាបន្តដែរ» ។ ក្នុងពេលជាមួយគ្នានេះដែរ ហ៊ុយស្រែ បានលើកឡើងអំពីបញ្ហាសុខភាពរបស់យុទ្ធជនថា «មានអ្នកឈឺចំនួន៤០០នាក់ តែមិនទាន់មានពលីទេ» ។

ហ៊ុយស្រែ មិនមានតួនាទីពេញលេញក្នុងការសម្រេចលើជោគវាសនារបស់ខ្មាំងបដិវត្តន៍ទេ ។ ហ៊ុយស្រែ តែងតែស្នើសុំយោបល់និងការសម្រេចចិត្តពីថ្នាក់លើ ។ នៅក្នុងពេលដែល តាណាត អតីតលេខាកងពលលេខ១២ គ្រប់គ្រងការងារសន្តិបាលស-២១ ហ៊ុយស្រែ តែងតែផ្ញើរបាយការណ៍ស្តីអំពីសកម្មភាពខ្មាំងទៅ តាណាត ។ នៅថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៧៦ ហ៊ុយស្រែ បានផ្ញើរបាយការណ៍ជូនទៅ តាណាត (បង០៣) ដោយរាយការណ៍អំពីសកម្មភាពយុទ្ធជនបីនាក់នៅក្នុងកង១១និងកង១៣ របស់មន្ទីរស-២១ឃ ។ ហ៊ុយស្រែ បានសរសេរនៅក្នុងរបាយការណ៍ថា «យុទ្ធជនទាំងបីនាក់នេះមានលក្ខណៈសេរី ខ្ជិលមិនធ្វើការងារអ្វីទាំងអស់ ។ យុទ្ធជនពីរនាក់នៅក្នុងកងលេខ១៣ ត្រូវចាប់ចងឃុំទុកនៅក្នុងមន្ទីរ និងម្នាក់ទៀតត្រូវនាំយកមកទុកជាមួយក្រុមដោះលែង ។ ចំពោះបញ្ហាខាងលើនេះ ហ៊ុយស្រែបានស្នើសុំយោបល់«បង០៣ សម្រេចយ៉ាងណា?» ។

បន្ទាប់ពី តាណាត បានផ្ទេរពីគ្រប់គ្រងការងារសន្តិបាលទៅជាជំនួយការសេនាធិការកងទ័ព ហ៊ុយ ត្រូវផ្ញើរបាយការណ៍សកម្មភាពការងារមួយចំនួនទៅ ឌុច ប្រធានមន្ទីរស-២១ ។ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧៧ ហ៊ុយ បានធ្វើបញ្ជី«ឈ្មោះអ្នកដែលត្រូវដក»ចំនួន២១នាក់ ផ្ញើទៅមន្ទីរស-២១ ។ ក្នុងចំណោមអ្នកទោសទាំង២១នាក់ ភាគច្រើនជាគ្រូបង្រៀន ។ អួន ធុល អតីតអធិការបឋមសិក្សា ត្រូវបានបញ្ជូនមកដល់មន្ទីរស-២១ឃ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៧៧ ។ នៅថ្ងៃទី១៣ក្នុងខែដដែល កូនស្រីពីរនាក់ទៀតរបស់ អួន ធុល ត្រូវបានចាប់ខ្លួនបញ្ជូនទៅមន្ទីរស-២១ឃ ។ លី សំអាត អតីតគ្រូបង្រៀន និងជាអ្នកទោសម្នាក់ក្នុងចំណោមអ្នកទោសទាំង២១នាក់ ត្រូវបានចាប់ខ្លួនជាមួយប្រពន្ធនិងកូនស្រីម្នាក់របស់គាត់នៅថ្ងៃទី៣០ខែមីនា ឆ្នាំ១៩៧៧ ។ ក្រុមគ្រួសាររបស់ លី សំអាត និង អួន ធុល រួមទាំងអ្នកទោសដទៃទៀតទាំង២១នាក់ ត្រូវបានកម្ទេចក្នុងថ្ងៃតែមួយក្រោម

ស្នាដៃរបស់ ហ៊ុយ ស្រែ ។

ហ៊ុយ ស្រែ មានឈ្មោះដើម នុន ហ៊ុយ កើតនៅខែមីនា ឆ្នាំ ១៩៥១ នៅភូមិទន្លេបាទី ឃុំទន្លេបាទី ស្រុកបាទី ខេត្តតាកែវ ។ ហ៊ុយ ស្រែ បានចូលបម្រើបដិវត្តន៍នៅថ្ងៃទី៧ ខែមេសា ឆ្នាំ ១៩៧០ នៅក្នុងកងពលលេខ១២(ក្រោយមកជាកងពលលេខ ៧០៣) ។ នៅសម័យសង្គមរាស្ត្រនិយម ហ៊ុយ ស្រែ ជាកសិករ ស្ថិតក្នុងវណ្ណៈភាពកសិករកណ្តាលក្រោម ។ ហ៊ុយ ស្រែ មានប្រពន្ធ ឈ្មោះ ប្រុក សាមុត ហៅ ប្រុក ខឿន ដែលបានចូលបម្រើបដិវត្តន៍នៅខែមីនា ឆ្នាំ១៩៧២ តាមរយៈ សូ សុខា ជាប្រធាននារីឃុំត្នោត និង តាណាត លេខាកងពលលេខ១២ ។ ខឿន មានគោលបំណង“ចូលធ្វើបដិវត្តន៍ដើម្បីរំដោះវណ្ណៈក្រីក្រ” ។ នៅខែមីនា ឆ្នាំ១៩៧៧ បក្សបានចាត់តាំង ខឿន ឲ្យមកនៅមន្ទីរស-២១ ស្ថិតក្រោមការដឹកនាំរបស់ ឌុច, ហ៊ និង ហ៊ុយ តូច (ហ៊ឹម ហ៊ុយ) ។

ហ៊ុយ ស្រែ ត្រូវបានចាប់ខ្លួននៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ១៩៧៨ ។ អង្គការបានចោទប្រកាន់ថា ហ៊ុយ ស្រែ បានចូលរួមរៀបចំផែនការវាយប្រហារបក្សកុម្មុយនិស្តកម្ពុជា ។ មិនមានឯកសារដែលបញ្ជាក់ថា ហ៊ុយ ស្រែ ត្រូវបានកម្ទេចនៅថ្ងៃណាឡើយ ។ ហ៊ុយ ស្រែ បានបញ្ចប់ការសរសេរចម្លើយសារភាពចុងក្រោយរបស់ខ្លួននៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៧៨ ។

ម៉ុន ជាអតីតគ្រូបង្រៀនតាំងពីឆ្នាំ១៩៥៨រហូតដល់ឆ្នាំ ១៩៧០ ។ ម៉ុន ជាមនុស្សមានការរាប់អានជិតស្និទ្ធជាមួយ តាណាត លេខាកងពលលេខ១២ និង សុក ប៊ុតចំរើន គណៈតំបន់ ២៥ ។ នៅក្នុងឆ្នាំ១៩៧៥ ម៉ុន មានតួនាទីបញ្ជាការកងអនុសេនាធំកងពលលេខ១២ ។ នៅខែឧសភា ឆ្នាំ១៩៧៦ថ្នាក់លើបានដក ម៉ុន ឲ្យនៅស្រែជាមួយ ហ៊ុយ ស្រែ ទទួលតួនាទីជាអនុប្រធានមន្ទីរស-២១យ ។

ម៉ុន អាយុ៤០ឆ្នាំ ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ១៩៧៧ និងកម្ទេចនៅដើមឆ្នាំ១៩៧៨ ។ ម៉ុន បានបន្សល់ទុកនូវចម្លើយសារភាពចំនួន៩៦ទំព័រ ។ នៅចុងបញ្ចប់នៃចម្លើយសារភាព ម៉ុន បានអង្វរចំពោះអង្គការថា “អង្គការជាទីគោរព! សេចក្តីរាយការណ៍ដូចបានរាយជូនខាងលើ គឺខ្ញុំបានរាយជូនអង្គការដោយស្មោះត្រង់ជាទីបំផុតដោយឥតលាក់លៀមទេ ។ ហេតុនេះស្នើអង្គការអនុគ្រោះដល់ជីវិតខ្ញុំនិងគ្រួសារឲ្យបានរស់រានដើម្បីបានឃើញពន្លឺបដិវត្តន៍សង្គមនិយមតទៅទៀត ។ ទោះជាខ្ញុំត្រូវរស់នៅជាអ្នកទោស មានភារកិច្ចលីសែង ក៏ខ្ញុំសុខចិត្តដែរ ហើយរាងចាលឈប់ក្បត់បដិវត្តន៍រហូតមួយជីវិត ។ សូមគោរពជាទីបំផុត ។ ធ្វើនៅថ្ងៃទី២១ ខែមករា ឆ្នាំ១៩៧៨ ។ យូប៉េងគ្រី ហៅ ម៉ុន” ។ លិខិតសំណូមពរមួយសន្លឹកនេះបញ្ជាក់ថា ម៉ុន ដឹងយ៉ាងច្បាស់ថា បន្ទាប់ពីអង្គការសម្លាប់គាត់ ក្រុមគ្រួសាររបស់គាត់ក៏នឹងមានវាសនាដូចគាត់ដែរ ។ នេះដូចទស្សនៈរបស់ខ្មែរក្រហមដែលថា “ដឹកស្មៅត្រូវដឹកទាំងឫស” ។

អ្នកទោសនៅមន្ទីរស-២១យ មានសំណាងរួចផុតពីការសម្លាប់រង្គាលច្រើនជាងអ្នកទោសនៅមន្ទីរស-២១(ទួលស្លែង) ។ អ្នកទោសទាំងនោះជាប្រភេទខ្សាំងដែលអង្គការចាត់ទុកថាអាចកសាងខ្លួនបាន ។ រដ្ឋ នឹម អតីតយុទ្ធនារីនៅក្នុងកងពលលេខ ៧០៣ ត្រូវបានបញ្ជូនឲ្យទៅលត់ដំនៅមន្ទីរស-២១យដោយសារជាប់និន្នាការបងប្រុសម្នាក់ធ្វើជាទាហាន លន់ ណុល ។ រដ្ឋ នឹម បាននិយាយថា សារី ជាលេខាកងវរសេនាតូចនារី បានហៅឈ្មោះគាត់ព្រមទាំងយុទ្ធជននិងយុទ្ធនារីដទៃទៀតប្រមាណ៣០០ នាក់បញ្ជូនតាមរថយន្តឆ្ពោះទៅគុកព្រៃស (មន្ទីរស-២១យ) ។ សារី មិនបានប្រាប់គាត់អំពីមូលហេតុអ្វីឡើយ ។ កម្មាភិបាលនៅមន្ទីរស-២១យបានបង្ខំគាត់ឲ្យដាំដំណាំនិងធ្វើស្រែស្ទើរតែគ្មានពេលសម្រាក ។ នឹម បានលួចពិភាក្សាជាមួយ ផាត ជាយុទ្ធនារីដែលត្រូវបានជម្រុះមកជាមួយគ្នាថា “យើងសុទ្ធតែអ្នកជាប់ពាក់ព័ន្ធហើយបានជាអង្គការដកយកមកទីនេះ ។ កាលធ្វើជាកងទ័ពនៅក្នុងសង្គ្រាម យើងខំលត់ដំខ្លួនតស៊ូពិបាកស្ទើរស្លាប់ ដេកនៅតែក្នុងព្រៃ ដល់ពេលស្រណុក (ជ័យជំនះ) អង្គការមិនឲ្យយើងនៅក្នុងភ្នំពេញ ។ អ៊ីចឹងយើងជាអ្នកពាក់ព័ន្ធហើយ” ។

នៅចុងឆ្នាំ១៩៧៨ គណៈកងនារីបានប្រាប់ នឹម ឲ្យទៅថតរូបធ្វើប្រវត្តិរូប ។ ទាក់ទិនរូបថតនេះ នឹម បាននិយាយថា យ៉ុន គណៈកងវរសេនាតូចនារី បានហៅគាត់ឲ្យទៅថតរូបក្នុងខណៈពេលដែលគាត់កំពុងតែរែកទឹកសម្រាប់ដាំបាយ ។ គាត់គ្រាន់តែឮតាមគ្នាថា យ៉ុន ឲ្យថតរូបដើម្បីយកទៅធ្វើប្រវត្តិរូប ។ នឹម បន្តថា


232


មាស ប៉េងគ្រី


សោម នឹម


575





វ៉ែន ហ៊ាន



ទាង គិន



បន្ទាប់ពីថតរូបរួចហើយ ម្នាក់ៗត្រូវបំពេញលើក្រដាសប្រវត្តិរូបមួយសន្លឹករួចប្រគល់ឲ្យប្រធានក្រុមរបស់ខ្លួន ។

តាមចម្លើយសារភាព ម៉ុន អនុប្រធានមន្ទីរស-២១យ ក៏ធ្លាប់និយាយជាមួយ ស្រ៊ូ ប្រធានកងវរ១៣ នៅព្រៃសដែរថា "ស្រ៊ូ ឯងឃើញទេ កាលនៅសង្គ្រាមលំបាកស្លាប់រស់ ។ បដិវត្តន៍ត្រូវការយើងដឹកនាំអង្គភាពប្រយុទ្ធ ប៉ុន្តែដល់ចប់សង្គ្រាម បោះបង់យើងចោលឲ្យមកធ្វើស្រែលត់ដំនៅមន្ទីរ២១ ។ ចំណែកឯការងារសំខាន់ៗគឺវណ្ណៈមូលដ្ឋានកាន់កាប់ទាំងអស់ ទោះជាអ្នកមិនដែលស្គាល់សមរភូមិសោះក៏ដោយ ក៏ត្រូវកាន់ការងារសំខាន់ៗដែរ ។ គិតទៅ ស្រ៊ូឯងក្តី ខ្ញុំក្តី ធ្វើបដិវត្តន៍ចាំតែពេលស្លាប់តែប៉ុណ្ណោះ ព្រោះនៅមន្ទីរ២១គឺជាគុក គ្រាន់តែនៅក្រៅឃុំនិងក្នុងឃុំតែប៉ុណ្ណោះ" ។

ទុយ គិន អតីតយុទ្ធនារីនៅក្នុងកងពលលេខ៧០៣ បាននិយាយថា ក្រោយពេលរំដោះបានទីក្រុងភ្នំពេញ យ៉ុន ជាគណៈវរសេនាតូចនារី បានចុចឈ្មោះគាត់ឲ្យទៅធ្វើស្រែនិងដាំបន្លែនៅគុកព្រៃស ។ អង្គការបានដកគាត់ទៅគុកព្រៃសដោយសារគាត់មានឪពុកមាម្នាក់ជាទាហានសក្តិ៣បម្រើការនៅពោធិចិនតុង ។ ទុយ គិន និយាយថា យុទ្ធនារីដែលអង្គការជ្រើសរើសយកទៅលត់ដំនៅគុកព្រៃសជាមួយគាត់មានចំនួនជាង១០០នាក់ ។

វ៉ែន ហ៊ាង បានស្ម័គ្រចិត្តចូលធ្វើជាយុទ្ធនារីក្រហម នៅក្នុងកងពលលេខ៧០៣នៅខែមេសា ឆ្នាំ១៩៧៣ ។ ចាប់តាំងពីរំដោះបានទីក្រុងភ្នំពេញនៅថ្ងៃ១៧មេសា ១៩៧៥រហូតដល់ការដួលរលំនៃរបបខ្មែរក្រហម ហ៊ាង មិនដែលបានមកសួរសុខទុក្ខក្រុមគ្រួសារម្តងណាឡើយ ។ ក្រោយឆ្នាំ១៩៧៩ មានយុទ្ធជនមួយចំនួនបានវិលត្រឡប់មករស់នៅជួបជុំគ្រួសាររបស់ខ្លួនវិញ ។ រៀងរាល់ថ្ងៃជិតលិច លោកតា ឡាច ដាន់ ឪពុករបស់ ហ៊ាង តែងតែឈរនៅក្រោមដើមអំពិលនៅខាងមុខផ្ទះទន្ទឹងមើលផ្លូវកូនស្រីរបស់គាត់ ។

លោកយាយ វ៉ែន រុន ជាម្តាយរបស់ ហ៊ាង បាននិយាយថា "គាត់ទន្ទឹងមើលផ្លូវកូនស្រីរហូតដល់ដាច់បាយដាច់ទឹក" ។ មិនយូរប៉ុន្មាន លោកតា ដាន់ ក៏ធ្លាក់ខ្លួនឈឺ ។ នៅឆ្នាំ១៩៨៣ លោកតា ដាន់ បានទទួលមរណៈភាពដោយមិនបានជួបមុខកូនស្រីរបស់គាត់ឡើយ ។ នៅឆ្នាំ១៩៩២ ជាមួយគ្នានឹងការធ្វើមាតុភូមិនិវត្តន៍របស់ប្រជាជនខ្មែរនៅតាមដំរទល់ដែនកម្ពុជា-ថៃ វ៉ែន ហ៊ាង បានត្រឡប់មកស្រុកកំណើតរបស់ខ្លួនរួមជាមួយប្តីនិងកូនប្រុស២នាក់ ។ នៅក្នុងសម័យខ្មែរក្រហម មន្ទីរស-២១ បានធ្វើ"ប្រវត្តិរូបសង្ខេប"របស់ ហ៊ាង ចំនួនមួយសន្លឹកដែលមានបិទរូបថតពាក់កណ្តាលខ្លួន ។ ប្រវត្តិរូបរបស់ ហ៊ាង មានលក្ខណៈដូចគ្នានឹងប្រវត្តិរូបរបស់ រដ្ឋ នឹម និង ទុយ គិន ។



នៅឆ្នាំ១៩៧៧ មាស ប៉េងគ្រី អតីតយុទ្ធជននៅក្នុងកងពលលេខ៧០៣ បម្រើការផ្នែកបើកបររថយន្តនៅសេនាធិការកងទ័ព ត្រូវបានចាប់ខ្លួនបញ្ជូនមកមន្ទីរស-២១យ ។ ប៉េងគ្រី បាន




ប្រាប់អំពីមូលហេតុដែលនាំឲ្យមានការចាប់ខ្លួនគាត់ថា "ខ្ញុំបើកឡានក្រឡាប់"នៅម្តុំបែកចាន ។ ហ៊ឹម ហ៊ុយ អតីតអនុប្រធានកងការពារអ្នកទោសនៅមន្ទីរស-២១និយាយថា នៅឆ្នាំ១៩៧៨ គាត់ធ្លាប់ជួប ប៉េងគ្រី កំពុងបើកឡានដឹកបន្លែនៅព្រៃស ។ ក្នុងខណៈពេលនៅព្រៃស ប៉េងគ្រី ត្រូវធ្វើប្រវត្តិរូបដូចអ្នកទោសដទៃទៀតដែរ ។ នៅក្នុង"ប្រវត្តិរូបសង្ខេប"របស់ប៉េងគ្រី បានសរសេរថា "ថ្ងៃចូលអង្គភាពៈ ៥-៨-៧៧" ។ នៅត្រង់"ចំណុចពាក់ព័ន្ធ" ដែលនាំឲ្យ ប៉េងគ្រី ត្រូវចាប់បញ្ជូនមកមន្ទីរស-២១យ បានបញ្ជាក់ថា "បើកឡានក្រឡាប់" ។

បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម មន្ទីរស-២១(គុកទួលស្លែង) ត្រូវបានរៀបចំឡើងវិញជាសារមន្ទីរជាតិ ។ ចាប់តាំងពីពេលនោះមក គុកទួលស្លែងត្រូវបានប្តូរឈ្មោះទៅជា "សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង" ។ រូបថតជនរងគ្រោះនិងកម្មាភិបាលខ្មែរក្រហមជាច្រើននាក់ត្រូវបានដាក់តាំងនៅតាមជញ្ជាំងសារមន្ទីរ ។

រូបថតពាក់កណ្តាលខ្លួនសម្រាប់ធ្វើប្រវត្តិរូបរបស់ ទុយ គិន ដែលថតនៅព្រៃសកាលពីចុងឆ្នាំ១៩៧៨ ក៏ត្រូវបានដាក់តាំងនៅទីនោះដែរ ។ ដោយសារតែរូបថតដាក់តាំងមួយសន្លឹកនេះ បានធ្វើឲ្យ ទុយ គិន ជាប់ពន្ធនាគារអស់រយៈពេល១៨ខែ (នៅឆ្នាំ១៩៨៤) ក្រោមការចោទប្រកាន់ពីតុលាការខេត្តកណ្តាលពីបទដែលថាគាត់បានសម្លាប់មនុស្សរាប់រយនាក់នៅគុកទួលស្លែង ។ រូបថតមួយសន្លឹកនេះ ក៏បានធ្វើឲ្យ ទុយ គិន ចំណាយពេលវេលាជាងម្ភៃឆ្នាំរស់នៅក្នុងភាពមន្ទិលសង្ស័យពីសំណាក់ញាតិជិតខាងចំពោះអតីតភាពដែលជិតជាមមកពីរបបខ្មែរក្រហម ។ ទុយ គិន បានបដិសេធថា "ខ្ញុំមិនបានសម្លាប់មនុស្សទេ" ។

ប្រវត្តិរូបរបស់ ទុយ គិន, រដ្ឋ នឹម និង វ៉ែន ហ៊ាង ជាប្រភេទប្រវត្តិរូបដែលធ្វើឡើងដោយមន្ទីរស-២១ ក្នុងពេលតែមួយ និងមានលក្ខណៈដូចៗគ្នា ។ យុទ្ធនារីទាំងបីនាក់ខាងលើត្រូវបានបញ្ជូនទៅមន្ទីរស-២១យ នៅក្នុងថ្ងៃតែមួយដូចគ្នា "ចូលអង្គភាពៈ ២៣-១២-៧៥" ។ នៅខាងលើផ្នែកខាងឆ្វេងនៃប្រវត្តិរូបនីមួយៗមានបិទរូបថតពាក់កណ្តាលខ្លួន ។ រូបថតរបស់អតីតយុទ្ធនារីទាំងបីនាក់និងរូបថតរបស់ មាស ប៉េងគ្រី ត្រូវបានថតពង្រីកឡើងវិញ ហើយដាក់តាំងនៅលើជញ្ជាំងសារមន្ទីរទួលស្លែងរួមជាមួយរូបថតរបស់ជនរងគ្រោះនិងជនដៃដល់ជាច្រើននាក់ទៀត ។

**ហ៊ុយ វណ្ណៈ**

# តុលាការនៅទីម័រខាងកើត៖
# ក្រុមប្រឹក្សាអ្នកច្បាប់ពិសេសខាងព្រហ្មទណ្ឌកម្រិតធ្ងន់

**(តចប់)**

កម្ពុជាបានរងនូវការវាយប្រហារពីសំណាក់របាយការណ៍ជាច្រើន ស្តីពីកង្វះសេចក្តីសុចរិតនៃប្រព័ន្ធតុលាការរបស់ខ្លួន ។ ការព្រួយបារម្ភអំពីកង្វះសេចក្តីសុចរិតរបស់តុលាការ គឺជាហេតុ-ផលដ៏សំខាន់ដែលនាំឲ្យក្រុមអ្នកជំនាញការច្បាប់បដិសេធមិនទទួលយកនូវដំណើរការជម្រះក្តីដែលគ្រប់គ្រងដោយកម្ពុជា ហើយស្នើឲ្យបង្កើតតុលាការអន្តរជាតិពិសេស ។ មិនតែប៉ុណ្ណោះ នៅមានមាត្រា១ នៅក្នុងនីតិវិធីព្រហ្មទណ្ឌដែលប្រើសព្វថ្ងៃ ដែលយកការគ្រប់គ្រងផ្នែកនយោបាយទាំងស្រុង ដាក់ទៅលើដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលជាការបង្កគ្រោះថ្នាក់ដល់សេចក្តីសុចរិតនៃដំណើរការកាត់ទោសនេះ ។ មាត្រា៥៥នៃរដ្ឋធម្មញ្ញកម្ពុជា គឺជាសំណល់ដែលបន្សល់ទុកពីអតីតភាពសង្គមនិយមរបស់កម្ពុជា ហើយតម្រូវឲ្យព្រះរាជអាជ្ញាមិនត្រឹមតែត្រូវជម្រាបរដ្ឋមន្ត្រីក្រសួងយុត្តិធម៌អំពី«សំណុំរឿងដែលធ្ងន់ធ្ងរខុសពីធម្មតា» ប៉ុណ្ណោះទេ តែថែមទាំងតម្រូវឲ្យធ្វើតាមសេចក្តីបង្គាប់នៅក្នុងកិច្ចការនេះទៀតផង ។

បញ្ហាផ្សេងមួយទៀតប៉ុន្តែទាក់ទងគ្នាគឺថា ច្បាប់កម្ពុជាមិនបានទទួលស្គាល់ថា ការជ្រៀតជ្រែកនៅក្នុងដំណើរក្តីរកយុត្តិធម៌ជាបទល្មើសព្រហ្មទណ្ឌឡើយ ប៉ុន្តែចែងថា ការបំភិតបំភ័យសាក្សីត្រូវតែមានទោស ។ (មាត្រា៥៥នៃច្បាប់អ៊ុនតាក់និយាយតែអំពីការគាបសង្កត់លើសាក្សីប៉ុណ្ណោះ) ។ ការដាក់ឲ្យទទួលទោសចំពោះរាល់ការប៉ុនប៉ងដោយចេតនាក្នុងការរារាំងនាំទៅផ្លូវអាក្រក់ ឬជ្រៀតជ្រែកក្នុងដំណើរការរកយុត្តិធម៌ នឹងក្លាយទៅជាជំហានដ៏សំខាន់មួយឆ្ពោះទៅរកដំណោះស្រាយកែតម្រូវបញ្ហាដែលកើតឡើងជាប្រព័ន្ធ និងបង្កើតនូវសំឡេងមួយធ្វើឲ្យដំណើរការកាត់ក្តីប្រកបដោយភាពមិនលម្អៀងនិងយុត្តិធម៌ត្រឹមត្រូវ ។ ក៏ប៉ុន្តែភាពចាំបាច់ក្នុងការការពារឯករាជ្យភាពរបស់អ្នកដែលមានអាជីព គួរតែប្រើប្រាស់ដើម្បីទប់កុំឲ្យអ្នកធ្វើការខាងរដ្ឋបាលផ្តើមគំនិតក្នុងការដោះស្រាយបញ្ហាដែលកើតឡើងពីកិរិយាមិនត្រឹមត្រូវ ឬការគ្រប់គ្រងមិនត្រូវ ។ វប្បធម៌នៃការដាក់ឲ្យទទួលខុសត្រូវចំពោះមុខច្បាប់ ចាំបាច់ត្រូវតែបង្កើតឡើងចាប់តាំងពីដើមទី និងមានចំណាត់ការដោះស្រាយបញ្ហាឲ្យបានរហ័សដើម្បីទប់ទល់ជាមួយនឹងបញ្ហាដែលនឹងកើតឡើង ។

វាតម្រូវឲ្យមានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលឯករាជ្យនិងមិនលម្អៀង ពោលគឺជាស្ថាប័នដែលថែមទាំងមានសមត្ថភាពក្នុងការរៀបចំជ្រើសរើសបុគ្គលិកប្រកបដោយភាពចំហឥតលាក់លៀមនិងមានតម្លាភាព ។ ជាការសំខាន់បំផុតដែលទាំងបុគ្គលិកដែលត្រូវជ្រើសរើសពីក្នុងស្រុកនិងអន្តរជាតិជាបុគ្គលិកដែលមានសមត្ថភាពគ្រប់គ្រាន់ មានសុចរិតភាព ភាពគ្មានលម្អៀង និងឯករាជ្យភាព ។ សង្គមស៊ីវិលចាំបាច់ត្រូវប្រយ័ត្នប្រយែងយកចិត្តទុកដាក់ក្នុងការត្រួតពិនិត្យដំណើរការជ្រើសរើសបេក្ខជនទាំងនេះ ។ ជាការសំខាន់ដែរ ដែលបុគ្គលិកអន្តរជាតិមានគុណសម្បត្តិខ្ពស់ សុចរិត និងមានជំនាញត្រឹមត្រូវតាមតម្រូវការពិតប្រាកដ ។ បទពិសោធន៍ច្រើនឥតគណនាដែលបន្សល់ទុកនៅតុលាការព្រហ្មទណ្ឌ បង្កើតឡើងសម្រាប់ប្រទេសយូហ្គោស្លាវីនិងរ៉្វាន់ដា ចាំបាច់ត្រូវតែដកស្រង់មកជួយជ្រោមជ្រែងតុលាការកាត់ទោសខ្មែរក្រហម ប្រហែលជាតាមរយៈបុគ្គលិកដែលមានការគាំទ្រដល់តុលាការខ្មែរក្រហម និងការពង្រីកទំនាក់ទំនងជាមួយស្ថាប័នទាំងអស់នេះ ។ ដោយសារតែបុគ្គលិកទាំងនេះ នឹងមានចំនួនតិចជាងបុគ្គលិកក្នុងស្រុកនោះ តំណាងរបស់សហគមន៍អន្តរជាតិត្រូវស្តែងឲ្យឃើញជាក់ស្តែងពីសមត្ថភាពពិតក្នុងការបំពេញការងារនិងឯករាជ្យភាព ដើម្បីចៀសវាងកុំឲ្យស្ថិតនៅក្រោមការបំភិតបំភ័យ ។ ការធានាឲ្យបានដើម្បីឲ្យអ្នកដែលមានគុណសម្បត្តិខ្ពង់ខ្ពស់បែបនេះមកចូលរួមធ្វើការក៏ជាការសំខាន់ដែរ ដោយសារតែមានផ្នែកបន្ទាប់បន្សំសំខាន់មួយចំនួននៃការផ្លាស់ប្តូរ និងការកសាងសមត្ថភាពដែលនឹងចេញពីកិច្ច

សហការគ្នារវាងកម្ពុជានិងអន្តរជាតិ ដូចដែលបានស្នើឡើងរួចហើយនោះ ។

### ៥) នីតិវិធីព្រហ្មទណ្ឌ

អ្នកធ្វើសេចក្តីព្រាងច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមបានសម្រេចចិត្តបញ្ចូលច្បាប់កម្ពុជាដែលកំពុងតែត្រូវបានរិះគន់យ៉ាងខ្លាំង មកប្រើប្រាស់នៅក្នុងនីតិព្រហ្មទណ្ឌនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ។ ក៏ប៉ុន្តែច្បាប់នេះចែងថា ប្រសិនបើចាំបាច់ ហើយនីតិដែលមានជាធរមាននៅមានភាពខ្វះចន្លោះ សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។

នីតិវិធីដែលមានជាធរមាននឹងតម្រូវឲ្យមានការពិនិត្យទៅលើរដ្ឋធម្មនុញ្ញ ច្បាប់អ៊ុនតាក់ និងច្បាប់រដ្ឋកម្ពុជា ។ នៅក្នុងករណីជាច្រើនជាការចាំបាច់គឺត្រូវក្រឡេកមើលឲ្យបានឆ្ងាយពីកម្ពុជា ពីព្រោះដូចដែលតំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិមួយចំនួនប្រចាំនៅកម្ពុជា និងអង្គការក្រៅរដ្ឋាភិបាល បានលើកឡើងហើយថា មានបញ្ហាច្រើនណាស់ទាក់ទងនឹងនីតិវិធីព្រហ្មទណ្ឌបច្ចុប្បន្ននេះ ។ ឧទាហរណ៍ ច្បាប់រដ្ឋកម្ពុជានិងច្បាប់អ៊ុនតាក់មានវិធានផ្ទុយគ្នាទៅលើការចាប់ខ្លួនដោយគ្មានដីកា ។ គ្មានជនណាម្នាក់ត្រូវបានឃុំខ្លួនលើសពី៤៨ម៉ោងដោយមិនបានបញ្ជូនទៅចៅក្រមស៊ើបអង្កេតឡើយ ។ ប៉ុន្តែនគរបាលយុត្តិធម៌បកស្រាយខ្លឹមសារមាត្រានេះថា ការស៊ើបអង្កេតត្រូវធ្វើឲ្យហើយនៅក្នុងថិរវេលា៤៨ម៉ោង បើមិនដូច្នោះទេនឹងបញ្ចប់សំណុំរឿងត្រឹមនេះ ។ ច្បាប់កម្ពុជាមិនបានទទួលស្គាល់ឲ្យបានច្បាស់លាស់អំពីសិទ្ធិក្នុងការមិនដាក់ខ្លួនក្នុងការចោទប្រកាន់ខ្លួនឯង ហើយជារឿយៗជនជាប់ចោទត្រូវបានសម្លុតធ្វើបាប ឬថែមទាំងទទួលរងនូវទារុណកម្មឲ្យឆ្លើយដាក់ខ្លួនឯងថា មានកំហុសទៀតផង ។ ដោយសារប្រវត្តិសាស្ត្រមានការផ្តោតសំខាន់ទៅលើចម្លើយសារភាពដែលគិតជាបញ្ហាចម្បង ហើយជួនកាលគ្រាន់តែយកចម្លើយសារភាពជាមធ្យោបាយបញ្ជាក់ពីតឹកតាងតែប៉ុណ្ណោះ ។ ដូចដែលបានលើកឡើងខាងលើមកហើយថា គ្មានការធានាដល់ជនជាប់ចោទដែលឆ្លើយសារភាពកំហុស (ក្រៅពីបញ្ញត្តិមួយចំនួនដែលតែងតែមិនត្រូវបានអើពើ) ដែលថាចម្លើយសារភាពបានមកពីការបង្ខិតបង្ខំគ្រប់បែបយ៉ាងត្រូវទុកជាមោឃៈ ហើយចម្លើយសារភាពត្រូវតែធ្វើបមាណីករណ៍(អះអាងបន្ថែម) មុនពេលយកមកប្រើប្រាស់ជាភស្តុតាងសម្រាប់ទម្លាក់កំហុស ។ រដ្ឋធម្មនុញ្ញផ្តល់ឲ្យជនជាប់ចោទគ្រប់រូបនូវសិទ្ធិការពារក្តីខ្លួនឯង ប៉ុន្តែនីតិវិធីព្រហ្មទណ្ឌកម្ពុជាមិនទទួលស្គាល់ករណីនេះឡើយ គ្រាន់តែទទួលស្គាល់កត្តាសម្រាលទោសប៉ុណ្ណោះ ។

នីតិវិធីព្រហ្មទណ្ឌកម្ពុជាបច្ចុប្បន្នដាក់ឧបសគ្គយ៉ាងច្រើនទៅលើដំណើរការកាត់ក្តីដោយយុត្តិធម៌ចំពោះបទល្មើសសាមញ្ញ ចុះទម្រាំដល់បទឧក្រិដ្ឋអន្តរជាតិដែលមានលក្ខណៈស្មុគ្រស្មាញនោះវាពិបាកយ៉ាងណាទៅវិញ ។ វិធីមួយក្នុងការដោះស្រាយគឺត្រូវតែបង្កើនល្បឿននៃការព្រាងច្បាប់ និងអនុម័តច្បាប់ព្រហ្មទណ្ឌថ្មីដែលបាន និងកំពុងតែដំណើរការដោយមានការជ្រោមជ្រែងពីបារាំងអស់មួយរយៈកន្លងមកហើយនេះ ។ ជម្រើសមួយទៀតគឺត្រូវអនុម័តវិធានពិសេសស្តីអំពីនីតិវិធី និងវិធាននៃភស្តុតាងឲ្យស្របតាមផ្លូវត្រួសត្រាយនៅតុលាការព្រហ្មទណ្ឌអន្តរជាតិបង្កើតឡើងសម្រាប់ប្រទេសយូហ្គោស្លាវីនិងរ៉ាន់ដា (ដែលព្រាងនិងអនុម័តដោយចៅក្រម) ។

### ៦) នីតិវិធីត្រឹមត្រូវតាមច្បាប់ និងការជំនុំជម្រះក្តីដោយយុត្តិធម៌

លក្ខខណ្ឌធ្ងន់ធ្ងរដែលជាសម្ពាធដាក់មកលើការងារព្រហ្មទណ្ឌកម្រិតធ្ងន់ ជាចំណែកនាំឲ្យមានបញ្ហានៅក្នុងការមិនឆ្លើយតបទៅនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ។ បញ្ហាមួយចំនួនក្នុងបញ្ហាទាំងនេះត្រូវបានដោះស្រាយជាបណ្តើរៗហើយ ប៉ុន្តែក៏នៅមានសេសសល់មួយចំនួនទៀតដែរ ។ ការព្រួយបារម្ភអំពីការរំលោភ គឺផ្តោតសំខាន់ទៅលើផ្នែកដកហូតសេរីភាពនីតិវិធីត្រឹមត្រូវតាមច្បាប់ និងការជំនុំជម្រះក្តីដោយយុត្តិធម៌ ។ មានបញ្ហាធំៗជាច្រើនកើតចេញមកពីការឃុំខ្លួនមនុស្សខុសច្បាប់នៅក្នុងអំឡុងពេលចាប់ផ្តើមដំណើរការងារដំបូង ។ មានករណីមួយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាតុលាការព្រហ្មទណ្ឌពិសេសបានស្នើជាយោបល់ដែលមានលក្ខណៈអគតិ និងការវិនិច្ឆ័យទុកជាមុនទៅលើតួនាទីរបស់ប្រទេសឥណ្ឌូនេស៊ីនៅក្នុងអំពើឃោរឃៅនាខែកញ្ញា ឆ្នាំ១៩៩៩ ដោយសារគ្មានភស្តុតាង ឬបណ្តឹងវិវាទពី

ភាគីក្តី ។ សំណួរនៅតែមានថា តើចៅក្រមនិងរដ្ឋអាជ្ញាអន្តរជាតិដែលត្រូវបានតែងតាំងអាចយកជាសាច់ការបានដែរឬទេ ។ ការបកប្រែអន់និងមិនគ្រប់គ្រាន់នៅក្នុងដំណើរកាត់ក្តីពហុភាសា បានជះឥទ្ធិពលដល់ភាពត្រឹមត្រូវនៃសំណុំរឿង ការយល់ដឹងរបស់ជនជាប់ចោទនិងតុលាការ ព្រមទាំងធ្វើឲ្យដំណើរការកាត់ក្តីត្រូវពន្យារពេលថែមទៀតផង ។ យោងតាមមូលសាស្ត្រសំខាន់ៗរបស់អង្គការសហប្រជាជាតិស្តីអំពីតួនាទីរបស់មេធាវីឃើញថា ជនជាប់ចោទមានសិទ្ធិទទួលបាននូវការការពារក្តីពីមេធាវីដែលមានសមត្ថភាព ។ ដោយសារការចោទប្រកាន់ដំណើរការទៅទាំងលំបាកក្រោមកម្រិតដ៏ធ្ងន់ធ្ងរក្នុងការកសាងសំណុំរឿងនោះការដែលថាមកទល់នឹងពេលនេះ គ្មានសាលក្រមសម្រេចឲ្យរួចខ្លួនសម្រាប់ជនជាប់ចោទពីបទព្រហ្មទណ្ឌកម្រិតធ្ងន់នៅទីម័រខាងកើតអាចត្រូវបានចាត់ទុកថា ជាការសម្តែងឲ្យឃើញនូវការបណ្តុះបណ្តាលការណែនាំ និងការជួយជ្រោមជ្រែងមិនបានគ្រប់គ្រាន់ចំពោះអ្នកការពារក្តីដែលគ្មានបទពិសោធន៍នៅទីម័រខាងកើត ។

បញ្ហាលើនីតិវិធីត្រឹមត្រូវតាមច្បាប់ និងការជំនុំជម្រះក្តីដោយយុត្តិធម៌ដែលកើតចេញពីការពឹងផ្អែកទៅលើនីតិវិធីព្រហ្មទណ្ឌកម្ពុជាបច្ចុប្បន្ន និងកើតចេញពីតួនាទីគាបសង្កត់ពីតុលាការ ត្រូវបានលើកមកពិភាក្សារួចមកហើយ ។

បញ្ហាសិទ្ធិមនុស្សសំខាន់មួយគឺការបន្តឃុំខ្លួន ឌុច និង តាម៉ុក ។ តាម៉ុក និង ឌុច ត្រូវបានឃុំខ្លួនហួសពីច្បាប់អ៊ុនតាក់ដែលកំណត់ឃុំខ្លួនត្រឹម៦ខែ ប្រសិនបើមានការចាំបាច់ក្នុងការស៊ើបអង្កេត ។ ច្បាប់ស្តីអំពីរយៈពេលនៃការឃុំខ្លួនមុនពេលជម្រះក្តីដែលត្រូវបានអនុម័តដោយរដ្ឋសភាកាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៩៩ ដើម្បីដោះស្រាយសភាពការណ៍នេះ ដោយបន្ថយរយៈពេលឃុំខ្លួនយូរបំផុតត្រឹម៣ឆ្នាំ ក្នុងករណីបទអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ អត្ថិភាពនៃច្បាប់នេះ មិនបានការពារដល់ការរំលោភលើសិទ្ធិ ទទួលបាននូវការជម្រះក្តីដោយរួសរាន់ និងការឃុំខ្លួនលើសកំណត់មុនពេលកាត់ក្តីឡើយ ។ ដូចគ្នានេះដែរ អត្ថិភាពនៃចម្លើយសារភាពមិនមានន័យថា ការឃុំខ្លួនមុនពេលជម្រះក្តីអាចបន្តទៅដោយគ្មានភាពប្រាកដប្រជារហូតដល់តុលាការចេញជារូបរាងឡើយ ។ អាជ្ញាធរនឹងត្រូវតែពិចារណាយ៉ាងប្រុងប្រយ័ត្នទៅលើកាតព្វកិច្ចក្រោមច្បាប់ក្នុងស្រុកនិងច្បាប់អន្តរជាតិក្នុងការកាត់សេចក្តីឧក្រិដ្ឋកម្មអន្តរជាតិឲ្យបានរួសរាន់ និងគោរពគោលការណ៍សិទ្ធិមនុស្សចម្បងៗនៅក្នុងដំណើរកាត់សេចក្តី ។ មេរៀនបានមកពីទឹកដីទីម័រខាងកើតគឺថា ជម្រើសអាចមានពីរពេលគឺត្រូវដោះលែងជនជាប់ចោទដោយសារការឃុំខ្លួនហួសពេលកំណត់ ឬចាប់ផ្តើមដំណើរការរឿងក្តីដោយមានបទចោទប្រកាន់ក្រោមច្បាប់ក្នុងស្រុកដូចជាក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលនឹងធ្វើការឲ្យការស៊ើបអង្កេតនិងដំណើរការរឿងក្តីទៅមុខបានយ៉ាងឆាប់រហ័ស ។

ការជំនុំជម្រះក្តីដោយយុត្តិធម៌នៅក្នុងតុលាការខ្មែរក្រហមតម្រូវឲ្យមានក្រុមប្រឹក្សាការពារកូនក្តីដែលមានសមត្ថភាពនិងមានបទពិសោធន៍គ្រប់គ្រាន់ ដែលមានលទ្ធភាព មានឆន្ទៈនិងដែលទទួលបាននូវមធ្យោបាយនានាក្នុងការការពារបុគ្គលដែលប្រឈមមុខនឹងទោសបញ្ញត្តិកម្រិតធ្ងន់ធ្ងរចំពោះការប្រព្រឹត្តរបស់ខ្លួនតាមការចោទប្រកាន់ដែលជាបទឧក្រិដ្ឋយង់ឃ្នងបំផុតទទួលស្គាល់ដោយសហគមន៍អន្តរជាតិ ។ ត្រូវចែងបទបញ្ញត្តិសម្រាប់ជនជាប់ចោទជាអ្នកខ្សត់ខ្សោយដែលមិនអាចរកថវិកាសម្រាប់ការពារក្តីខ្លួនឯង ដើម្បីឲ្យខ្លួនមានសមត្ថកិច្ចក្នុងការបង្ហាញជូននូវសំណុំឯកសារឬលិខិតនីតិវិធី ។ ដោយសារតែមានការខ្វះខាតមួយផ្នែកនៃសមាជិកសមាគមវិជ្ជាជីវៈមេធាវី ជនជាប់ចោទជាច្រើនចូលខ្លួននៅក្នុងតុលាការកម្ពុជាដោយគ្មានបង្ហាញជូនសំណុំឯកសារឬលិខិតនីតិវិធីឡើយ ។ មេធាវីក្នុងស្រុកដែលមានជំនាញច្បាស់លាស់ក្នុងការការពារជនជាប់ចោទពីបទឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរប្រសិនបើមានក៏មានតិចដែរ ។ ច្បាប់អ៊ុនតាក់អនុញ្ញាតឲ្យមេធាវីបរទេសអាចជជែកការពារចំពោះតុលាការកម្ពុជាក្នុងកាលៈទេសៈណាដែលមេធាវីបរទេសនោះអាចបង្ហាញភស្តុតាងថាខ្លួនបានចុះឈ្មោះក្នុងអង្គការមេធាវីមួយឬក៏បានសេចក្តីអនុញ្ញាតជាផ្លូវការឲ្យជជែកការពារនៅក្នុងប្រទេសរបស់ខ្លួន ។ ក៏ប៉ុន្តែច្បាប់ស្តីពីលក្ខន្តិកៈមេធាវីចែងថា ជនដែលអាចចូលប្រកបវិជ្ជាជីវៈមេធាវីបាន ត្រូវតែមានសញ្ជាតិជាខ្មែរ ។ មេធាវីបរទេសដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីប្រទេសក្រៅ ឬដែល

ប្រទេសដើមរបស់ខ្លួនទទួលស្គាល់ឲ្យប្រកបវិជ្ជាជីវៈមេធាវី មានសិទ្ធិចូលរួមប្រកបវិជ្ជាជីវៈជាមួយមេធាវីខ្មែរនៅចំពោះមុខតុលាការ ឬស្ថាប័នដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ។ មេធាវីទាំងនោះពុំអាចតំណាងឲ្យកូនក្តីបានឡើយ ។

មិនតែប៉ុណ្ណោះ លក្ខខណ្ឌនេះរារាំងដល់មេធាវីបរទេសមិនឲ្យធ្វើការរួមគ្នាជាសហមេធាវីជាមួយមេធាវីខ្មែរ ហើយថែមទាំងហាមឃាត់មេធាវីបរទេសមិនឲ្យធ្វើជាតំណាងសំខាន់របស់កូនក្តីរបស់ខ្លួនទៀត ។ វិធានច្បាប់ទាំងនេះគួរតែបើកឲ្យមានលក្ខណៈសេរី ហើយសមាគមវិជ្ជាជីវៈមេធាវីកម្ពុជាគួរតែបើកចំហឲ្យទីប្រឹក្សាច្បាប់អន្តរជាតិ និងមេធាវីខ្មែរក្មេងៗដែលគួរតែអនុញ្ញាតឲ្យការពារជនជាប់ចោទនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។

**៧) ការកាត់សេចក្តីជាយុទ្ធសាស្ត្រៈ ផ្តោតសំខាន់ទៅលើមេដឹកនាំនិងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត**

ក្រុមការងារព្រហ្មទណ្ឌកម្រិតធ្ងន់នៅទីម័រខាងកើត បានជួបប្រទះនូវបញ្ហាជាក់ស្តែងមួយចំនួនទាក់ទងទៅនឹងជនដែលបង្កឲ្យមានការសម្លាប់រង្គាលនៅទីម័រខាងកើត ។ ដោយសារធនធានខ្វះខាតខ្លាំង និងដោយសារការបដិសេធរបស់ប្រទេសឥណ្ឌូនេស៊ីក្នុងការប្រគល់ខ្លួនជនជាប់ចោទដែលជាជនជាតិឥណ្ឌូនេស៊ី ក្រុមការងារព្រហ្មទណ្ឌកម្រិតធ្ងន់ពីមួយថ្ងៃទៅមួយថ្ងៃកាត់ទោសតែកងជីវពលតូចតាចជាជនជាតិទីម័រខាងកើតប៉ុណ្ណោះ ។ ច្បាប់លេខ ២០០០/១៥ មិនមែនដៅទៅលើមេដឹកនាំឬអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតនោះទេ ហើយក៏មិនមែនដាក់ឧក្រិដ្ឋកម្មកម្រិតធ្ងន់ទាំងអស់នៅក្នុងសមត្ថកិច្ចរបស់ស្ថាប័ននានានៃក្រុមការងារព្រហ្មទណ្ឌកម្រិតធ្ងន់ដែរ ។ នេះមានន័យស្មើនឹង“ការបើកទ្វារបង្ហៀរទឹក” ។ ដូច្នេះធនធានរបស់អង្គភាពព្រហ្មទណ្ឌកម្រិតធ្ងន់ ដែលមានការខ្វះខាតនេះ ត្រូវបានប្រើប្រាស់សម្រាប់កាត់ទោសកងជីវពលថ្នាក់ទាបដែលជាប់ឃុំរួចជាស្រេច និងដែលត្រូវបានបន្តចាប់ខ្លួន និងឃុំខ្លួនជាបន្តបន្ទាប់ ។ យុទ្ធសាស្ត្រស៊ើបអង្កេត ឬកាត់សេចក្តី ដែលធ្វើឲ្យធនធានកាន់តែតិចទៅៗ ដោយសារតែផ្តោតទៅលើ“ក្រុមតូចតាច” ជាជាងកសាងសំណុំរឿងក្តីប្រឆាំងនឹងមេដឹកនាំដែលមានការទទួលខុសត្រូវនោះ ធ្វើឲ្យមានបញ្ហាចម្រូងចម្រាស់យ៉ាងខ្លាំង ។

ដោយសារច្បាប់កាត់ទោសខ្មែរក្រហមផ្តោតសំខាន់ទៅលើមេដឹកនាំ និងជនទាំងឡាយដែលទទួលការខុសត្រូវខ្ពស់បំផុតនោះមានន័យថា យុទ្ធសាស្ត្រមានហើយស្រេចសម្រាប់ដៅក្រុមដែលជាមុខសញ្ញាកាត់ទោស ។ មេដឹកនាំខ្មែរក្រហមភាគច្រើនដែលនៅរស់ ឥឡូវនេះទទួលបាននូវឋានៈពលរដ្ឋខ្ពស់ ហើយបើចេះតែបណ្តោយទៅមុខទៀតនឹងគ្មានការជម្រះក្តីច្រើនប៉ុន្មានទេ ។ ប្រសិនបើគម្រោងនេះ ចង់ផ្តល់នូវចម្លើយដល់ការស្វែងរកការពិតឋិតថេរមួយ រាល់ការស៊ើបអង្កេតទាំងឡាយចាំបាច់ត្រូវតែធ្វើតាមយុទ្ធសាស្ត្រដែលពុះពារពិនិត្យទៅលើបទឧក្រិដ្ឋកម្មទាំងអស់ដែលប្រព្រឹត្តដោយខ្មែរក្រហម ស្វែងយល់អំពីទិសដៅ និងគោលដៅនៃចលនាការងារនេះ និងរកឲ្យឃើញច្បាស់នូវការផ្តោតសំខាន់ដែលត្រូវយកចិត្តទុកដាក់ទៅលើតួនាទី និងសារប្រយោជន៍របស់អ្នកដែលត្រូវកាត់ទោស ។ តែងតែមានគ្រោះថ្នាក់នៅក្នុងការជម្រះក្តីដែលក្នុងនោះមានមនុស្សម្នាក់ឬពីរនាក់នឹងត្រូវទទួលទោស និងត្រូវទទួលបន្ទុកជំនួសមនុស្សជាច្រើន ចំណែកឯអ្នកដែលមានការទទួលខុសត្រូវស្មើគ្នា ឬទទួលខុសត្រូវច្រើនជាងផង ត្រូវរួចខ្លួនពីការទទួលខុសត្រូវដោយសារហេតុផលនយោបាយ ។ ក្រុមអ្នកជំនាញការក៏បាននិយាយបង្ការក្រែងលោផ្តោតលើរឿងសំខាន់តែសំបកក្រៅ នាំឲ្យឃ្លាតចាកពីសារជាតិដើមនៃអំពើឃោរឃៅរបស់ខ្មែរក្រហមដែលប្រព្រឹត្តមកលើពលរដ្ឋខ្លួនឯង ដូចជាការជំនុំជម្រះក្តីទៅលើឧក្រិដ្ឋកម្មសង្គ្រាមដែលតម្រូវឲ្យមានការពិនិត្យអំពីការពាក់ព័ន្ធប្រដាប់អាវុធជាមួយប្រទេសជិតខាង ក៏ដូចជាតួនាទីរបស់រដ្ឋផ្សេងៗទៀតនៅក្នុងជម្លោះក្នុងអំឡុងឆ្នាំ១៩៧៥ - ១៩៧៩ ។

ដោយសារការចាប់ផ្តើមដំណើរតុលាការចេះតែខកខានម្តងជាពីរដង ធ្វើឲ្យជនសង្ស័យដែលមានវ័យចំណាស់ស្រាប់ទៅហើយកាន់តែចាស់ទៅៗថែមទៀត ។ ដូចនេះឃើញថាមានការប្រថុយគ្រោះថ្នាក់ណាស់ថា មេដឹកនាំខ្មែរក្រហមមួយចំនួននឹងមិនអាចរស់នៅរហូតដល់មានការជម្រះក្តីទេ ដោយបដិសេធនូវឱកាសជម្រះក្តីចំហ ដែលមានការវែកញែកភស្តុតាងតាមផ្លូវគតិយុត្តិ ។ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិដែលបង្កើតឡើងសម្រាប់

ប្រទេសយូហ្គោស្លាវី ជនជាប់ចោទឈ្មោះ ស្លាវកូ ដុកម៉ាណូវិក បានធ្វើអត្តឃាត៣ថ្ងៃមុនពេលការចេញសាលក្រមពីអង្គជំនុំជម្រះដែលធ្វើឡើងអស់រយៈពេលប៉ុន្មានខែមកហើយ ។ ស្ថានការណ៍បែបនេះមិនអាចនាំដល់ការចេញផ្សាយនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទៅលើការចោទប្រកាន់មកលើដុកម៉ាណូវិក ឡើយ ។ ចៅក្រមក៏មិនបានយល់ព្រមចេញសេចក្តីសម្រេចទៅលើអង្គហេតុស្តីអំពីពត៌មាន ពន្យល់ពីហេតុការណ៍នៃការបំប៉ែកអតីតសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវី និងការវាយយកយ៉ាងកម្រោលនូវទីក្រុងដ៏ានូបៀននៃរដ្ឋវូកូវ៉ា ដោយមានការសម្លាប់មនុស្សឈឺនិងរបួសចំនួន២០០នាក់ដែលយកមកពីមន្ទីរពេទ្យនៅតំបន់នោះ ។ ការសម្រេចមិនចេញសាលក្រមនេះគឺប្រហែលជាការត្រឹមត្រូវ ។ ក៏ប៉ុន្តែយោងតាមគោលបំណងនិងគោលដៅរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដែលបង្កើតឡើងសម្រាប់ប្រទេសយូហ្គោស្លាវី អាចទាញទស្សនៈករណ៍បានថា គោលបំណងដ៏ធំក្នុងការនាំមកនូវការបង្រួបបង្រួមផ្សះផ្សាតាមរយៈការផ្តល់យុត្តិធម៌ដល់ប្រជាជននៅតំបន់បាល់កង់ និងបំពេញចិត្តគ្រួសារជនរងគ្រោះនិងអ្នកដែលរស់រានមានជីវិតនៅទីក្រុងវូកូវ៉ា អាចធ្វើទៅបានតាមរយៈការចេញសេចក្តីសម្រេចទៅលើអង្គហេតុដែលគ្មានការទាក់ទងជាលក្ខណៈបុគ្គលដល់ ស្លាវកូ ដុកម៉ាណូវិក សោះឡើយ ។

ច្បាប់កម្ពុជាអនុញ្ញាតឲ្យមាន“សេចក្តីវិនិច្ឆ័យសង្ខេប” ពេលដែលបុគ្គលម្នាក់មានចេតនាគេចវេះមិនព្រមចូលខ្លួនឲ្យតុលាការវិនិច្ឆ័យទោសតាមច្បាប់ ។ ដូចជានៅប្រទេសដទៃជាច្រើនទៀតដែរ ប្រទេសកម្ពុជាគ្មាននីតិវិធីបង្ហាញអង្គហេតុដែលគ្មានការទាក់ទងនឹងភាពមានទោស ឬគ្មានទោសដែលនឹងត្រូវវិនិច្ឆ័យក្នុងករណីជនជាប់ចោទស្លាប់ក្រោយពីដំណើរជម្រះក្តីមិនទាន់ចប់សព្វគ្រប់ ប៉ុន្តែមុនពេលចេញសាលក្រម ។ នេះអាចជារឿងដែលត្រូវពិចារណាថែមទៀតដោយផ្អែកលើស្ថានការណ៍ដែលហៀបនឹងកើតឡើង ។

## ៨) ការផ្សព្វផ្សាយដល់សាធារណជន

នៅទីម័រខាងកើត គោលបំណងដ៏ធំក្នុងការឈានដល់ការបង្រួបបង្រួមផ្សះផ្សាតាមរយៈយន្តការតុលាការ មិនត្រូវបានយកចិត្តទុកដាក់ឲ្យបានមាំទាំទេ ។ ករណីបទល្មើសព្រហ្មទណ្ឌកម្រិតធ្ងន់ដើមដំបូងឡើយ គឺស្ថិតនៅក្នុងសមត្ថកិច្ចរបស់រដ្ឋអាជ្ញា



គណៈប្រតិភូទីម័រខាងកើតមកទស្សនកិច្ចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

(ទីតាំងរូបថតៈ ទីស្តីការគណៈរដ្ឋមន្ត្រីបច្ចុប្បន្ន)

និងចៅក្រមជនជាតិទីម័រខាងកើត ប៉ុន្តែនៅពេលមានក្រុមការងារព្រហ្មទណ្ឌកម្រិតធ្ងន់មកដល់ កិច្ចការទាំងនេះត្រូវដកយកចេញមកវិញ ដែលជាការនាំឲ្យមានការមិនសប្បាយចិត្តយ៉ាងខ្លាំង ។ ចាប់តាំងពីពេលនោះមក មូលហេតុចូលរួមរបស់ជនជាតិទីម័រខាងកើតនៅក្នុងដំណើរការជម្រះក្តី ពោលគឺការចូលខ្លួនមកស្រាយបំភ្លឺរបស់សាក្សីជនរងគ្រោះនិងជនជាប់ចោទ មានចំនួនតិចបំផុត ។ រដ្ឋអាជ្ញាជនជាតិទីម័រមួយរូបត្រូវបានចាត់តាំងឲ្យធ្វើអយ្យការ ប៉ុន្តែគ្រាន់តែមានតួនាទីជាបន្ទាប់បន្សំប៉ុណ្ណោះ ព្រមទាំងបានចំណាយពេលយ៉ាងច្រើនទៅទទួលការបណ្តុះបណ្តាលនៅប្រទេសព័រទុយហ្កាល់ ។ ចៅក្រមជនជាតិទីម័រដែលធ្វើការនៅក្នុងក្រុមប្រឹក្សាតុលាការព្រហ្មទណ្ឌពិសេស ស្ថិតក្នុងចំនួនភាគតិច១ទល់នឹង២ ។ ចាប់ផ្តើមដំបូង មានការខកខានមិនបានផ្សព្វផ្សាយសកម្មភាពទាំងនេះដល់ជនជាតិទីម័រខាងកើត និងមិនបានពន្យល់អំពីយន្តការយុត្តិធម៌ព្រមទាំងការងារដែលកំពុងដំណើរការលើផ្នែកព្រហ្មទណ្ឌកម្រិតធ្ងន់នេះ ។ ទាក់ទងនឹងចំណុចនេះដែរ គឺការចោទប្រកាន់អំពីបញ្ហាខាងវប្បធម៌ និងភាពក្រអឺតក្រអោងរបស់បុគ្គលិកបរទេសដែលធ្វើការនៅក្នុងរដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅទីម័រខាងកើត ដែលឮនិយាយថា អំពើនេះបានធ្វើឲ្យជនជាតិទីម័រខាងកើតកាន់តែឃ្លាតឆ្ងាយពីដំណើរការការងារនេះកាន់តែខ្លាំងថែមទៀត ។ រាល់បញ្ហាទាំងអស់នេះបាននាំឲ្យមានការគិតក្នុងលក្ខណៈអវិជ្ជមានមកលើការងារព្រហ្មទណ្ឌកម្រិតធ្ងន់ និងទៅលើកង្វះខាតការយល់ដឹងទៅលើទំហំការងារជាក់ស្តែងដែលសម្រេចបានក្នុងពេលមានបញ្ហាប្រទាំងប្រទើសទាំងនេះ ។

ជាការសំខាន់ណាស់ដែលសាធារណជនកម្ពុជាយល់ថា កិច្ចការនេះជាកិច្ចការរបស់ខ្លួនផ្ទាល់ និងការចូលរួមក្នុងដំណើរការជម្រះក្តីក៏ជាកិច្ចការរបស់ខ្លួនដែរ ។ ហេតុផលមួយដែលនាំឲ្យមានសុទិដ្ឋិនិយមទៅលើតុលាការក្នុងស្រុកបំប្លែងពីតុលាការអន្តរជាតិ គឺតួនាទីដែលតុលាការនេះផ្តល់ចំពោះចៅក្រម រដ្ឋអាជ្ញា និងមេធាវីការពារកូនក្តីនៅតាមមូលដ្ឋាន ។ ការផ្តល់អំណាចដល់ជនជាតិដើមដែលមានទទួលផលប៉ះពាល់បែបនេះក្នុងការសម្រេចបាននូវការជម្រះបញ្ជីត្រឹមត្រូវ គឺជាវិធីដ៏មានប្រសិទ្ធភាពក្នុងការផ្សព្វផ្សាយដល់មហាជន (ក្នុងកាលៈទេសៈសមស្រប) ។ នៅក្នុងសង្គមដែលទើបតែងើបផុតពីជម្លោះ ដែលសេចក្តីសម្រេចត្រូវបានធ្វើឡើងដើម្បីស្វែងរកការដាក់ឲ្យទទួលខុសត្រូវបទព្រហ្មទណ្ឌជាបុគ្គល ជាការសំខាន់គឺថា សាធារណជនត្រូវយល់ដឹងអំពីសេចក្តីសម្រេចនេះ និងវិធានការនានាដែលកំពុងអនុវត្ត ។ ប្រសិនបើការជំនុំជម្រះក្តីនឹងត្រូវធ្វើឡើង ដើម្បីជាមធ្យោបាយក្នុងការឈានដល់ការបង្រួបបង្រួមផ្សះផ្សាជាតិតាមរយៈយុត្តិធម៌នោះ ពលរដ្ឋទូទៅចាំបាច់ត្រូវតែទទួលព័ត៌មានអំពីដំណើរការជំនុំជម្រះក្តីនេះ ។ កិច្ចការនេះតម្រូវឲ្យមានការត្រួតពិនិត្យយ៉ាងជិតដល់ទៅលើការជម្រះក្តីនិងការផ្សព្វផ្សាយព័ត៌មានតាមរយៈប្រព័ន្ធឃោសនាដែលមិនលម្អៀង និងមានគោលដៅបម្រើផលប្រយោជន៍រួម និងតាមរយៈការអប់រំជាសាធារណៈស្តីអំពីសារសំខាន់របស់នីតិរដ្ឋ នីតិវិធីត្រឹមត្រូវតាមច្បាប់ និងការជម្រះក្តីដោយយុត្តិធម៌ ។ ការជម្រះក្តីក៏នឹងផ្តល់ឱកាសឲ្យមានការពិភាក្សាយ៉ាងទូលំទូលាយជាសាធារណៈ អំពីអំឡុងពេលប៉ុន្មានឆ្នាំនៃការកាន់អំណាចរបស់ខ្មែរក្រហម និងពេលមុននិងក្រោយរបបនេះចាប់ផ្តើមនិងបញ្ចប់ទៅ ។ ការមកជួបជុំពិភាក្សាគ្នាក្នុងលក្ខណៈសម្របសម្រួលការលំបាករបៀបនេះ អាចជួយឲ្យផ្សះរបួសមួយកម្រិតដែលចេះតែបន្តធ្វើឲ្យមានការឈឺចាប់នៅក្នុងសង្គមកម្ពុជាសព្វថ្ងៃ ។

ទាំងអស់នេះគឺជាបទពិសោធន៍មួយចំនួននៃការងារនៅទីម័រខាងកើត ដែលកម្ពុជាអាចទាញយកមកអនុវត្តតាមការជាក់ស្តែង ។ ច្បាប់កាត់ទោសខ្មែរក្រហមអាចអនុម័តបាន ប៉ុន្តែយុត្តិធម៌ស្ថិតនៅឆ្ងាយសែនឆ្ងាយ ។ មេរៀនទូទៅនេះគឺចង់និយាយថា ឆន្ទៈនយោបាយ គឺជាអ្វីដែលជាការចាំបាច់ខ្ពស់បំផុតដើម្បីធ្វើឲ្យតុលាការក្នុងស្រុកបំប្លែងជាតុលាការអន្តរជាតិដំណើរការបានផ្លែផ្កា ។ ប៉ុន្មានខែក្រោយពីបុគ្គលិកខិតខំធ្វើការទាំងលំបាកដើម្បីនាំមកនូវយុត្តិធម៌សម្រាប់ទីម័រខាងកើត ស្រាប់តែមានប្រភពធនធានព្រមទាំងការគាំទ្រគ្រាប់គ្រាន់ទៅលើគម្រោងការព្រហ្មទណ្ឌកម្រិតធ្ងន់ ។ នេះគឺជាឱកាសដ៏ល្អក្នុងការបំពេញតាមពាក្យសន្យា ។ ជាការច្បាស់ណាស់ថា ប្រសិនបើអ្នកដែលមានសមត្ថកិច្ចធ្វើកិច្ចការនេះពិតជាចង់ឲ្យស្ថាប័ននេះទទួលបានជោគជ័យមែននោះ ត្រូវតែផ្តល់ឲ្យស្ថាប័ននេះនូវគ្រប់មធ្យោបាយនានានិងការគាំទ្រកិច្ចការនេះផង ។

**ស៊ូហ្សាណា លីនតុន**

# សុន្ទរកថាថ្លែងដោយឯកឧត្តម សុខ អាន ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារសម្រាប់សហប្រតិបត្តិការជាមួយអ្នកជំនាញការច្បាប់បរទេស និងការរៀបចំដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម នៅក្នុងវេទិកាអន្តរជាតិស្តីអំពីការពិត យុត្តិធម៌ និងការបង្រួបបង្រួមផ្សះផ្សាជាតិ ដែលប្រព្រឹត្តទៅនៅទីក្រុងស្តុកខូម ប្រទេសស៊ុយអែដ នាថ្ងៃទី២៣-២៤ ខែមេសា ឆ្នាំ២០០២

ឯកឧត្តម អគ្គទូតនានា និងអ្នកចូលរួមក្នុងវេទិកាអន្តរជាតិនៅទីក្រុងស្តុកខូមលើកទីបី ជាទីមេត្រី!

ជាបឋមខ្ញុំសូមថ្លែងអំណរគុណចំពោះរដ្ឋាភិបាលស៊ុយអែដដែលបានចាត់ចែងឲ្យគណៈប្រតិភូកម្ពុជាបានចូលរួមនៅក្នុងវេទិកានេះ ដែលជាការផ្តល់ឱកាសដ៏មានតម្លៃសម្រាប់យើងខ្ញុំក្នុងការជួបជុំគ្នានិងផ្លាស់ប្តូរមតិយោបល់ជាមួយអ្នកសិក្សាជាន់ខ្ពស់ អគ្គទូត និងអ្នកជំនាញការច្បាប់មកពីបណ្តាប្រទេសនានានៅជុំវិញពិភពលោក ។ ការរៀនសូត្រពីបទពិសោធន៍របស់អ្នកដទៃនិងចូលរួមយោបល់របស់យើងផ្ទាល់ គឺជាឱកាសដ៏មានតម្លៃណាស់សម្រាប់យើងទាំងអស់គ្នា ។ ឆ្លៀតឱកាសនេះដែរ ខ្ញុំសូមថ្លែងនូវអំណរគុណចំពោះការគាំទ្រដែលរដ្ឋាភិបាលនិងប្រជាជនស៊ុយអែដ ផ្តល់សម្រាប់ការស្តារបនាប្រទេសកម្ពុជាឡើងវិញចាប់តាំងពីដើមឆ្នាំ១៩៧៩រហូតមកដល់ពេលបច្ចុប្បន្នទៀត ។ សូមរំឭកថា ក្នុងគ្រានោះមានអ្នកគាំទ្រយើងតិចតួចណាស់ ។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសក្ខីភាពបង្ហាញពីដំហរមិត្តភាពនេះ ហើយយើងសង្ឃឹមថាស្មារតីបែបនេះនឹងស្តែងឲ្យឃើញតាមរយៈការចូលរួមនិងការគាំទ្រចំពោះការជំនុំជម្រះក្តីដែលនឹងត្រូវរៀបចំឡើងនាពេលឆាប់ៗនេះ ។

នៅក្នុងខែមេសាកាលពី២៧ឆ្នាំកន្លងទៅ ខ្ញុំយល់ឃើញថាខ្លួនខ្ញុំរួមជាមួយនឹងជនរួមជាតិរបស់ខ្ញុំទើបតែចាប់ផ្តើមចេញដំណើរ ។ ដំណើរនេះចាប់ផ្តើមឡើងដោយមានជិតជាមទៅដោយសុបិនអាក្រក់ដែលមកសន្ធប់យើងខ្ញុំអស់កាល៣ឆ្នាំ៨ខែនិង២០ថ្ងៃ ។ ដោយមានមិត្តទាំងឡាយជួយចូលរួមផងនោះ យើងបានខំក្រោកឈរឡើងទាំងតគេះតគះ ខិតខំកម្ចាត់ខបទ្រពចង្រៃ និងខិតខំកសាងប្រទេសនិងជីវិតបាក់បែកខ្ទេចខ្ទាំរបស់ប្រជាជនកម្ពុជាសាជាថ្មី ។ ប៉ុន្តែមកដល់សព្វថ្ងៃនេះ ទោះបីជាយើងដឹងថាយើងទទួលបានសន្តិភាពជាលើកដំបូងក្នុងរយៈពេល៣០ឆ្នាំក៏ដោយក៏យើងជាជនជាតិខ្មែរមិនទាន់ចាកផុតពីស្រមោលអន្ទោលតាមប្រាណនៅឡើយទេ ។ ចំណែកឯប្រជាជននៅលើពិភពលោកក៏មិនទាន់ខិតខំប្រឹងប្រែងឲ្យអស់ពីដៃពីជើងដើម្បីធ្វើការជាមួយយើងក្នុងការសម្រេចបាននូវយុត្តិធម៌នេះដែរ ។

ជាអកុសល ក្រោយពីយើងបានផ្តួលរំលំរបបខ្មែរក្រហមនៅខែមករា ឆ្នាំ១៩៧៩ ភាគតិចបំផុតនៃសហគមន៍អន្តរជាតិដែលបានជួយយើងក្នុងការស្តារបនាប្រទេសឡើងវិញ ។ ថ្ងៃនេះខ្ញុំសូមបញ្ជាក់សាជាថ្មីនូវកតវេទិតាយ៉ាងជ្រាលជ្រៅចំពោះសប្បុរសជនទាំងនោះ ក្នុងនោះរួមទាំងប្រទេសស៊ុយអែដ ដែលបានជួយជ្រោមជ្រែងកិច្ចខិតខំប្រឹងប្រែងយើងខ្ញុំ ។ ប៉ុន្តែជាការគួរឲ្យងឿងឆ្ងល់និងឈឺចាប់នោះគឺថា អ្នកដែលបានប្រព្រឹត្តអំពើគួរឲ្យខ្លាចរអា ដែលក្នុងនោះមានពីរនាក់ (ប៉ុល ពត និង អៀង សារី) ត្រូវបានកាត់ទោសនៅក្នុងតុលាការអំពើប្រល័យពូជសាសន៍មុនគេនៅលើពិភពលោកក្នុងខែសីហា ឆ្នាំ១៩៧៩ នៅតែត្រូវបានបន្តអនុញ្ញាតឲ្យមានសិទ្ធិតំណាងប្រទេសកម្ពុជាប្រចាំនៅមហាសន្និបាតអង្គការសហប្រជាជាតិពេញមួយទសវត្សរ៍ឆ្នាំ១៩៨០ ហើយត្រូវបានទទួលជំនួយទាំងផ្នែកនយោបាយ

សេដ្ឋកិច្ច និងយោធា ក្នុងការវាយផ្ដួលរំលំរដ្ឋាភិបាលពិតប្រាកដនាពេលនោះ ។

លទ្ធផលនៃការគាំទ្របែបនេះបណ្ដាលឲ្យប្រជាជនកម្ពុជារាប់សែននាក់បានបាត់បង់ជីវិត និងទទួលរងនូវគ្រោះថ្នាក់ដែលបណ្ដាលមកពីគ្រាប់មីន ទោះបីជាខ្លួនត្រូវបានរំដោះឲ្យចាកផុតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហមក៏ដោយ ។ មនោគមវិជ្ជា និងផលប្រយោជន៍របស់ប្រទេសមហាអំណាចមួយចំនួន បានដ្ធិត្រចៀកបិទភ្នែកសហគមន៍អន្តរជាតិឲ្យបំភ្លេចការពិត យុត្តិធម៌ និងសិទ្ធិមនុស្ស និងធ្វើមិនដឹងមិនឮចំពោះសោកនាដកម្មនិងការបាត់បង់ជីវិតរបស់ប្រជាជនកម្ពុជារាប់លាននាក់ ។ កម្ពុជាមិនទទួលបានយុត្តិធម៌ទេ តែផ្ទុយទៅវិញទទួលបាននូវរង្វាន់មួយបែប គឺជីវិតស្ថិតនៅក្នុងភាពប្រទាញប្រទង់គ្នារវាងសន្តិភាពនិងសង្គ្រាមស៊ីវិល ការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅទ្រឹងមិនទៅមុខ និងមានគ្រាប់មីនរាប់លានគ្រាប់ដែលសព្វថ្ងៃនេះនៅតែបន្តគំរាមកំហែងដល់ជីវិតប្រជាជនក្រីក្រនៅតាមជនបទដាច់ស្រយាល ។

កិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីសឆ្នាំ១៩៩១បានបង្កើតធម្មានុរូបកម្មផ្នែកនយោបាយចំពោះខ្មែរក្រហម ហើយនៅពេលដែលអាជ្ញាធរបណ្ដោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា (ហៅកាត់ថាអ៊ុនតាក់) ចាកចេញពីប្រទេសកម្ពុជានៅឆ្នាំ១៩៩៣ រដ្ឋាភិបាលចម្រុះថ្មីមួយត្រូវតែទទួលបន្ទុកដោះស្រាយទប់ទល់ជាមួយនឹងនយោបាយបន្តសង្គ្រាមស៊ីវិល និងអស្ថិរភាពដែលបង្កឡើងដោយខ្មែរក្រហម ។ ពេលនោះយើងក៏បានប្រើយុទ្ធសាស្ត្រចម្រុះមួយដែលរួមមានយុទ្ធនាការតាមផ្លូវនយោបាយ តាមផ្លូវច្បាប់ តាមផ្លូវសេដ្ឋកិច្ច និងតាមផ្លូវយោធា ដែលក្នុងនោះរួមមានទាំងការតាក់តែងច្បាប់ឆ្នាំ១៩៩៤ដើម្បីដាក់ខ្មែរក្រហមឲ្យនៅក្រៅច្បាប់ និងកិច្ចខិតខំប្រឹងប្រែងនានាដើម្បីជម្រុញឲ្យសមាសភាពក្នុងជួរខ្មែរក្រហមចុះចូលនិងបំបែកខ្លួន ។ អ្វីដែលសម្ដេចនាយករដ្ឋមន្ត្រីហៅថា “នយោបាយឈ្នះ-ឈ្នះ” ដែលបង្កើតបានជាគោលការណ៍គ្រឹះនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជានោះ មានធាតុផ្សំ៥យ៉ាង ÷ “បំបែក ធ្វើឲ្យឯកោ បញ្ចប់ ធ្វើសមាហរណកម្ម និងអភិវឌ្ឍ” ។ តាមរយៈគោលការណ៍គ្រឹះនេះ អង្គការចាត់តាំងនយោបាយនិងយោធារបស់ខ្មែរក្រហមត្រូវបានបញ្ចប់ ប៉ុន្តែខ្មែរក្រហមដែលបានចុះចូលត្រូវតែទទួលបាននូវការធានាសុវត្ថិភាពនិងជីវិត សិទ្ធិធ្វើការងារនិងប្រកបអាជីពរបស់ខ្លួន និងការធានាទ្រព្យសម្បត្តិដែលខ្លួនមាន ។

នៅចុងខែធ្នូឆ្នាំ១៩៩៨ យើងបានបញ្ចប់អង្គការចាត់តាំងនយោបាយនិងយោធារបស់ខ្មែរក្រហមដោយជោគជ័យ ហើយអ្វីដែលយើងត្រូវជួបប្រទះគឺកិច្ចការភ្លោះរវាងការបង្រួបបង្រួមផ្សះផ្សាជាតិនិងយុត្តិធម៌ ។ កម្ពុជាប្រហែលជាអាចផ្ដល់នូវមេរៀនមួយចំនួនដែលទាញចេញពីបទពិសោធន៍របស់យើងផ្ទាល់នៅក្នុងដំណើរការបង្រួបបង្រួមនិងផ្សះផ្សាជាតិដ៏វែងឆ្ងាយនិងស្មុគស្មាញ ។ សព្វថ្ងៃនេះអតីតខ្មែរក្រហមបានទម្លាក់កាំភ្លើងចុះហើយមករួមរស់ជាមួយសង្គមជាតិ ចំណែកអតីតគូបក្ខដិបក្ខបានងាកមកចាប់ដៃគ្នាអភិវឌ្ឍន៍ប្រទេស ។

នៅក្នុងប្រទេសកម្ពុជា ការផ្សះផ្សាជាតិមិនមែនមានន័យថាបំភ្លេចអតីតកាលចោលនោះទេ ។ កិច្ចខិតខំប្រឹងប្រែងចម្បងៗក្នុងការស្វែងរកនិងចងក្រងឯកសារទាក់ទងនឹងការពិតដែលបានកើតឡើងនៅក្រោមរបបខ្មែរក្រហម ត្រូវបាននិងកំពុងតែធ្វើឡើងតាំងតែក្រោយពីការដួលរលំនៃរបបខ្មែរក្រហមមកម្ល៉េះ ។ នៅដើមឆ្នាំ១៩៧៩ មន្ទីរស-២១ដ៏អសោចត្រូវបានប្រែក្លាយទៅជាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ចំណែកឯវាលពិឃាតស្ថិតនៅជាយក្រុងភ្នំពេញដែលមានអ្នកទោសប្រមាណ១ម៉ឺន៩ពាន់នាក់ត្រូវបានសម្លាប់ចោលនោះ បានក្លាយទៅជាបូជនីយដ្ឋានជើងឯក ដែលនៅទីនោះអដ្ឋិធាតុរបស់ជនរងគ្រោះត្រូវបានខ្ទិសបង្សុកូលនិងរៀបចំថែរក្សានៅក្នុងចេតិយ ។ កសិណផ្ទាល់មាត់ និងភ័ស្តុតាងជាក់ស្ដែងនៃឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើង (រួមទាំងការជីករណ្ដៅនិងធ្វើកោសល្យវិច័យ) ត្រូវបានប្រមែប្រមូលសម្រាប់ដាក់ជូនតុលាការប្រជាជនបដិវត្តនៅឆ្នាំ១៩៧៩ ។ នៅដើមទសវត្សរ៍ឆ្នាំ១៩៨០ ការសិក្សាស្រាវជ្រាវក្នុងទ្រង់ទ្រាយធំបានប្រមូលបាននូវភ័ស្តុតាងជាញត្តិមកពីប្រជាជនកម្ពុជារហូតទៅដល់ជាង១លាននាក់មកពីស្ទើរគ្រប់ខេត្តទាំងអស់នៅទូទាំងប្រទេសកម្ពុជា ។

នៅក្នុងឱកាសនេះដែរ លោក ឆាំង យុ នឹងរៀបរាប់ជូន

នូវការងារដ៏មានតម្លៃដែលធ្វើឡើងចាប់តាំងពីឆ្នាំ១៩៩៥ដោយកម្មវិធីសិក្សាស្រាវជ្រាវអំពើប្រល័យពូជសាសន៍នៅកម្ពុជានិងមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានប្រមែប្រមូលនិងវិភាគយ៉ាងផ្ចិតផ្ចង់នូវឯកសារនានានិងទីតាំងប្រល័យពូជសាសន៍ដែលបានមកពីការចុះធ្វើផែនទីនៅទូទាំងប្រទេស ។

ដើម្បីជាការសម្តែងនូវការយកចិត្តទុកដាក់ថែរក្សាទីតាំងទាំងនេះ នៅខែធ្នូ ឆ្នាំ២០០១ រដ្ឋាភិបាលបានចេញសារាចរមួយទាក់ទងទៅនឹងការថែរក្សាអដ្ឋិធាតុជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងការរៀបចំអតីតតំបន់ការពាររបស់ខ្មែរក្រហមនៅអន្លង់វែងឲ្យក្លាយទៅជាតំបន់ទេសចរណ៍ប្រវត្តិ-សាស្ត្រ និងសម្រាប់អប់រំកូនខ្មែរសម័យបច្ចុប្បន្ននិងកូនខ្មែរជំនាន់ក្រោយ ក៏ដូចជាទេសចរបរទេសដែរ ។

ក៏ប៉ុន្តែទោះជាយ៉ាងនេះក្តី យើងក៏ទទួលស្គាល់ដែរថា សមិទ្ធផលរបស់កម្ពុជានៅក្នុងការស្វែងរកការពិតនិងការផ្សះផ្សាបង្រួបបង្រួមជាតិមិនទាន់អាចឈានទៅសម្រេចបាននូវយុត្តិធម៌សម្រាប់ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍នៅឡើយទេ ។ នេះជាកិច្ចការដែលជាគំនិតរបស់ប្រទេសយើងតាំងតែពីឆ្នាំ១៩៧៩មកម្ល៉េះ ដែលកាលនោះយើងបានបង្កើតតុលាការប្រជាជនបដិវត្តដែលខ្ញុំបានលើកឡើងរួចមកហើយ ។ គួរឲ្យសោកស្តាយដោយសារមានកង្វះខាតនៅក្នុងដំណើរការពេលនោះ ជាពិសេសដោយសារភាពឯកោផ្នែកនយោបាយរបស់រដ្ឋាភិបាលយើងធ្វើឲ្យប្រទេសខាងក្រៅគ្មានការអើពើចំពោះសក្ខីកម្មនិងសាលក្រមរបស់យើង ហើយកិច្ចការនាពេលនេះគឺជាកិច្ចការដែលយើងបាននិងកំពុងតែចូលរួមអស់រយៈពេលជាច្រើនឆ្នាំមកហើយ ។ ឥឡូវនេះ នៅពេលដែលយើងខិតខំស្វែងរកយុត្តិធម៌ យើងចង់ចាំយ៉ាងច្បាស់ថា បញ្ហានេះប្រាកដជាមិនប៉ះពាល់ដល់ដំណើរការផ្សះផ្សាបង្រួបបង្រួមជាតិដូចដែលយើងបានបរិយាយពីខាងដើមនោះទេ ។ នៅកម្ពុជា យើងស្វែងរកយុត្តិធម៌ដែលជាការលើកទឹកចិត្តដល់ការផ្សះផ្សារបួសសង្គម ។

នៅខែមិថុនា ឆ្នាំ១៩៩៧ សហនាយករដ្ឋមន្ត្រីកម្ពុជាបានផ្ញើសំណើដាក់ជូនអង្គការសហប្រជាជាតិសុំជំនួយការក្នុងការរៀបចំដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ សំណើនេះនាំដល់ការអនុម័តនូវសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិនៅខែធ្នូ ហើយបន្ទាប់មក លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ បានបង្កើតក្រុមអ្នកជំនាញការមួយក្រុម ។ ខ្ញុំសូមឆ្លៀតឱកាសនេះសម្តែងនូវការកោតសរសើរជាសាធារណៈចំពោះកិច្ចខិតខំប្រឹងប្រែងដ៏សំខាន់ក្រៃលែងរបស់ឯកឧត្តម ថូម៉ាស ហាម៉ាប៊ឺក ដែលកាលនោះជាតំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ។

ផ្នែកទីពីរនៃសុន្ទរកថារបស់ខ្ញុំនាថ្ងៃនេះគឺខ្ញុំចង់ចូលរួមជាមួយអស់លោកនិងលោកស្រីទាំងអស់ អំពីទស្សនវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាទៅលើកិច្ចខិតខំប្រឹងប្រែងទាំងនេះដែលចេះតែបន្តទៅមុខ ដើម្បីឈានទៅសម្រេចបាននូវយុត្តិធម៌ឧក្រិដ្ឋកម្មប្រព្រឹត្តឡើងដោយខ្មែរក្រហម ដែលក្នុងនោះយើងមានគោលការណ៍ជាមូលដ្ឋានគ្រឹះ៣÷

**ទីមួយ** គឺការគោរពនិងស្វែងរកយុត្តិធម៌ ។ យើងថ្កោលទោសឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយខ្មែរក្រហម ថាជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ យើងស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះនិងសម្រាប់ប្រជាជនកម្ពុជាទាំងមូល ។ យើងក៏ចូលរួមចំណែកដល់ការអភិវឌ្ឍន៍គោលការណ៍មនុស្សធម៌អន្តរជាតិដែរ ដោយថ្កោលទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍និងខិតខំទប់ស្កាត់កុំឲ្យអំពើនេះកើតឡើងសាជាថ្មី។ ប្រជាជនកម្ពុជាសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសហគមន៍អន្តរជាតិដែលបានចូលរួមនៅក្នុងដំណើរការស្វែងរកយុត្តិធម៌នៅក្នុងពេលប៉ុន្មានឆ្នាំកន្លងទៅនេះ ទោះបីជាក្នុងរបបប៉ុលពតនិងក្រោយបន្តិចអ្នកទាំងនោះធ្លាប់បានងាកចេញក៏ដោយ ។

**ទីពីរ** គឺថែរក្សាសន្តិភាព ស្ថិរភាពនយោបាយ និងឯកភាពជាតិដែលកម្ពុជាទើបតែសម្រេចបានថ្មីៗនេះ ។ ក្នុងរយៈពេលពីរខែកន្លងទៅនេះ យើងបានរៀបចំការបោះឆ្នោតនៅតាមមូលដ្ឋាននៅទូទាំងប្រទេសកម្ពុជា ហើយសប្តាហ៍មុននេះយើងបានប្រារព្ធពិធីចូលឆ្នាំថ្មីប្រពៃណីជាតិ ។ ពិធីទាំងពីរនេះប្រព្រឹត្ត

ទៅក្នុងបរិយាកាសមិនធ្លាប់មានពីមុនមក ពោលគឺប្រកបដោយសុទិដ្ឋិនិយមនិងមិនសូវមានអំពើហិង្សា ដែលជាការផ្ទុយស្រឡះទៅនឹងស្ថានការណ៍កាលពីពេលមុនៗ ទោះបីជាយើងមិនទាន់សម្រេចបាននូវច្បាប់សង្គមនិងរបៀបរបបសង្គមមួយរយភាគរយ និងសន្តិសុខមួយរយភាគរយយ៉ាងណាក៏ដោយ ។ យើងមិនអាចសម្រេចបានមួយរយភាគរយបានទេ ដោយសារតែមានដំណើរប៉ះទង្គិចនៅក្នុងអតីតកាលដែលទើបតែកន្លងទៅថ្មីៗនេះ ។ ក៏ប៉ុន្តែយើងមានមោទកភាពក្នុងការធ្វើដំណើរទៅមុខនៅក្នុងដំណើរការពង្រឹងស្ថិរភាពនយោបាយ សន្តិភាព និងសន្តិសុខ នៅក្នុងប្រទេសកម្ពុជា ហើយនេះគឺជាសមិទ្ធផលដ៏មានតម្លៃចំពោះមាតុភូមិរបស់យើង ។ អ្វីៗដែលយើងធ្វើមិនត្រូវឲ្យប៉ះពាល់ដល់សន្តិភាពនិងស្ថិរភាពឡើយ ។ នៅក្នុងកិច្ចដំណើរការទាំងមូលក្នុងការរៀបចំបង្កើតតុលាការកាត់ទោសខ្មែរក្រហមអស់រយៈពេលជាង៤ឆ្នាំកន្លងមកនេះ យើងតែងតែរិះរកវិធីនានាដើម្បីស្វែងរកសម្បទាន (កុងសង់ស៊ីស) ដោយផ្អែកលើការគោរពផលប្រយោជន៍ជាតិជាធំ ។

មានមតិមួយចំនួនបានរិះគន់ថាដំណើរការនេះធ្វើដំណើរទៅមុខតើមៗ ប៉ុន្តែការសម្រេចនូវការមូលមតិគ្នាពិតជាការពិបាកណាស់ ពោលគឺទាល់តែទទួលបាននូវសំឡេងឆ្នោតដាច់ខាតពីសំណាក់អង្គនីតិបញ្ញត្តិទាំងពីរ (រដ្ឋសភាជាតិនិងព្រឹទ្ធសភា) ទើបការសម្រេចមួយអាចយកជាការបាន ។ ច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមត្រូវបានប្រកាសឲ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ គឺមានរយៈពេល២ឆ្នាំគត់បន្ទាប់ពីសេចក្តីព្រាងច្បាប់ត្រូវបានយកមកដាក់នៅលើតុចរចា ។ រយៈពេលនេះ មិនយូរប៉ុន្មានទេក្នុងការបង្កើតច្បាប់ដែលមិនធ្លាប់មានពីមុនទាក់ទងនឹងបញ្ហាដ៏ងាយនឹងប្រេះស្រាំនិងសំខាន់បែបនេះ ។

**ទីបី** គឺការគោរពអធិបតេយ្យជាតិដែលត្រូវបានលើកឡើងជាគោលការណ៍គ្រឹះនៅក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ ។ ការលើកឡើងនូវគោលការណ៍គោរពអធិបតេយ្យជាតិរបស់យើងគឺមានហេតុផល ។ យើងបានពុះពារដោយឥតសំចៃដើម្បីឲ្យមានគោលការណ៍នេះ ។ រាជរដ្ឋាភិបាលកម្ពុជាមិនបានទទួលយកនូវអនុសាសន៍របស់ក្រុមអ្នកជំនាញការទេ ដែលស្នើឲ្យមានអង្គជំនុំជម្រះក្តីនៅក្រៅប្រទេសដោយគ្មានការចូលរួមពីសំណាក់ជនជាតិខ្មែរលើកលែងតែចុងចោទឬអ្នកចូលរួមមើលនោះ ។ ដូចសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានកត់សម្គាល់កាលពីពេលនោះដែរ កិច្ចការដែលលោកអគ្គលេខាធិការអង្គការសហប្រជាជាតិចង់ផ្តល់ឲ្យជនជាតិខ្មែរគឺ "ឲ្យចូលក្នុងព្រៃចាប់ខ្លា" និង "ធ្វើជាសុនខបម្រើរបស់អង្គការសហប្រជាជាតិតែប៉ុណ្ណោះ" ។

គំនិតរបស់យើងកន្លងមកក៏ដូចជាបច្ចុប្បន្នគឺថា កម្ពុជាមានកាតព្វកិច្ចច្បាស់ក្នុងការរៀបចំការវិនិច្ឆ័យទោសក្រោមមាត្រា៦នៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ហើយអាចចាប់ផ្តើមដំណើរការនៅក្នុងតុលាការក្នុងស្រុកដែលមានស្រាប់ ។ អនុញ្ញាតឲ្យខ្ញុំរំឭកជូនអ្នករិះគន់ទៅលើគំនិតនេះថា គោលការណ៍ជួយបំពេញគ្នាទៅវិញទៅមកគឺជាគ្រឹះយ៉ាងសំខាន់ចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិដែលក្នុងនោះកម្ពុជាមានមោទកភាពដែលបានក្លាយខ្លួនជារដ្ឋសមាជិកទី៦០ដែលបានផ្តល់សច្ចាប័ននិងអនុវត្តជាក់ស្តែងក្នុងរយៈពេល១០ឆ្នាំក្រោយមក ។

ក៏ប៉ុន្តែ ទោះបីជាយើងមានកាតព្វកិច្ចទាំងស្រុងនៅក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅក្នុងតុលាការក្នុងស្រុកយ៉ាងណាក៏ដោយ យើងក៏បានស្វែងរកការចូលរួមពីសំណាក់អន្តរជាតិដែរ ជាពិសេសតាមរយៈអង្គការសហប្រជាជាតិផ្ទាល់តែម្តង ។ ហេតុអ្វី? ម្យ៉ាងគឺដោយសារយើងដឹងច្បាស់ណាស់អំពីចំណុចខ្សោយរបស់ប្រព័ន្ធតុលាការរបស់យើង ហើយយើងចង់បានជំនួយការដើម្បីឲ្យការជម្រះក្តីនេះចូលតាមបទដ្ឋានមួយដែលទទួលស្គាល់ដោយអន្តរជាតិ ។ ម្យ៉ាងទៀតខ្ញុំសូមនិយាយដោយត្រង់ទៅចុះថា យើងមានអារម្មណ៍ថាវាជាការសំខាន់សម្រាប់សហគមន៍អន្តរជាតិ ដើម្បីឲ្យចូលរួមអនុវត្តកិច្ចការនេះប្រយោជន៍ដើម្បីឲ្យសហគមន៍នេះមានការដាច់ស្រេចច្បាស់លាស់ទាំងអស់គ្នាទៅលើប្រវត្តិរបស់ខ្លួនពីមុនមកដែលគាំទ្រខ្មែរក្រហម ។ នេះគឺជាការឲ្យហេតុផលរបស់យើងនៅពេលដែលយើងសុំឲ្យមានជំនួយនៅឆ្នាំ១៩៩៧ និងនៅពេលដែលយើងសម្រេចកិច្ចព្រមព្រៀងជាគោលការណ៍ជាមួយអង្គការសហប្រជាជាតិក្នុងការរៀបចំអង្គជំនុំជម្រះជាលក្ខណៈជាតិដោយមានការចូលរួមពីសំណាក់អន្តរជាតិ ។ មកដល់សព្វថ្ងៃនេះ

យើងក៏នៅតែប្រកាន់យកហេតុផលនេះដដែល ។

នៅឆ្នាំ១៩៩៩ និងឆ្នាំ២០០០ អង្គការសហប្រជាជាតិបានបញ្ជូនគណៈប្រតិភូចំនួន៣ក្រុមមកកម្ពុជា ដែលក្រុមនីមួយៗសុទ្ធតែដឹកនាំដោយអ្នកជំនាញការកម្រិតខ្ពស់ៗមកពីការិយាល័យច្បាប់នៃអង្គការសហប្រជាជាតិ (ដូចជា ឯកឧត្តម ហេន កូរេល និង រ៉ាហ្វ ហ្សាកលីន ជាដើម) ។ ជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងទាំងអស់នេះដែលធ្វើឡើងដោយភាគីទាំងសងខាងនៅក្នុងអំឡុងពេលចរចាគ្នា យើងបានឈានទៅដល់ការសម្រេចកិច្ចព្រមព្រៀងលើគោលការណ៍សំខាន់ៗមួយចំនួនតាមរយៈដំណើរការដែលមាន៥ជំហានសំខាន់ៗដូចខាងក្រោម÷

១) នៅពេលយើងមានការខ្វែងគំនិតគ្នាវវាងសញ្ញាណនៃតុលាការអន្តរជាតិនិងការជំនុំជម្រះក្តីនៅក្នុងតុលាការជាតិ ពេលនោះយើងបានបោះជំហានទៅមុខមួយជំហាន យល់ព្រមយកតុលាការជាតិ ប៉ុន្តែធ្វើឡើងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងប្រព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ ដោយដើរតាមនីតិវិធីកម្ពុជា ។ ជាពិសេសទៅទៀតនោះ អង្គជំនុំជម្រះវិសាមញ្ញនេះនឹងមានចៅក្រមបរទេសចូលរួមទៀតផង ។ នៅពេលនោះពោលគឺនៅឆ្នាំ១៩៩៩ គំនិតនេះគឺជាគំនិតដែលមិនធ្លាប់មានជាអន្តរជាតិពីមុនមក ។

២) បន្ទាប់ពីយើងបានព្រមព្រៀងគ្នាឲ្យមានការចូលរួមពីបរទេសរួចមក ក៏លេចឡើងនូវការទាល់ច្រកទាក់ទងនឹងបញ្ហាថាតើភាគីណាមួយដែលត្រូវទទួលនូវការចូលរួមពីចៅក្រមច្រើនជាងគេ ។ ខាងអង្គការសហប្រជាជាតិចង់បានចៅក្រមបរទេសច្រើនជាងចៅក្រមខ្មែរ ចំណែកខាងយើងទទូចចង់ឲ្យមានសមាសភាពចៅក្រមខ្មែរច្រើនជាង ។ ដោយមានការសម្របសម្រួលលើកទីពីររួចមក ភាពទាល់ច្រកនេះក៏ត្រូវបានទម្លាយ ។ ដំណោះស្រាយគឺថាចៅក្រមខ្មែរមានច្រើនជាងចៅក្រមបរទេស ប៉ុន្តែមតិភាគតិចនឹងក្លាយជា "មតិភាគតិចដែលមានអំណាចរារាំង" ។ មានន័យថា បើគ្មានមតិភាគតិចទេ មតិភាគច្រើនក៏មិនអាចចេញសាលក្រមបានដែរ ។ ជាថ្មីម្តងទៀត យើងបានដោះស្រាយភាពទាល់ច្រកនេះតាមរយៈការទទួលយកនូវការរៀបចំចាត់ចែងតាមរូបមន្ត "មតិភាគច្រើនពិសេស"នេះ ។

៣) ការសម្របសម្រួលទីបីពាក់ព័ន្ធទៅនឹងគំនិតឲ្យមានសហព្រះរាជអាជ្ញា ។ អង្គការសហប្រជាជាតិចង់ឲ្យមានព្រះរាជអាជ្ញាអន្តរជាតិ ចំណែកយើងវិញចង់បានព្រះរាជអាជ្ញាជនជាតិខ្មែរ ។ ដូច្នេះយើងសំយោគមកថាឲ្យមានសហព្រះរាជអាជ្ញា ។ ទាក់ទងនឹងចៅក្រមស៊ើបអង្កេតក៏យកតាមរូបមន្តនេះដែរ ។

៤) ការសម្របសម្រួលទី៤ដែលជាការសម្របសម្រួលដ៏សំខាន់ពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចនៅពេលមានការមិនចុះសម្រុងគ្នារវាងសហព្រះរាជអាជ្ញាចំពោះការចេញដីការចោទប្រកាន់ ។ អង្គការសហប្រជាជាតិចង់ឲ្យព្រះរាជអាជ្ញានីមួយៗធ្វើការដោយស្វ័យភាព ។ យើងអះអាងថា ដោយសារយើងបានព្រមព្រៀងរួចហើយទៅលើគំនិត"សហ"ព្រះរាជអាជ្ញាជាគោលការណ៍គេគួរតែធ្វើសហប្រតិបត្តិការនៅក្នុងកិច្ចដែលខិតខំសម្រេចជាមួយគ្នា ។ ប៉ុន្តែប្រសិនបើសហព្រះរាជអាជ្ញាមិនដើរស្របគ្នាទេនោះ បញ្ហាច្បាស់ជាកើតឡើងមិនខាន ។ បញ្ហានេះទៀតសោតក៏ត្រូវបានដោះស្រាយតាមរយៈការបង្កើតឡើងនូវយន្តការមួយហៅថាអង្គបុរេជំនុំជម្រះដើម្បីដោះស្រាយការខ្វែងគំនិតគ្នារវាងសហព្រះរាជអាជ្ញានិងរវាងសហចៅក្រមស៊ើបអង្កេត ។

៥) ការសម្របសម្រួលទី៥ចេញជារូបរាងឡើងដោយសារតែអង្គការសហប្រជាជាតិចង់បានច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមនេះដែលមិនបញ្ចូលលទ្ធភាពនៃការលើកលែងទោសឬបន្ធូរបន្ថយទោសចំពោះជនទាំងឡាយដែលត្រូវបានចោទប្រកាន់ឬកាត់ឲ្យជាប់ទោស ។ ក្នុងស្មារតីនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោសនិងលើកលែងទោស ។ យើងមិនចង់ឲ្យច្បាប់នេះមានខ្លឹមសារផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញរបស់យើងទេ ។ ជាការសម្របសម្រួល យើងបានយល់ស្របចែងក្នុងច្បាប់នេះថា រាជរដ្ឋាភិបាលកម្ពុជាមិនអាចស្នើសុំព្រះមហាក្សត្រឲ្យលើកលែងទោសឬការអនុគ្រោះទោសឡើយ ។ នាយករដ្ឋមន្ត្រីរបស់យើងនិងខ្ញុំបានលើកឡើងម្តងហើយម្តងទៀតថា គ្មានជនណាម្នាក់ស្ថិតនៅលើច្បាប់ទេ ហើយអ្វីៗនឹងអាស្រ័យទៅលើអង្គជំនុំជម្រះវិសាមញ្ញជាអ្នកសម្រេចថាតើជនណានឹងត្រូវចោទប្រកាន់ ឬកាត់ឲ្យជាប់ទោស ។

នៅក្នុងដំណាក់កាលនេះ (នៅពាក់កណ្តាលឆ្នាំ២០០០) យើងយល់ថាការចរចារបស់យើងជាមួយនឹងអង្គការសហប្រជាជាតិបានឈានដល់កិច្ចព្រមព្រៀងមួយ ទៅលើគោលការណ៍និងវចនាសម្ព័ន្ធសំខាន់ៗមួយចំនួន ។ រួចមកយើងឈានទៅមុខទៀត គឺដល់ដំណាក់កាលតាក់តែងច្បាប់ ។ ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យត្រូវបានអនុម័តដោយសភាជាតិនិងព្រឹទ្ធសភានៅខែមករា ឆ្នាំ២០០១ ។ ក្រោយពីមានវិសោធនកម្មទៅលើលក្ខណៈបច្ចេកទេសរួចមក សម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា បានឡាយព្រះហស្តលេខាឲ្យចូលជាធរមាននៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ។

ខ្ញុំសូមសង្កត់ធ្ងន់នៅទីនេះថា ច្បាប់នេះគឺជាលទ្ធផលនៃការចរចាជាមួយអង្គការសហប្រជាជាតិ ហើយមានលក្ខណៈខុសពីសេចក្តីព្រាងដើមដែលដាក់នៅលើតុចរចាដោយភាគីទាំងសងខាងនៅខែសីហា ឆ្នាំ១៩៩៩ ។

យើងមានការភ្ញាក់ផ្អើលនិងស្រងាកចិត្តយ៉ាងខ្លាំងដែលប្រមាណជា៦ខែក្រោយ បន្ទាប់ពីច្បាប់នេះត្រូវបានប្រកាសឲ្យប្រើប្រាស់ យើងបានទទួលសំបុត្រមួយច្បាប់ពីឯកឧត្តម ហេន ខូរេល ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០២ ដែលនិយាយថាអង្គការសហប្រជាជាតិនឹងឈប់ចរចាជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការបង្កើតអង្គជំនុំជម្រះវិសាមញ្ញតទៅទៀតហើយ ។

វាជាការគួរឲ្យភ្ញាក់ផ្អើលខ្លាំងយ៉ាងខ្លាំងនៅពេលអានសំបុត្រទៅឃើញថា អគ្គលេខាធិការដ្ឋានអង្គការសហប្រជាជាតិជឿថា «មើលទៅមិនអាចដោះស្រាយបានតាមរយៈការចរចាទៅមុខទៀតទេ» ប្រសិនបើគិតពីអ្វីដែលភាគីទាំងពីរបានធ្វើជាមួយគ្នាយ៉ាងច្បាស់ក្រឡែតតាមរយៈការចរចានេះ ។ វាមិនមែនជាការងាយស្រួលទេក្នុងការបើកទូកក្តោងកាត់ទឹកដែលមិនទាន់បានស្ទាបស្ទង់ជាមុន និងរៀបគម្រោងប្លង់តុលាការជាតិដែលមិនធ្លាប់មានពីមុនមកដោយមានការចូលរួមពីអន្តរជាតិ ។ ការសម្របសម្រួលនានាត្រូវបានធ្វើឡើងទាំងសងខាង ប៉ុន្តែខ្ញុំជឿជាក់ថាគំរូដែលយើងបានរៀបចំឡើងនិងដែលប្រកាសឲ្យចូលជាធរមានឲ្យក្លាយជាច្បាប់កម្ពុជានៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ កន្លងទៅនេះគឺជាមូលដ្ឋានគ្រឹះមួយដ៏សំខាន់ ។ ខ្ញុំជឿជាក់ថាច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដោយមានការចូលរួមពីអន្តរជាតិ គឺតំណាងឲ្យគោលការណ៍សំខាន់ៗទាំងអស់ដែលយល់ស្របគ្នាដោយភាគីទាំងសងខាងនៅពេលចរចា ដែលក្នុងនោះរួមទាំងការធ្វើឲ្យចូលជាបទដ្ឋានដែលទទួលស្គាល់ដោយអន្តរជាតិផង ។

ក្រោយពីប្រកាសច្បាប់នេះឲ្យចូលជាធរមាន យើងសង្ឃឹមថានឹងធ្វើដំណើរឆ្ពោះទៅមុខ ឈានទៅបញ្ចប់ដំណើរការនេះ ប៉ុន្តែផ្ទុយមកវិញអង្គការសហប្រជាជាតិបែរជាប្រកាសការដកថយឈប់ចូលរួម ។ ដោយសារពេលវេលាមានកំណត់ ខ្ញុំមិនអាចនិយាយឲ្យបានលម្អិតអំពីការផ្លាស់ប្តូរសារលិខិតរវាងខ្ញុំផ្ទាល់និងឯកឧត្តម ហេន ខូរេល ខ្ញុំសូមនិយាយឲ្យបានច្បាស់ថា យើងគិតថាគ្មានបញ្ហាណាមួយក្នុងចំណោមបញ្ហាទាំងអស់ដែលលើកឡើងនេះមិនអាចដោះស្រាយរួចនោះទេ ។ ប្រសិនបើអស់លោក លោកស្រីមានចំណាប់អារម្មណ៍ទៅលើចំណុចពិស្តារថែមទៀត សូមអញ្ជើញមើលតាមរយៈវើបសៃដែលយើងបានបង្កើត នៅក្នុងនោះមានឯកសារសំខាន់ៗចេញពីភាគីកម្ពុជានៅក្នុងអំឡុងពេលចរចា ក៏ដូចជាឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធ *(www.cambodia.gov.kh/krt main)* ។

ក៏ប៉ុន្តែចាំបាច់ខ្ញុំត្រូវតែបញ្ជាក់ចំណុចមួយ ដោយហេតុថាចំណុចនេះហាក់ដូចជាបុព្វហេតុចម្បងដែលធ្វើឲ្យអង្គការសហប្រជាជាតិដកខ្លួនថយ ។ ចំណុចនេះទាក់ទងទៅនឹងទំនាក់ទំនងរវាងច្បាប់កម្ពុជាដែលបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាមួយនឹងអត្ថបទសហប្រតិបត្តិការ *(Articles of Cooperation)* ដែលស្នើឡើងឲ្យមានការចុះហត្ថលេខាដោយភាគីទាំងពីរ ។ តាមគំនិតយើងគឺថា ច្បាប់ដែលត្រូវបានអនុម័តដោយអង្គនីតិបញ្ញត្តិកម្ពុជាក្រោមដំបូលរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជាបានកំណត់ពីដែនយុត្តាធិការនិងសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញ ក៏ដូចជាសមាសភាពវចនាសម្ព័ន្ធចាត់តាំង និងនីតិវិធីក្នុងការធ្វើសេចក្តីសម្រេចចិត្ត ។ ចំណែកឯអត្ថបទសហ-

ប្រតិបត្តិការ គឺជាអ្នកសម្រេចអំពីទម្រង់នៃសហប្រតិបត្តិការរវាង រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិក្នុងការអនុវត្ត បទបញ្ញត្តិទាំងឡាយ ចែងនៅក្នុងច្បាប់ទាក់ទងដល់ការគាំទ្រពី បរទេសផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ ។ ដូច្នេះយើងឃើញថា ឯកសារពីរនេះមានភាពបំពេញឲ្យគ្នាទៅវិញទៅមក ហើយយើង មិនចាំបាច់បង្កើតឋានានុក្រមរវាងឯកសារទាំងពីរនេះទេ ។

ឥឡូវនេះយើងចូលមកដល់ខែមេសា ឆ្នាំ២០០២ ហើយ កំពុងតែស្ថិតនៅក្នុងដំណាក់កាលចុងក្រោយនៃដំណើរលើផ្លូវដ៏ វែងឆ្ងាយរបស់យើង ។ យើងមិនទាន់ច្បាស់នៅឡើយទេថាតើ កម្ពុជានឹងត្រូវបន្តចិត្តដើរលើកំណាត់ផ្លូវនេះដោយគ្មានការ គាំទ្រពីអង្គការសហប្រជាជាតិដែរឬយ៉ាងណានោះ ។ សូម អនុញ្ញាតឲ្យខ្ញុំបញ្ជាក់សាជាថ្មីថា ខាងភាគីកម្ពុជានៅតែបើកទ្វារ ចំហនៅឡើយសម្រាប់ការចរចាសាជាថ្មីជាមួយអង្គការសហ ប្រជាជាតិ ហើយសម្តេចនាយករដ្ឋមន្ត្រីរបស់យើងក៏បានមាន ប្រសាសន៍ដែរថា យើងមានសុឆន្ទៈរង់ចាំការផ្លាស់ប្តូរចិត្តពីខាង ភាគីអង្គការសហប្រជាជាតិ ។

ប៉ុន្តែយើងមិនអាចរង់ចាំជារៀងរហូតនោះទេ ។ មាត្រា ៤៦នៃច្បាប់នេះបញ្ជាក់ច្បាស់ថា ដោយសារការចូលរួមរបស់ អង្គការសហប្រជាជាតិមានលក្ខណៈសំខាន់ចាំបាច់ ប្រសិនបើ អង្គការសហប្រជាជាតិដើរចេញមិនព្រមចូលរួម កម្ពុជាមាន សិទ្ធិបន្តបង្កើតអង្គជំនុំជម្រះវិសាមញ្ញដោយគ្មានអង្គការសហ ប្រជាជាតិ ដោយសង្ឃឹមថានឹងមានការចូលរួមនិងឧបត្ថម្ភគាំទ្រ ពីសំណាក់រដ្ឋជាសមាជិកនិងឥស្សរជនច្បាប់បរទេស ឬជម្រើស ចុងក្រោយគឺធ្វើការដោយខ្លួនឯងទាំងស្រុងតែម្តង ។ ខ្ញុំសូម សម្តែងនូវអំណរគុណជាពិសេសចំពោះលោកនាយករដ្ឋមន្ត្រីនៃ សាធារណរដ្ឋឥណ្ឌា ដែលបានសន្យាថានឹងបញ្ជូនចៅក្រមមួយរូប មកចូលរួមក្នុងដំណើរការនេះ ។ (ខ្ញុំធ្លាប់បានធ្វើជាឯកអគ្គរដ្ឋទូត កម្ពុជាប្រចាំនៅប្រទេសនេះម្តងដែរ) ។ ឥណ្ឌាបានសម្តែងឲ្យ ឃើញសាជាថ្មីម្តងទៀតនូវភាពជាមិត្តជិតដិតដែលជួយគ្នា នៅគ្រាក្រ ។

ខ្ញុំសូមសង្កត់ធ្ងន់ថា រាជរដ្ឋាភិបាលកម្ពុជាជំនួសមុខឲ្យ ប្រជាជនកម្ពុជានិងមនុស្សជាតិទាំងមូល នៅតែតាំងចិត្តស្វែង រកយុត្តិធម៌នៃអំពើឧក្រិដ្ឋដែលប្រព្រឹត្តឡើងដោយខ្មែរក្រហម ។ ការតាំងចិត្តដ៏មុតមាំនេះត្រូវបានបង្ហាញឲ្យឃើញតាមរយៈការ ចំណាយពេលវេលានិងថាមពលដ៏ច្រើនដែលយើងបានធ្វើជាង ៣ឆ្នាំកន្លងមក តាំងពីសម្តេចនាយករដ្ឋមន្ត្រីបានបង្កើតក្រុម ការងារសម្រាប់ប្រតិបត្តិការជាមួយអ្នកជំនាញការច្បាប់បរទេស និងការរៀបចំដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមដែល រូបខ្ញុំផ្ទាល់ត្រូវបានតែងតាំងជាប្រធាន ។ ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ ថា នេះជាពេលវេលានិងថាមពលដែលត្រូវបានបង្វែរយកមក ពីការងារបន្ទាន់មួយចំនួនទាក់ទងនឹងការស្តាបនាជាតិឡើងវិញ ប៉ុន្តែយើងខ្ញុំរៀបចំខ្លួនរួចជាស្រេចក្នុងការធ្វើពលិកម្មដើម្បីឈាន ទៅសម្រេចបាននូវយុត្តិធម៌ពិតប្រាកដមួយ ។ ដូចដែលខ្ញុំបាន បញ្ជាក់រួចហើយនៅក្នុងលិខិតរបស់ខ្ញុំចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០០២ ផ្ញើជូនឯកឧត្តម ហេន ខូរេល ថា យើងជឿជាក់ថា ច្បាប់ដែលចរចាដោយយើង និងប្រកាសឲ្យប្រើប្រាស់នៅថ្ងៃ ទី១០ ខែសីហា ឆ្នាំ២០០១ ផ្តល់នូវគ្រឹះយ៉ាងរឹងមាំមួយ ហើយយើងសង្ឃឹមថាអង្គការសហប្រជាជាតិនឹងចូលរួមជាមួយ យើងក្នុងការអនុវត្តច្បាប់ដែលចូលជាធរមានរួចហើយនេះ ។

ផ្ទៃរឿងសំខាន់ៗនៅក្នុងវេទិកាឆ្នាំនេះគឺភាពអសកម្មក្នុង ការកាត់សេចក្តីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ កម្ពុជាដឹង ច្បាស់ថា កាលណាយុត្តិធម៌ត្រូវបានពន្យារពេល នោះមានន័យ ថាយុត្តិធម៌ត្រូវបានបដិសេធចោលហើយ ។ យើងបានរង់ចាំ អស់កាលជាង២៧ឆ្នាំមកហើយ ហើយមិនអាចនៅទន្ទឹងរង់ចាំ តទៅទៀតបានទេ ។ សូមអញ្ជើញចូលរួមជាមួយយើងខ្ញុំក្នុង ការអនុវត្តកិច្ចការនេះ ។

(ប្រែសម្រួលក្រៅផ្លូវការដោយ សួ ប៊ុនស៊ូ)

**ពាក្យស្លោកខ្មែរក្រហម**

**◆ បំផុសមហាចលនាបដិវត្តរបស់មហាជន ការពារប្រទេស កសាងប្រទេស ធ្វើបដិវត្តន៍សង្គមនិយមឱ្យសន្ធោសន្ធៅជាប់ ជានិច្ច ដើម្បីកសាង វិនិច្ឆ័យ សារិតសំរាំង និងជ្រើសរើសជួរ កម្មាភិបាលល្អ របស់មហាជនរបស់បក្ស។**

**(ឯកសារ D១៣៧៩២)**




## គណៈកម្មាធិការសិទ្ធិមនុស្ស

*១៧) សូមអះអាងសាជាថ្មីថា ការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរជាងគេបំផុតនៅក្នុងប្រវត្តិសាស្ត្រកម្ពុជាកន្លងទៅថ្មីៗនេះត្រូវបានប្រព្រឹត្តឡើងដោយខ្មែរក្រហម ហើយទទួលស្គាល់ថា ការដួលរលំជាលើកចុងក្រោយនៃចលនាខ្មែរក្រហម កិច្ចខិតខំប្រឹងប្រែងដែលមានជាបន្តរបស់រដ្ឋាភិបាល បានត្រួសត្រាយផ្លូវសម្រាប់ការស្តារឡើងវិញនូវសន្តិភាព ស្ថេរភាព និងការបង្រួបបង្រួមផ្សះផ្សាជាតិនៅកម្ពុជា ហើយនិងការស៊ើបអង្កេត និងកាត់ទោសមេដឹកនាំខ្មែរក្រហម ។*

*សូមអំពាវនាវដល់រដ្ឋាភិបាលកម្ពុជាឲ្យធានាឲ្យប្រាកដថា មេដឹកនាំកម្ពុជាប្រជាធិបតេយ្យនិងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ត្រូវតែនាំមកកាត់ទោសដោយយុត្តិធម៌ត្រឹមត្រូវ និងតាមនីតិវិធីត្រឹមត្រូវតាមច្បាប់ទៅតាមបទដ្ឋានអន្តរជាតិ ។ ទាក់ទិននឹងបញ្ហានេះ សូមទទួលស្គាល់នូវការចាំបាច់ឲ្យរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិធ្វើសហប្រតិបត្តិការគ្នា ។*

*១៨) សូមអំពាវនាវដល់ភាគីទាំងពីរបន្តការពិភាក្សាសាជាថ្មីទៅលើការបង្កើតតុលាការមួយដើម្បីឈានទៅសម្រេចក្នុងគោលបំណងនេះ ហើយសូមអំពាវនាវដល់សហគមន៍អន្តរជាតិឲ្យផ្តល់នូវជំនួយសម្រាប់បម្រើវិស័យនេះ ។*

*(ប្រែសម្រួលសេចក្តីដកស្រង់ក្រៅផ្លូវការដោយ សួ ប៊ុនស៊ូ)*

# ការឆ្លុះបញ្ចាំងអំពីវាសនាតុលាការប្រល័យពូជសាសន៍នៅកម្ពុជា

អង្គការសហប្រជាជាតិបានប្រកាសថ្មីៗនេះថា ខ្លួនដកថយមិនចូលរួមក្នុងតុលាការកាត់សេចក្តីអំពើប្រល័យពូជសាសន៍នៅកម្ពុជាទេ ។ ការសម្រេចចិត្តបែបនេះ ទោះបីជាមានហេតុផលអំពីការផ្លាស់ប្តូរនយោបាយយ៉ាងណាក៏ដោយ ក៏នៅតែមានឥទ្ធិពលខ្លាំងណាស់ ។ ដូច្នេះតើធ្វើដូចម្តេចទើបជនរងគ្រោះក្រោមនយោបាយឃោរឃៅរបស់ ប៉ុល ពត បានទទួលយុត្តិធម៌ ការជួយសម្រាលទុក្ខ និងបំភ្លេចការឈឺចាប់ខ្លះ នៅខណៈដែលខ្លួនកំពុងតែរស់នៅក្នុងសម្ពាធទាំងផ្លូវកាយនិងផ្លូវចិត្តនៅនឹងមុខ



បែបនេះ? តើធ្វើដូចម្តេចទើបកូនចៅជំនាន់ក្រោយទទួលបានការអប់រំអំពីប្រវត្តិដ៏អសោចរបស់ប្រទេសខ្លួនបាន?

សេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិផ្អែកមួយផ្នែកទៅលើការកំណត់ច្បាស់ថា តុលាការកម្ពុជានឹងមានលក្ខណៈលម្អៀងនិងមិនយុត្តិធម៌ ។ ក៏ប៉ុន្តែគេមិនអាចធ្វើឲ្យសេចក្តីសម្រេចចិត្តនេះត្រឡប់ថយក្រោយវិញបានឡើយ ។ តុលាការដែលមានការយល់ស្របពីសហគមន៍អន្តរជាតិ ច្បាស់ជានឹងធ្វើការចោទប្រកាន់ ចាប់ខ្លួន និងការវិនិច្ឆ័យទោសមេដឹកនាំខ្មែរក្រហមដែលនៅរស់ដែលជាមេគំនិតធ្វើឲ្យមនុស្សស្លាប់និងការបំផ្លិចបំផ្លាញយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ អង្គការសហប្រជាជាតិចង់ជួយជ្រោមជ្រែងក្នុងដំណើរការរៀបចំគម្រោងការនិងការអនុវត្តផ្ទាល់របស់តុលាការនេះតាមរយៈបទពិសោធន៍ដ៏ច្រើនដែលខ្លួនទទួលបានក្នុងការកាត់ទោសចារីប្រព្រឹត្តអំពើប្រល័យពូជសាសន៍នៅអារូស្សា តង់ហ្សានី និងឡាអេ ។ ប៉ុន្តែអង្គការសហប្រជាជាតិ



ដកថយនេះ គឺដោយសារមានអារម្មណ៍ថាខ្លួនគ្មានផ្លូវណាជ្រើសរើសក្រៅពីនេះ ។

រដ្ឋាភិបាលកម្ពុជាទទូចហើយទទូចទៀតថា ខ្លួននឹងបន្តដំណើរការតុលាការទៅមុខតទៅទៀត ទោះបីជាមាន ឬគ្មានការចូលរួមពីសំណាក់អង្គការសហប្រជាជាតិក៏ដោយចុះ ។ រដ្ឋាភិបាលកម្ពុជាប្រាកដជាអាចធ្វើដូច្នេះបាន ហើយអាចប្រើឲ្យអស់លទ្ធភាពនូវព័ត៌មានដែលប្រមូលបានពីស្ថាប័ននានាជាច្រើន ។ ការដែលតុលាការកម្ពុជា មិនអាចធ្វើទៅតាមការរំពឹងទុករបស់អន្តរជាតិនោះគឺមិនមែនស្ថិតត្រង់បញ្ហាខ្វះភ័ស្តុតាងនោះទេ ។

នៅក្នុងរយៈពេល២៥ឆ្នាំ ចាប់តាំងពីមានរបបពិឃាតរបស់ខ្មែរក្រហមមក អំពើប្រល័យពូជសាសន៍នៅកម្ពុជាត្រូវបាននិងកំពុងរំឭកតាមរយៈការដាក់តាំងពិព័រណ៍នៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងដែលស្ថិតនៅទីក្រុងភ្នំពេញ និងការតុបតែងលម្អរបូជនីយដ្ឋាននៅជើងឯក ។ ក្រៅពីបូជនីយដ្ឋានជាតិទាំងនេះ ប្រជាជនកម្ពុជាបានកសាងនូវចេតិយតូចៗរាប់ពាន់កន្លែង ទាំងជាសាធារណៈ ទាំងជាលក្ខណៈឯកជន សម្រាប់ជាទីសក្ការៈបូជា និងឧទ្ទិសដល់ព្រលឹងអ្នកដែលបានលាចាកលោកទៅដោយស្នាដៃខ្មែរក្រហម ។ រូបគំនូរដែលចេញពីទឹកដៃរបស់ វ៉ាន់ ណាត ដែលជាជនរងគ្រោះម្នាក់ក្នុងចំណោមជនរងគ្រោះដទៃទៀតដែលបានរស់រានមានជីវិតពីទួលស្លែង, ខ្សែភាពយន្តរបស់លោក ឬទ្ធី ប៉ាន់, កិច្ចការសម្រេចដោយលោក ឌិត ប្រន, សំណេររបស់ អ៊ឹង លួង, ហ៊ីម ច័ន្ទបុទ្ធី, ខូវ៉ដាល លីនដា និង ហ៊ីហៀល អាដាម (និងអ្នកផ្សេងទៀត) សកម្មភាពនិយមរបស់អ្នកគួរគោរព និងអប់រំអាន ឈន ។ អ្វីដែលគេមិនសូវរំឭកដល់ ប៉ុន្តែមិនមែនមិនសំខាន់នៅសហរដ្ឋអាមេរិក នោះគឺអ្នកទោសជនជាតិអាមេរិកកាំងដើមកំណើតខ្មែរដែលខិតខំស្វែងរកវិធីនានាដើម្បីដឹងអំពីប្រវត្តិសាស្ត្រប្រកបដោយសោកនាដកម្មដែលកើតឡើងនៅលើប្រទេសខ្លួន នៅក្នុងខណៈខ្លួនកំពុងតែជាប់ឃុំឃាំង និងជាសិស្សនិស្សិតនៅតាមវិទ្យាល័យនិងមហាវិទ្យាល័យនៅពេលដែលមានការជម្លៀសប្រជាជនកម្ពុជា ស្វែងរកឯកសារដើម្បីសរសេរនិក្ខេបបទសម្រាប់ឆមាសទាក់ទងនឹងព្រឹត្តិការណ៍ដែលឪពុកម្តាយខ្លួនស្ទាក់ស្ទើរមិនហ៊ាននិយាយចេញមក ។ ទោះបីជាមាន ឬមិនមានតុលាការអន្តរជាតិក៏ដោយ ក៏សកម្មភាពទាំងអស់នេះគឺជាទង្វើដែលមានបំណងរកយុត្តិធម៌ជូនដល់ព្រលឹងរបស់អ្នកដែលបានលាចាកលោកយើងនេះ ដោយសារសោកនាដកម្មសម័យខ្មែរក្រហម ។

ប្រសិនបើពិភពលោកយើងនេះមានយុត្តិធម៌ជាងសព្វថ្ងៃ ម៉េះសមចារីដែលប្រព្រឹត្តអំពើប្រល័យពូជសាសន៍ត្រូវបាននាំខ្លួនមកកាត់ទោសចំពោះមុខតុលាការតាំងពីយូរយារណាស់មកហើយ ហើយចារីទាំងនោះនឹងទទួលនូវសាលក្រមដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរឲ្យសមទៅនឹងទង្វើរបស់ខ្លួន ។ ព័ត៌មានដែលទទួលបានពីអង្គការនានានៅជុំវិញពិភពលោក គួរតែត្រូវបានប្រមូលផ្តុំរួមគ្នាជាមួយក្រុម គ្រួសារជនរងគ្រោះតាំងពីដើមម៉េះ ដើម្បីឆ្លើយតបទៅនឹងសំណួរនិងជួយសម្រួលដល់ក្តីទុក្ខព្រួយរបស់ជនរងគ្រោះទាំងអស់នោះ ។

ប្រជាជនកម្ពុជាជាច្រើនសង្ឃឹមថា តុលាការអន្តរជាតិមួយនឹងមិនត្រឹមតែកាត់សេចក្តីទៅលើឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយខ្មែរក្រហមទេ ប៉ុន្តែថែមទាំងកាត់សេចក្តីទៅលើការរំលោភសិទ្ធិមនុស្សដែលកើតឡើងនៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំថ្មីៗកន្លងទៅនេះ ។ ប្រជាជនកម្ពុជាប្រាកដជានឹងមានអារម្មណ៍មិនពេញចិត្ត ចំពោះដំណើរការកាត់ក្តីដែលមានការបង្ខិតបង្ខំនិងមានលក្ខណៈជានយោបាយ ដូចជាអារម្មណ៍របស់អង្គការអន្តរជាតិដែលមានកន្លងមកនេះដែរ ។ អំពើប្រល័យពូជសាសន៍ត្រូវបានប្រព្រឹត្តឡើងនៅក្នុងប្រទេសកម្ពុជា ចំណែកឯ "យុត្តិធម៌" ចេញពីតុលាការដែលអនុម័តតែទៅលើអង្គច្បាប់ ហាក់ដូចជានៅឆ្ងាយនៅឡើយ ។ ប៉ុន្តែការពិត និងការចងចាំនៅតែមានជារៀងរហូត បើមិនមាននៅក្នុងកិច្ចខិតខំប្រឹងប្រែងដែលរៀបចំឡើងដោយរដ្ឋាភិបាលនិងអង្គការនានារបស់សហគមន៍អន្តរជាតិ ក៏វាស្ថិតនៅក្នុងការសម្តែងមនោសញ្ចេតនា ក្នុងជីវភាពរស់នៅជារៀងរាល់ថ្ងៃ និងការផ្តួចផ្តើមគំនិតរបស់ប្រជាជនកម្ពុជា និងក្រៅពីប្រជាជនកម្ពុជានៅជុំវិញពិភពលោកដែរ ។ ខ្ញុំជឿជាក់ថា អ្នកទាំងនេះនឹងសម្រេចបាននូវអ្វីដែលមេដឹកនាំពិភពលោកមួយចំនួនមិនអាចធ្វើបាន ។ នេះជាមធ្យោបាយស្វែងរកសេចក្តីស្ងប់ស្ងៀមក្នុងចិត្ត និងការបញ្ចប់នូវខបកថាដែលនឹងបន្តតាមលងយើងរាល់គ្នាដែលគ្មានទីបញ្ចប់នោះ ។

**ស៊ុំសាន យុក**

# ការទន្ទឹងរង់ចាំយុត្តិធម៌នៅកម្ពុជាអាចនឹងត្រូវខកចិត្ត

កាលពីថ្ងៃទី៨ ខែកុម្ភៈ កន្លងទៅថ្មីៗនេះ ក្រោយពីអង្គការសហប្រជាជាតិបានសម្រេចចិត្តដកថយពីការចរចាជាមួយរាជរដ្ឋាភិបាលកម្ពុជាអំពីការបង្កើតអ្វីដែលហៅថា “តុលាការចម្រុះ” ក្នុងគោលបំណងកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យបានធ្វើឲ្យពិភពលោកមានការភ្ញាក់ផ្អើលជាខ្លាំង ហើយបានបញ្ចេញនូវប្រតិកម្មផ្សេងៗគ្នា ។ មានមតិខ្លះបានបន្ទោសដល់អង្គការសហប្រជាជាតិថាខ្វះឆន្ទៈក្នុងការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះកម្ពុជាប្រឆាំងនឹងឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងចន្លោះឆ្នាំ១៩៧៥-១៩៧៩ ដែលដឹកនាំដោយមេដឹកនាំកុម្មុយនិស្តផ្ដាច់ការខ្មែរក្រហម ។ មានមតិខ្លះទៀតបានបន្ទោសដល់រាជរដ្ឋាភិបាលកម្ពុជាថា ក្រោយហេតុការណ៍នេះកើតឡើងរួចមក រដ្ឋាភិបាលកម្ពុជាយល់ឃើញថាខ្លួនឯងមានបញ្ហាជាមួយគំនិតបង្កើតតុលាការ ហើយនៅពេលដែលអង្គការសហប្រជាជាតិបន្តធ្វើការជាមួយក្នុងឆន្ទៈល្អដើម្បីរកយុត្តិធម៌ឲ្យប្រជាជនកម្ពុជា រដ្ឋាភិបាលកម្ពុជា ក៏ចាប់ផ្ដើមចរចាយ៉ាងគំហុក ដើម្បីបញ្ចៀសកុំឲ្យមានតុលាការដែលអាចកើតមានឡើងនៅពេលខាងមុខ ដែលខ្លួនលែងត្រូវការប្រើប្រាស់ និងដែលខ្លួនមិនអាចគ្រប់គ្រងបាន ។

ចំពោះជនរងគ្រោះកម្ពុជាជាច្រើនដែលធ្លាប់បានឆ្លងកាត់ការឈឺចាប់ដោយសាររបបនេះ បានបញ្ចេញទស្សនៈថា “មើលទៅទាល់តែមេខ្មែរក្រហមស្លាប់អស់ ទើបបានមានតុលាការ” ។ ការពោលដូច្នេះគឺដោយសារតែការអស់សង្ឃឹមនឹងការរង់ចាំយុត្តិធម៌ដែលមានរយៈពេល២៣ឆ្នាំមកហើយ ។ មតិខ្លះបានប៉ាន់ប្រមាណថា “តុលាការនេះនឹងមិនអាចធ្វើទៅបានទេ ប្រសិនបើគ្មានការចូលរួមពីអង្គការសហប្រជាជាតិ” ហើយបញ្ជាក់ថា “ទោះបីជារាជរដ្ឋាភិបាលកម្ពុជាអាចធ្វើទៅបានដោយខ្លួនឯងក៏ដោយ ក៏តុលាការនោះនឹងមិនផ្ដល់នូវភាពយុត្តិធម៌ពេញលេញដែរ” ។ “យុត្តិធម៌”នៅពេលនេះគឺសំដៅទៅរកយុត្តិធម៌មួយពិតប្រាកដសម្រាប់ប្រជាជនកម្ពុជាដែលភាគច្រើនគឺជាជនរងគ្រោះនៃរបបសម្លាប់រង្គាលព្រៃផ្សៃនេះ និងដែលអាចទទួលយកបាន ។ ការអះអាងខាងលើនេះសំដៅទៅរកហេតុផលនយោបាយនៃរដ្ឋាភិបាលដែលកំពុងគ្រប់គ្រងអំណាចនិងអសមត្ថភាពនៅក្នុងប្រព័ន្ធតុលាការកម្ពុជាសព្វថ្ងៃ ។ ប៉ុន្តែការព្រួយបារម្ភដ៏ខ្លាំងបំផុតរបស់ជនរងគ្រោះកម្ពុជានោះ គឺថាមិនដឹងជាត្រូវរង់ចាំដល់ពេលណាទើបមានយុត្តិធម៌ពិតប្រាកដសម្រាប់ជនរងគ្រោះកម្ពុជាក្រោមរបបខ្មែរក្រហម ឬមួយត្រូវរង់ចាំរហូតដល់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមស្លាប់អស់ឬមួយយ៉ាងណា?

បញ្ហានេះបានទាញការចាប់អារម្មណ៍របស់ខ្ញុំឲ្យមានការគិតគូរទៅដល់ការព្រួយបារម្ភចំពោះវ័យចំណាស់របស់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលនៅសេសសល់ ហើយដែលកំពុងរស់នៅប្រកបដោយសេរីភាពនិងភាពគ្មានទោសជាមួយជនរងគ្រោះ ។ ទមិឡមួយក្ដាប់តូចនេះបានដឹកនាំប្រទេស បណ្ដាលឲ្យប្រជាជនកម្ពុជាស្លូតត្រង់ឲ្យស្លាប់អស់ជាងមួយលាននាក់ដោយសារការបង្ខំឲ្យធ្វើការហួសកម្លាំង ការបង្អត់អាហារ ការមិនគិតគូរពីសុខភាពរបស់ប្រជាជន ការចាប់ប្រជាជនធ្វើទារុណកម្មនិងការសម្លាប់ចោលគ្មានញញើតដៃដោយចោទថាខ្មាំង “ក្បត់បដិវត្តន៍” ។

ការព្រួយបារម្ភម្យ៉ាងទៀតគឺមិនដឹងថាមុនពេលមានតុលាការនេះបង្កើតឡើង តើមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហមប៉ុន្មាននាក់នឹងមិនទាន់ស្លាប់ ហើយនឹងត្រូវបាននាំយកទៅវិនិច្ឆ័យទោស ។ រហូតមកដល់ពេលនេះ ក្នុងចំណោមមេដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហមដែលនៅរស់ក្រោយឆ្នាំ១៩៧៩ មានមួយចំនួនបានស្លាប់ជាបណ្ដើរៗទៅហើយ ។

កន្លងមកដូចយើងឃើញស្រាប់ហើយ សុន សេន ហៅ ខៀវ ឬ បង៨៩ អតីតសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការបក្សកុម្មុយនិស្តកម្ពុជា និងគណៈកម្មាធិការអចិន្ត្រៃយ៍ និងជា

រដ្ឋមន្ត្រីសន្តិសុខជាតិ ព្រមទាំងប្រពន្ធឈ្មោះ យុន យ៉ាត ហៅ អាត អតីតរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌ និងពត៌មានក្នុងរបប ខ្មែរក្រហមនិងសមាជិកក្រុមគ្រួសារ ត្រូវបាន ប៉ុល ពត បញ្ជាឲ្យ កូនទាហានសម្លាប់ចោលនៅតំបន់ចុងក្រោយបង្អស់របស់ពួក ខុទ្ទាមខ្មែរក្រហមនៅអន្លង់វែង ក្នុងខែមិថុនា ឆ្នាំ១៩៩៧ ។ មូលហេតុនៃការសម្លាប់ក្រុមគ្រួសារ សុន សេន គឺដោយសារ ប៉ុល ពត ចោទប្រកាន់ថា សុន សេន ជាខ្នាំងបង្កប់របស់របប ក្រុងភ្នំពេញ ។

ក្រោយមកទៀត នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨ ប៉ុល ពត បានស្លាប់ ។ ប៉ុល ពត ស្លាប់នៅពេលដែលខ្លួនកំពុងតែ រត់គេចពីសំណាញ់យុត្តិធម៌អន្តរជាតិ ។ ប៉ុន្តែ ប៉ុល ពត បាន រស់នៅក្នុងរយៈពេលមួយគ្រប់គ្រាន់រហូតដល់ទីបញ្ចប់បាន ឃើញការស្រមើស្រមៃរបស់ខ្លួនរលំរលាយដោយជាក់ច្បាស់ ។ ប៉ុល ពត ស្លាប់ទៅក្នុងខណៈដែលចលនាកម្ពុជាប្រជាធិបតេយ្យ ស្ថិតនៅក្នុងភាពខ្សោយបំផុតក្នុងរយៈពេល៣០ឆ្នាំនេះ ដោយ មានទាហានពីររឬបីនាក់ និងទឹកដីកាន់កាប់តែមួយក្រវេចតូច ប៉ុណ្ណោះ ។ ប៉ុល ពត បានស្លាប់នៅចំពោះមុខគណបក្សប្រជាជន ដែលជាសត្រូវស្លូរពូជរបស់ខ្លួន ដែលមានកម្លាំងខ្លាំងជាងពេល ណាៗទាំងអស់ ។ ប៉ុល ពត បានស្លាប់ទៅដោយមានអ្នកក្បត់ ស្ទើរតែទាំងអស់ រួមទាំងអ្នកដែលខ្លួនធ្លាប់មានការសង្ស័យជា យូរមកហើយ និងអ្នកដែលខ្លួនទុកចិត្តបំផុតទៀតផង ។

នៅថ្ងៃទី១៥ ខែកុម្ភៈ កន្លងទៅថ្មីៗនេះទៀត កែ ពក អតីត លេខាភូមិភាគឧត្តរ ឬភូមិភាគកណ្តាល ដែលល្បីឈ្មោះក្នុងការ សម្លាប់មនុស្សនៅខេត្តកំពង់ចាម បានស្លាប់ដោយមិនទាន់ត្រូវ បាននាំយកមកវិនិច្ឆ័យទោសទាល់តែសោះ ។ កែ ពក ស្លាប់នៅ អន្លង់វែងដោយសារជំងឺថ្លើម ។ ការស្លាប់នេះក៏បណ្តាលមកពី ការដាច់សរសៃឈាមក្នុងខួរក្បាលដែរ បន្ទាប់ពីគាត់បានត្រឡប់ មកពីព្យាបាលនៅមន្ទីរពេទ្យមួយកន្លែងក្នុងខេត្តសុរិន្ទ ប្រទេស ថៃ ។

បច្ចុប្បន្ននេះ កាំង ហ្កិច អៀវ ហៅ ឌុច អតីតប្រធានមន្ទីរ ស-២១ (គុកទួលស្លែង) កំពុងតែជាប់ឃុំ ហើយជិតដល់ថ្ងៃដោះ លែងនៅក្រោយឃុំតាមច្បាប់កំណត់ ។ ចំណែកឯ តាម៉ុក អតីត លេខាភូមិភាគនិរតីដែលល្បីឈ្មោះខាងការសម្លាប់មនុស្សដែរ នោះ ក៏ត្រូវបានចាប់ខ្លួន និងឃុំខ្លួនពីបទប្រល័យពូជសាសន៍ ហើយរង់ចាំតែការបង្កើតតុលាការមួយដែលមានការទទួល ស្គាល់ជាលក្ខណៈអន្តរជាតិ ដើម្បីវិនិច្ឆ័យទោសនោះ មកដល់ ពេលនេះ ហួសរយៈកាលឃុំខ្លួនដែលកំណត់ក្នុងច្បាប់ ដោយសារ តែភាពយឺតយ៉ាវនៃដំណើរការបង្កើតតុលាការខ្មែរក្រហមនេះ ។

រីឯមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដទៃទៀតដូចជា នួន ជា ខៀវ សំផន អៀង សារី និងប្រពន្ធឈ្មោះ អៀង ធីរិទ្ធ បែរជា កំពុងតែរស់នៅដោយមានសេរីភាពនិងភាពរួចទោសនៅលើគំនរ ទុក្ខវេទនារបស់ជនរងគ្រោះកម្ពុជារាប់លាននាក់ទៅវិញ ។ តើ ភាពខុសគ្នារវាងមេដឹកនាំខ្មែរក្រហមទាំងនេះស្ថិតនៅត្រង់ណា? ហើយតើជនរងគ្រោះកម្ពុជាទាំងអស់សុខចិត្តរស់នៅជាមួយនឹង មេពេជ្ឈឃាតបាតដៃប្រឡាក់ឈាមដោយរបៀបនេះដែរឬទេ?

ដើម្បីយុត្តិធម៌ ដែលអាចទទួលយកបាន សម្រាប់ជន រងគ្រោះនៃរបបវាលពិឃាតនេះ អង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា ត្រូវតែបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការ ស្វែងរកដំណោះស្រាយជាផ្លូវការថ្មីមួយទៀតឲ្យបានឆាប់តាម



ពៅ ឆ្នាំ១៩៧៧
ឆ្នាំគុកទួលស្លែង

ដែលអាចធ្វើទៅបាន ពីព្រោះពេលវេលានៃការពិភាក្សាដើម្បីសម្របសម្រួលស្តីអំពីការបង្កើតតុលាការនេះបានអូសបន្លាយយូរមកហើយ ។ តើល្មមដល់ពេលឈានមកដល់ចំណុចឯកភាពគ្នាបានទេ ឬត្រូវរង់ចាំរហូតដល់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមស្លាប់អស់ឬយ៉ាងណា? បញ្ហាស្វែងរកដំណោះស្រាយនេះពិតជាអាចធ្វើទៅបាន ប្រសិនបើការពិភាក្សាអំពីការបង្កើតតុលាការសម្រាប់វិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យមិនមានពាក់ព័ន្ធនឹងបញ្ហានយោបាយផ្ទាល់ខ្លួនណាមួយនោះ ហើយលើកយកបញ្ហាច្បាប់មកធ្វើជាអត្ថិភាពជាងបញ្ហាផ្សេងៗដទៃទៀត ។

ការស្លាប់ជាបន្តបន្ទាប់នៃមេដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហមនេះ គឺជាបច្ច័យមួយដ៏អាក្រក់សម្រាប់ជនរងគ្រោះនៅក្រោមរបបខ្មែរក្រហម ហើយអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលនៅរស់ទាំងនោះអាចនឹងត្រូវស្លាប់អស់ទៀតដោយសារតែការខកខានមិនបាននាំយកមកវិនិច្ឆ័យទោសឲ្យបានទាន់ពេលវេលា ។ លទ្ធផលនេះនឹងបន្សល់ទុកឲ្យជនរងគ្រោះកម្ពុជាទាំងមូលនូវការឈឺចាប់ដែលគ្មានការតបស្នងរាប់រយគំណ និងការមន្ទិលសង្ស័យមិនចេះចប់មិនចេះហើយ ពីព្រោះតែស្រមោលអតីតកាលដ៏ខ្មៅងងឹតមិនទាន់ត្រូវបានជម្រះឲ្យជ្រះស្រឡះ ។

ដរាបណានៅតែគ្មានសញ្ញាណណាមួយបញ្ជាក់ថា តុលាការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមត្រូវបានបង្កើតឡើង ហើយយុត្តិធម៌ពិតប្រាកដត្រូវបានធានាឲ្យបានទាន់ពេលវេលាទេនោះ កម្ពុជានឹងនៅតែជាចំណាប់ខ្មាំងនៃប្រវត្តិសាស្ត្ររបស់របបខ្មែរក្រហមជារៀងរហូត ។

យើងទាំងអស់គ្នាដែលជាជនរងគ្រោះនៃប្រវត្តិសាស្ត្រពិភពលោក ការស្វែងរកយុត្តិធម៌គឺជាកាតព្វកិច្ចរបស់យើងម្នាក់ៗ ។ ខ្ញុំក៏ដូចជាជនរងគ្រោះនៃរបបខ្មែរក្រហមទាំងអស់គ្នាសង្ឃឹមថា អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជានឹងមិនបណ្តែតបណ្តោយឲ្យប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតនេះបន្តគ្របដណ្តប់លើជនរងគ្រោះកម្ពុជាដែលជាផ្នែកមួយនៃប្រវត្តិសាស្ត្រពិភពលោកឡើយ ។ ប្រសិនបើប្រការនេះនឹងក្លាយជាការពិត តើនរណាជាអ្នកទទួលខុសត្រូវក្នុងការធ្វើឲ្យការទន្ទឹងរង់ចាំយុត្តិធម៌ពិតប្រាកមួយដែលជាថ្នូរនៃតម្លៃតបស្នងចំពោះការឈឺចាប់របស់ជនរងគ្រោះកម្ពុជាត្រូវខកចិត្តនោះ? **ថ្លូង សុភារិទ្ធ**



ពៅ ឆ្នាំ១៩៩៩
កសិករនៅខេត្តកំពង់ឆ្នាំង

# កាលប្បវត្តិ៖
# ប្រវត្តិនៃការចរចារវាងអង្គការសហប្រជាជាតិ ជាមួយកម្ពុជាស្តីអំពីបញ្ហាបង្កើតតុលាការ កាត់ទោសមេដឹកនាំខ្មែរក្រហម

(រៀបរៀងដោយការិយាល័យទទួលបន្ទុកកិច្ចការច្បាប់អង្គការសហប្រជាជាតិ ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០២)

## ដំណាក់កាលទី១
## សំណើពីសហនាយករដ្ឋមន្ត្រី សម្តេច ហ៊ុន សែន និង សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ

***ថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧***

លិខិតរួមមួយរបស់សហនាយករដ្ឋមន្ត្រីកម្ពុជាផ្ញើជូនចំពោះលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ស្នើសុំជំនួយឧបត្ថម្ភពីសំណាក់អង្គការសហប្រជាជាតិក្នុងការវិនិច្ឆ័យទោសមេដឹកនាំទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនៃអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងរបបខ្មែរក្រហមក្នុងអំឡុងឆ្នាំ១៩៧៥-៧៩ ។

***ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៧***

តាមរយៈលិខិតចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៧ លោកអគ្គលេខាធិការបានផ្ញើលិខិតរបស់សហនាយករដ្ឋមន្ត្រីកម្ពុជាទៅលោកប្រធានមហាសន្និបាតអង្គការសហប្រជាជាតិនិងក្រុមប្រឹក្សាសន្តិសុខ(A/៥១/៩៣០-S/១៩៩៧/៤៨៨ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩៧) ។ គ្មានចំណាត់ការអ្វីពីសំណាក់អង្គការទាំងនេះឡើយ ។

***ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៩៨***

យោងតាមសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ៥២/១៣៥ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៩៧ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិតែងតាំងក្រុមអ្នកជំនាញការមួយក្រុមមានសមាជិក៣រូប ឲ្យទៅកាន់ប្រទេសកម្ពុជា ដើម្បីវាយតម្លៃភ័ស្តុតាងដែលមានស្រាប់ វាយតម្លៃលើលទ្ធភាពក្នុងការនាំយកមេដឹកនាំខ្មែរក្រហមមកវិនិច្ឆ័យទោស និងរិះរកវិធីនានាក្នុងការវិនិច្ឆ័យទោសមេដឹកនាំខ្មែរក្រហមនៅចំពោះមុខសមត្ថកិច្ចអន្តរជាតិឬសមត្ថកិច្ចជាតិ (A/៥២/១០០៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៨) ។

***ថ្ងៃទី១៤ដល់ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨***

ក្រុមអ្នកជំនាញការមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា និងប្រទេសថៃ ។

***ថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩***

យោងតាមសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ៥២/១៣៥ របាយការណ៍របស់ក្រុមអ្នកជំនាញការត្រូវបានដាក់ជូនក្រុមប្រឹក្សាសន្តិសុខនិងមហាសន្និបាតអង្គការសហប្រជាជាតិ ។ នៅក្នុងរបាយការណ៍នេះ ក្រុមអ្នកជំនាញការឲ្យយោបល់សូមឲ្យបង្កើតនូវតុលាការអន្តរជាតិ ដើម្បី

កាត់សេចក្តីមេដឹកនាំខ្មែរក្រហមពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនិងអំពើប្រល័យពូជសាសន៍ដែលបានប្រព្រឹត្តឡើងចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ (A/៥៣/៨៥០-S/១៩៩៩/២៣/១) ។

## ដំណាក់កាលទី២
## សំណើរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន គំនិតនេះត្រូវបានផ្លាស់ប្តូរវិញ

### ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩

សំណើពីសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន សូមឲ្យអង្គការសហប្រជាជាតិផ្តល់នូវអ្នកជំនាញការមកជួយកម្ពុជាក្នុងការធ្វើសេចក្តីព្រាងច្បាប់ដែលអនុញ្ញាតឲ្យមានចៅក្រមនិងព្រះរាជអាជ្ញាបរទេសចូលរួមនៅក្នុងដំណើរការជម្រះក្តី ។

### ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៩៩

នៅក្នុងជំនួបជាមួយតំណាងអចិន្ត្រៃយ៍កម្ពុជា ការិយាល័យទទួលបន្ទុកកិច្ចការច្បាប់ប្រគល់សំណើជូនអង្គការសហប្រជាជាតិស្តីអំពីការបង្កើតតុលាការចម្រុះមួយ ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ។ (កំណត់សម្គាល់ស្តីពីធាតុផ្សំនានារបស់តុលាការចម្រុះក៏ត្រូវបានប្រគល់ជូនដែរ) ។

### ថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

ក្នុងការឆ្លើយតបទៅនឹងកំណត់សម្គាល់ចុះថ្ងៃទី២៩ ខែកក្កដា កម្ពុជាបញ្ជាក់សាជាថ្មីអំពីជំហររបស់ខ្លួនដែលចង់បានតុលាការជាតិដែលមានស្រាប់ ដោយស្វាគមន៍ចំពោះជំនួយឧបត្ថម្ភរបស់អ្នកជំនាញការច្បាប់មកពីបរទេស ហើយបញ្ជាក់ជាថ្មីនូវការស្នើសុំជំនួយការក្នុងការធ្វើសេចក្តីព្រាងច្បាប់ និងការបញ្ជូនចៅក្រមនិងព្រះរាជអាជ្ញាបរទេសផង ។

### ថ្ងៃទី២៦ ខែសីហា ដល់ថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៩៩

បេសកកម្មលើកទី១របស់អង្គការសហប្រជាជាតិមកកាន់ប្រទេសកម្ពុជា ដើម្បីចរចាអំពីបញ្ហាច្បាប់និងបញ្ហាជាក់ស្តែងមួយចំនួនក្នុងការបង្កើតតុលាការចម្រុះក្រោមច្បាប់កម្ពុជា ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ។ គំរូតុលាការចម្រុះដែលស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិត្រូវបានស្នើឡើង ហើយការឲ្យយោបល់ផ្សេងៗទៅលើសេចក្តីព្រាងច្បាប់ត្រូវបានដាក់ជូនពិនិត្យ ។

### ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៩៩

នៅក្នុងឯកសារជំនួយស្មារតីមួយច្បាប់ផ្ញើជូនលោកអគ្គលេខាអង្គការសហប្រជាជាតិ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បញ្ជាក់ច្បាស់អំពី ជម្រើសបីយ៉ាងសម្រាប់ការចូលរួមរបស់អង្គការសហប្រជាជាតិនៅក្នុងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

ជម្រើសទី១ៈ ផ្តល់នូវក្រុមអ្នកច្បាប់ និងចូលរួមក្នុងសាលាក្តីដែលរៀបចំឡើងនៅក្នុងតុលាការកម្ពុជាដែលមានស្រាប់ ។

ជម្រើសទី២ៈ ផ្តល់នូវក្រុមអ្នកច្បាប់ដែរ ប៉ុន្តែមិនអាចចូលរួមនៅក្នុងតុលាការ ។

ជម្រើសទី៣ៈ មិនចូលរួមក្នុងតុលាការដែលស្នើឡើងនេះតែម្តង ។

### ថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៩

សេចក្តីព្រាងច្បាប់ស្តីអំពី«ការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ»ត្រូវបានតំណាងអចិន្ត្រៃយ៍កម្ពុជាដាក់ជូនការិយាល័យទទួលបន្ទុកកិច្ចការច្បាប់អង្គការសហប្រជាជាតិជាមួយនឹងកំណត់សម្គាល់មួយថា សេចក្តីព្រាងច្បាប់នេះនឹងដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យអនុម័តនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ។

### ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៩៩

នៅក្នុងលិខិតចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៩៩ លោកទីប្រឹក្សាច្បាប់ ហេន កូរេល សម្តែងនូវការព្រួយបារម្ភទៅលើ "៩" សំខាន់ៗមួយចំនួននៅក្នុងសេចក្តីព្រាងច្បាប់ដែលទាក់ទងជាពិសេសទៅនឹងសមាសភាពក្នុងការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ អយ្យការនិងតួនាទីរបស់ចៅក្រមស៊ើបអង្កេត និងបញ្ហានៃការផ្តល់ថវិកា ។

### ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៩

សេចក្តីព្រាងច្បាប់ស្តីអំពី«ការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ»ត្រូវបានផ្ញើជូនការិយាល័យទទួលបន្ទុកផ្នែកច្បាប់អង្គការសហប្រជា-

ជាតិ ជាមួយនឹងកំណត់សម្គាល់បញ្ជាក់ថា សេចក្តីព្រាងច្បាប់នេះនឹងត្រូវដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រីពិនិត្យជាលើកទីពីរនិងជាលើកចុងក្រោយនៅថ្ងៃទី៦ ខែមករា ឆ្នាំ២០០០ ។

### ថ្ងៃទី៤ ខែមករា ឆ្នាំ២០០០

នៅក្នុងលិខិតផ្ញើជូនតំណាងបេសកកម្មអចិន្ត្រៃយ៍នៅកម្ពុជា លោក កូរេល បានសូមឲ្យលោកតំណាងបេសកកម្មអចិន្ត្រៃយ៍ជម្រាបដល់រដ្ឋាភិបាលរបស់លោកអំពីការព្រួយបារម្ភមួយចំនួនរបស់អង្គការសហប្រជាជាតិ ។

### ថ្ងៃទី១៨ ខែមករា ឆ្នាំ២០០០

សេចក្តីព្រាងច្បាប់ដែលពិនិត្យមួយដងទៀតរួចហើយ ត្រូវបានដាក់ជូនលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ (ការវិភាគមួយទៅលើអត្ថបទច្បាប់នេះបង្ហាញថា អត្ថបទច្បាប់ថ្មីនេះមិនបានដោះស្រាយចំណុចដែលលើកឡើងនៅក្នុង Non-Paper ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០០០ឡើយ) ។

### ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០០

នៅក្នុងលិខិតមួយរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិជូនចំពោះសម្តេច ហ៊ុន សែន មានលើកឡើងនូវចំណុច៤សំខាន់ៗៈ ការធានាការចាប់ខ្លួននិងការចូលខ្លួនរបស់ជនជាប់ចោទ ការសម្រាលទោសនិងការលើកលែងទោស, ការតែងតាំងព្រះរាជអាជ្ញាអន្តរជាតិនិងមានឯករាជ្យ និងឲ្យមានចៅក្រមអន្តរជាតិច្រើនជាងខ្មែរ ។

### ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០០

នៅក្នុងសំបុត្រផ្ញើជូនលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន មិនបានស្វាគមន៍ចំពោះគម្លាតនៃជំហររវាងអង្គការសហប្រជាជាតិនិងកម្ពុជាទេ ជាពិសេសជំហររបស់រដ្ឋជាសមាជិក(របស់អង្គការសហប្រជាជាតិ) ។

### ថ្ងៃទី១៦ ដល់ថ្ងៃទី២២ ខែមីនា ឆ្នាំ២០០០

បេសកកម្មលើកទី២របស់អង្គការសហប្រជាជាតិធ្វើដំណើរមកដល់ប្រទេសកម្ពុជា ដើម្បីបញ្ចប់ការពិភាក្សាទៅលើសេចក្តីព្រាងច្បាប់ស្តីអំពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា និងបញ្ចប់ការពិភាក្សាទៅលើកិច្ចសហប្រតិបត្តិការរបស់អង្គការសហប្រជាជាតិ ក្នុងការបង្កើតនិងដំណើរការអង្គជំនុំជម្រះវិសាមញ្ញទាំងមូល ។

### ថ្ងៃទី២១ ខែមីនា ឆ្នាំ២០០០

ការផ្លាស់ប្តូរលិខិតទៅវិញទៅមករវាងលោក ហេន កូរេល ជាមួយនឹងឯកឧត្តម សុខ អាន ទៅលើបញ្ហានៃការលើកលែងទោស បញ្ហាសហព្រះរាជអាជ្ញា និងអំណាចរបស់អ្នកទាំងនោះក្នុងការបំពេញការងារដោយឯករាជ្យ ក្នុងករណីមានភាពមិនចុះសម្រុងចំណុចណាមួយ ។ បញ្ហាយន្តការដោះស្រាយវិវាទមិនទាន់សម្រេចនៅឡើយទេ ។

### ថ្ងៃទី៨ ខែមេសា ឆ្នាំ២០០០

ការៈធារីអមស្ថានទូតខ្មែរជូនលិខិតមួយច្បាប់របស់ឯឧត្តម សុខ អាន ដែលទាក់ទងនឹង«ការមិនចុះសម្រុងគ្នាទៅលើជម្រើសផ្សេងៗគ្នាទាក់ទងនឹងសហព្រះរាជអាជ្ញា» ។ (ជម្រើស៦ត្រូវបានលើកឡើង) ។

### ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០០

សំបុត្ររបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិជូនចំពោះសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ។ ក្នុងខ្លឹមសារសំបុត្រនោះ លោកអគ្គលេខាធិការមានយោបល់មួយចំនួនទាក់ទងនឹងជម្រើសដែលលើកឡើងដោយសម្តេច ហ៊ុន សែន ហើយដាក់ជូននូវសំណើមួយរបស់អង្គការសហប្រជាជាតិស្តីអំពីយន្តការមុនពេលជម្រះក្តីដើម្បីដោះស្រាយរាល់វិវាទរវាងសហព្រះរាជអាជ្ញានិងសហចៅក្រមស៊ើបអង្កេត ។

### ថ្ងៃទី២២ ខែមេសា ឆ្នាំ២០០០

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ឆ្លើយតបទៅនឹងលិខិតរបស់លោកអគ្គលេខាធិការចុះថ្ងៃទី១៩ ខែមេសា ដែលក្នុងខ្លឹមសារលិខិតនោះ សម្តេចមានប្រសាសន៍ថា មុនពេលច្បាប់នេះត្រូវបានអនុម័តមិនអាចមានការផ្លាស់ប្តូរលិខិតទៅវិញទៅមករវាងអង្គការសហប្រជាជាតិនិងកម្ពុជាបានទេ ។ សម្តេចនាយករដ្ឋមន្ត្រីស្នើឲ្យមានរូបមន្តបង្កើត«អង្គជំនុំជម្រះវិសាមញ្ញ»ដើម្បីដោះស្រាយការខ្វែងគំនិតគ្នារវាងសហព្រះរាជអាជ្ញា ។

### ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០០

លិខិតទីពីររបស់លោកអគ្គលេខាធិការជូនចំពោះសម្តេច ហ៊ុន សែន ជាការឆ្លើយតបទៅនឹងសំបុត្ររបស់សម្តេច ចុះថ្ងៃទី

២២ ខែមេសា ។ លិខិតទីពីរនេះជំរុញឲ្យសម្ដេច ហ៊ុន សែន ទទួលយកសំណើរបស់អង្គការសហប្រជាជាតិ ។

### ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០០

សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ឆ្លើយតបទៅនឹងលិខិតរបស់លោកអគ្គលេខាធិការ ចុះថ្ងៃទី២៥ ខែមេសា ដែលស្នើសុំពង្រីកដែនសមត្ថកិច្ចនៃពេលវេលានៃអង្គជំនុំជម្រះវិសាមញ្ញឲ្យដល់ដើមទសវត្សរ៍ឆ្នាំ១៩៧០ ។

### ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០០

លិខិតរបស់លោកអគ្គលេខាធិការជូនចំពោះសម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលក្នុងខ្លឹមសារសំបុត្រនោះ លោកអគ្គលេខាធិការចង់បានការបញ្ជាក់ឲ្យបានច្បាស់ថា សម្ដេចពិតជាទទួលយកតាមរយៈសមាជិកព្រឹទ្ធសភា ឃើរី នូវសំណើ មួយនៅក្នុងលិខិតរបស់លោកអគ្គលេខាធិការ ចុះថ្ងៃទី១៩ ខែមេសា ទាក់ទងនឹងយន្តការក្នុងការដោះស្រាយរាល់ការខ្វែងគំនិតគ្នារវាងសហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា ហើយចង់បានការបញ្ជាក់ទៀតថា ដែនសមត្ថកិច្ចនៃពេលវេលារបស់អង្គជំនុំជម្រះវិសាមញ្ញគឺពីឆ្នាំ១៩៧៥ដល់១៩៧៩ ។

### ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០០

សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បញ្ជាក់ច្បាស់អំពីការយល់ព្រមរបស់សម្ដេចទៅលើយន្តការក្នុងការដោះស្រាយការខ្វែងគំនិតគ្នារវាងសហព្រះរាជអាជ្ញានិងសហចៅក្រមស៊ើបអង្កេត ។

### ថ្ងៃទី៤ដល់៧ ខែកក្កដា ឆ្នាំ២០០០

ក្រុមបេសកកម្មលើកទីពីររបស់អង្គការសហប្រជាជាតិធ្វើដំណើរមកកម្ពុជា ដើម្បីបញ្ចប់កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាស្ដីអំពីកិច្ចសហប្រតិបត្តិការក្នុងការបង្កើតនិងការប្រព្រឹត្តទៅនៃអង្គជំនុំជម្រះវិសាមញ្ញ ។ នៅថ្ងៃទី៧ ខែកក្កដា ទីប្រឹក្សាច្បាប់បានប្រគល់សេចក្ដីព្រាងនៃអនុស្សរណៈនៃការយោគយល់គ្នាដែលគ្រប់គ្រងកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិនិងកម្ពុជាក្នុងការបង្កើតនិងការប្រព្រឹត្តទៅរបស់តុលាការ និងប្រគល់ច្បាប់ចម្លងស្ដីអំពីច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមដែលកែតម្រូវរួចហើយ ដើម្បីធ្វើឲ្យប្រាកដថាវាស្របគ្នាទៅនឹងអនុស្សរណៈនៃការយោគយល់គ្នា ។

### ថ្ងៃទី៩ ខែមករា ឆ្នាំ២០០១

អត្ថបទបកប្រែក្រៅផ្លូវការនៃច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម ដែលបានអនុម័តដោយរដ្ឋសភានៅថ្ងៃទី២ ខែមករា ឆ្នាំ២០០១ ត្រូវបានទទួលមកពីការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅទីក្រុងភ្នំពេញ ។ នៅក្នុងលិខិតចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០០១ លោក កូរេល លើកឡើងបញ្ហាមួយចំនួនទាក់ទងទៅនឹងមាត្រាមួយចំនួននៃច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម ។

### ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០០១

លោក កូរេល ស្នើសុំអត្ថបទបកប្រែនៃច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមដែលបានអនុម័តរួចហើយ ។

### ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០១

លិខិតមួយច្បាប់ផ្ញើមកពីឯកឧត្ដម សុខ អាន ដែលសម្ដែងការសោកស្ដាយចំពោះការយឺតយ៉ាវក្នុងការសម្រេចជាចុងក្រោយនូវវិសោធនកម្ម“ដែលតម្រូវដោយសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទៅលើច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមដែលត្រូវបានអនុម័តដោយរដ្ឋសភាជាតិ”(សំអាង“ខុស”ដែលថែងថា មានការដាក់ទោសប្រហារជីវិតនៅក្នុងច្បាប់នេះ) ។

### ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០១

នៅក្នុងខ្លឹមសារលិខិតផ្ញើទៅឯកឧត្ដម សុខ អាន លោក កូរេល បញ្ជាក់សាជាថ្មីនូវភាពចាំបាច់ក្នុងការបកប្រែអត្ថបទច្បាប់ជាផ្លូវការ ។ លោក កូរេល ថែមទាំងបានបញ្ជាក់ផងដែរនូវភាពចាំបាច់ក្នុងការធ្វើឲ្យលិខិតូបករណ៍ទាំងពីរមានលក្ខណៈស្របគ្នា ។

### ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០១

ឯកឧត្ដម សុខ អាន ជម្រាបលោក កូរេល ថា ទីស្ដីការគណៈរដ្ឋមន្ត្រីបានពិនិត្យសាឡើងវិញហើយនូវអត្ថបទច្បាប់មាត្រា៣នៃច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម ដើម្បីឲ្យស្របទៅតាមការអនុម័តរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ហើយបន្ថែមថាច្បាប់នេះកំពុងតែត្រូវបានជូនទៅរដ្ឋសភាដើម្បីអនុម័ត ជូនចំពោះព្រឹទ្ធសភាដើម្បីពិនិត្យសាឡើងវិញ និងក្រុមប្រឹក្សាធម្មនុញ្ញដើម្បីពិនិត្យធម្មនុញ្ញភាព និងជាចុងក្រោយជូនទៅប្រមុខរដ្ឋដើម្បី

ប្រកាសឲ្យប្រើប្រាស់ជាផ្លូវការ ។

**ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០១**

នៅក្នុងសំបុត្រជូនចំពោះលោក កូរេល ឯកឧត្តម សុខ អាន សម្តែងការយោគយល់ចំពោះទំនាក់ទំនងរវាងច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមនិងកិច្ចព្រមព្រៀង ។ នៅពេលទទួលយកនូវគោលការណ៍ថា អត្ថបទទាំងពីរមានលក្ខណៈស្របគ្នា ឯកឧត្តម សុខ អាន បដិសេធនូវសញ្ញាណនៃ «ការបង្ខំលើគ្នា» ។

**ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០១**

ក្នុងការឆ្លើយតបវិញ លោក កូរេល បញ្ជាក់សាជាថ្មីនូវភាពចាំបាច់ក្នុងការឲ្យឯកសារទាំងពីរនេះ មានលក្ខណៈស្របគ្នា ។

**ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០១**

ឯកឧត្តម សុខ អាន ដាក់ជូននូវច្បាប់ស្តីអំពី «ការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ» ដែលត្រូវបានអនុម័តនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ជាភាសាខ្មែរដោយមានកំណត់សម្គាល់មួយបញ្ជាក់ថាការបកប្រែជាភាសាអង់គ្លេសនិងភាសាបារាំងកំពុងតែដំណើរការជាលើកចុងក្រោយ ។

**ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០១**

ច្បាប់ស្តីអំពី«ការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ»ជាភាសាអង់គ្លេសនិងភាសាបារាំងត្រូវបានដាក់ជូនការិយាល័យទទួលបន្ទុកកិច្ចការច្បាប់ អមជាមួយលិខិតមួយពីឯកឧត្តម សុខ អាន ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ។

**ថ្ងៃទី៧ ខែតុលា ឆ្នាំ២០០១**

ឯកឧត្តម សុខ អាន ផ្ញើសេចក្តីអញ្ជើញ លោក កូរេល ឲ្យមកប្រទេសកម្ពុជា ដើម្បីបញ្ចប់និងសម្រេចជាលើកចុងក្រោយនូវអត្ថបទសហប្រតិបត្តិការ ។

**ថ្ងៃទី១០ ខែតុលា ឆ្នាំ២០០១**

នៅក្នុងលិខិតជូនចំពោះឯកឧត្តម សុខ អាន លោក កូរេល បញ្ចេញជាគំនិតយោបល់ទាក់ទងនឹងច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមនិងអនុស្សរណៈនៃការយោគយល់គ្នា ដែលត្រូវបានរៀបចំឡើងដើម្បីធ្វើឲ្យលិខិតូបករណ៍ទាំងពីរមានលក្ខណៈស្របគ្នា ។

**ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០១**

ឯកឧត្តម សុខ អាន បញ្ជាក់ថាបានទទួលនូវលិខិតនេះព្រមទាំងកិច្ចព្រមព្រៀងដែលពិនិត្យកែសម្រួលសាឡើងវិញរួចហើយ ដោយបញ្ជាក់ថា ការឆ្លើយតបរបស់ឯកឧត្តមមិនទាន់ពេញលេញនៅឡើងទេ ។ ឯកឧត្តម សុខ អាន លើកឡើងនូវការជំទាស់ចំពោះការមានអំណាចគ្រប់គ្រងរបស់កិច្ចព្រមព្រៀងទៅលើច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម ។

**ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០១**

នៅក្នុងលិខិតជូនចំពោះឯកឧត្តម សុខ អាន លោក កូរេល បញ្ជាក់ថា ការឆ្លើយតបមួយដែលមានលក្ខណៈទូលំទូលាយនឹងត្រូវបញ្ជូនមកនៅពេលណាក្រុមការងារសម្រាប់សហប្រតិបត្តិការជាមួយអ្នកជំនាញការច្បាប់បរទេសនិងការរៀបចំដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមបញ្ចប់សព្វគ្រប់ និងការពិនិត្យសាឡើងវិញទៅតាមយោបល់របស់អង្គការសហប្រជាជាតិ ។

**ថ្ងៃទី២២ ខែមករា ឆ្នាំ២០០២**

ឯកឧត្តម សុខ អាន បញ្ជូនការឆ្លើយតបដ៏លម្អិតមួយទៅកាន់លោក កូរេល ។

**ថ្ងៃទី៨ ខែកម្ភៈ ឆ្នាំ២០០២**

លោក កូរេល ជម្រាបជូនឯកឧត្តម សុខ អាន ថា អង្គការសហប្រជាជាតិលែងស្ថិតក្នុងជំហរបន្តការចរចាទៀតហើយ ។

**(ប្រែសម្រួលក្រៅផ្លូវការដោយ ស្វ ប៊ុនស៊ូ)**


សូមសរសេរលិខិត

ឬអត្ថបទពិភាក្សាជុំវិញបញ្ហាខ្មែរក្រហម ផ្ញើមក

**ទស្សនាវដ្តី«ស្វែងរកការពិត»**

ប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥)(២៣)២១១៨៧៥

ទូរសារលេខៈ (៨៥៥)(២៣)២១០៣៥៨

Email: dccam@bigpond.com.kh

# ថ្ងៃ២០ ឧសភា: នឹកដល់លោកតានិងពូរបស់ខ្ញុំ

កាលខ្ញុំនៅក្មេង ថ្ងៃ ២០ឧសភា គ្រាន់តែជាស្រមោលព្រាលៗ នៅក្នុងអារម្មណ៍របស់ខ្ញុំតែប៉ុណ្ណោះ ។ ខ្ញុំពុំដែលស្វែងយល់ឲ្យបានច្បាស់អំពីអត្ថន័យនៃទិវា២០ឧសភានេះឡើយ ។ ខ្ញុំគ្រាន់តែបានស្តាប់វិទ្យុនិងអានកាសែតអំពីការប្រារព្ធទិវានេះ ។ ខ្ញុំដឹងត្រឹមតែថា ទិវា២០ឧសភា ជាឱកាសដែលប្រជាជនខ្មែរជួបជុំគ្នាដើម្បីសារស័ព្ទអំពីទុក្ខវេទនានិងការព្រាត់ប្រាសសាច់ញាតិរបស់ខ្លួនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ខ្ញុំមិនស្គាល់បុគ្គលឈ្មោះ ប៉ុល ពត ។ ខ្ញុំមិនយល់អំពីរបបកម្ពុជាប្រជាធិបតេយ្យដែលប្រជាជនខ្មែរហៅថារបបប៉ុលពត សូម្បីតែឪពុកម្តាយរបស់ខ្ញុំធ្លាប់បានប្រាប់ថាខ្ញុំកើតក្នុងពេល ប៉ុល ពត ជម្លៀស (គឺជាដំណាក់កាលចាប់ផ្តើមនៃរបបប៉ុលពត) ក៏ដោយ ។ ខ្ញុំមិនយល់អំពីមូលហេតុដែលរបបប៉ុលពតសម្លាប់មនុស្សអស់រាប់លាននាក់ ។

បន្តិចម្តងៗ ការចង់ដឹងអំពីរបបប៉ុលពត អំពីបុគ្គលឈ្មោះ ប៉ុល ពត, អៀង សារី, ខៀវ សំផន, នួន ជា...និងអំពីចិត្តថ្លើមដ៏ខ្មៅងងឹតរបស់ជនទាំងនោះ បានដុះដាលឡើងនៅពេលដែលខ្ញុំរៀននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងកាន់តែយល់ដឹងជាបន្តបន្ទាប់នាពេលបច្ចុប្បន្ន ។ ខ្ញុំបានដឹងអំពីវិសាលភាពដ៏ធំធេងនៃមហាវិនាសកម្មនៅក្នុងប្រទេសកម្ពុជាដែលបានសាបព្រោះដោយជនទុយ៌សទាំងប៉ុន្មានរូបខាងលើនេះ ។ គ្រប់ក្រុមគ្រួសារខ្មែរសុទ្ធតែមិនអាចបំភ្លេចបាន និងមិនចង់ជួបជាថ្មីម្តងទៀត ។

ដោយសារខ្ញុំទើបតែកើតក្នុងអំឡុងពេលចាប់ផ្តើមនៃរបបប៉ុលពត ដូច្នេះខ្ញុំពុំអាចដឹងក្តីទាន់ដើម្បីបន្សល់នូវការចងចាំអំពីរបបដ៏ឃោរឃៅនេះទេ ។ ឪពុករបស់ខ្ញុំធ្លាប់បានប្រាប់ខ្ញុំថាគាត់បានបាត់បង់ឪពុក (ជីតារបស់ខ្ញុំ) និងប្អូនប្រុសពៅម្នាក់ (ពូរបស់ខ្ញុំ) នៅក្នុងរបប ប៉ុល ពត ។ ពូរបស់ខ្ញុំស្លាប់នៅកងចល័តកុមារដោយសារតែការអត់ឃ្លាន ។ លោកតារបស់ខ្ញុំស្លាប់ដោយជំងឺដែលបណ្តាលមកពីកង្វះអាហារនិងការបង្ខំឲ្យធ្វើការបាក់កម្លាំង ។ ខ្ញុំពុំដែលស្គាល់មុខលោកតានិងពូរបស់ខ្ញុំទេ ដូច្នេះមនោសញ្ចេតនារបស់ខ្ញុំចំពោះគាត់ទាំងពីរនាក់ពុំសូវជ្រាលជ្រៅប៉ុន្មានឡើយ ។ ប៉ុន្តែសម្រាប់ឪពុករបស់ខ្ញុំ ការសោកស្តាយដែលបណ្តាលមកពីការបាត់បង់ប្អូនប្រុសនិងឪពុកជាទីស្រលាញ់របស់គាត់មានទំហំធំធេងរកទីបំផុតគ្មាន ។ កំសួលនៃការឈឺចាប់របស់ឪពុកខ្ញុំផុសឡើងរាល់ពេលដែលគាត់រំឭកអំពីរបបខ្មែរក្រហម ។

២០ឧសភា ជាថ្ងៃដែលខ្មែរក្រហមចាប់ផ្តើមបង្កើតសហករណ៍ហូបរួមនិងរស់នៅរួម ប៉ុន្តែធាតុពិតជាថ្ងៃដែលខ្មែរក្រហមចាប់ផ្តើមបន្អត់បាយប្រជាជន ជាថ្ងៃដែលខ្មែរក្រហមចាប់ផ្តើមសម្លាប់ប្រជាជនតាមមធ្យោបាយបង្ខំឲ្យធ្វើការជាទម្ងន់ប៉ុន្តែមិនឲ្យបរិភោគគ្រប់គ្រាន់ ជាថ្ងៃដែលលោកតានិងពូរបស់ខ្ញុំចាប់ផ្តើមអត់ឃ្លានបន្តិចម្តងៗរហូតដល់ស្លាប់ ។

មេដឹកនាំខ្មែរក្រហមទាំងអស់! ឆ្លើយប្រាប់ខ្ញុំមក ហេតុអ្វីបានជាធ្វើឲ្យលោកតានិងពូរបស់ខ្ញុំបាត់បង់ជីវិត? ហេតុអ្វីក៏របបខ្មែរក្រហមមិនឲ្យម្ហូបអាហារដល់លោកតានិងពូរបស់ខ្ញុំបរិភោគឲ្យបានគ្រប់គ្រាន់ក្នុងខណៈដែលគាត់ត្រូវបានបង្ខំឲ្យធ្វើការរហូតដល់បាក់កម្លាំង?

ថ្ងៃ២០ឧសភា ជិតមកដល់ទៀតហើយ ។ ខ្ញុំមិនចង់ឲ្យថ្ងៃ ២០ឧសភា ឈានចូលមកដល់ទេ ពីព្រោះជាថ្ងៃដែលធ្វើឲ្យខ្ញុំសោកសៅក្នុងចិត្តដោយសារតែបានដឹងពីរឿងឈឺចាប់ ។ ប៉ុន្តែខ្ញុំក៏មិនចង់បំភ្លេចថ្ងៃ២០ឧសភាដែរ ដរាបណាខ្ញុំមិនទាន់ឃើញឪពុកខ្ញុំបានទទួលសំណងណាមួយឲ្យស័ក្តិសមនឹងការបាត់បង់ឪពុកនិងប្អូនប្រុសពៅរបស់គាត់ ។ រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិមិនគួរបន្តមិនអើពើចំពោះការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ហើយបណ្តែតបណ្តោយឲ្យមេឃាតករដែលមានបាតដៃប្រឡាក់ឈាមទាំងនេះគេចរួចពីសំណាញ់ច្បាប់ និងរស់នៅយ៉ាងសុខស្រួលនៅចំពោះមុខក្រសែភ្នែកឈឺចាប់របស់ជនរងគ្រោះខ្មែរទាំងអស់ឡើយ ។ ខ្ញុំចង់ឲ្យតុលាការខ្មែរក្រហមចាប់បដិសន្ធិនៅថ្ងៃ២០ឧសភាឆ្នាំ២០០២នេះ ។ ខ្ញុំចង់បានយុត្តិធម៌ ឪពុកខ្ញុំក៏ចង់បានយុត្តិធម៌ ប្រជាជនខ្មែរទាំងអស់ក៏ចង់បានយុត្តិធម៌ មនុស្សជាតិទាំងអស់ក៏ចង់ឲ្យភពផែនដីនេះមានយុត្តិធម៌ដូចៗគ្នា ។

**សាន់ កល្យាណ**

# ឪពុកនិងប្អូនរបស់ខ្ញុំស្លាប់ដោយសារខ្មែរក្រហម

បងស្រី ខ្លៃ ហ៊ាង មានអាយុ៤៥ឆ្នាំ បានរៀបការនៅឆ្នាំ១៩៧៩ ។ សព្វថ្ងៃគាត់មានកូនបីនាក់ ស្រីពីរនាក់និងប្រុសម្នាក់ ។ ប្តីរបស់គាត់ប្រកបមុខរបររត់រ៉ឺម៉កម៉ូតូដើម្បីយកកម្រៃមកផ្គត់ផ្គង់ជីវភាពគ្រួសារ ។ នៅមុនឆ្នាំ១៩៧៥ បងស្រី ខ្លៃ ហ៊ាង រស់នៅក្នុងបន្ទុកគ្រួសារដែលមានសមាជិកចំនួន៩នាក់ ។ ក្រោយពេលឆ្លងកាត់របបខ្មែរក្រហម គ្រួសាររបស់បងស្រី ខ្លៃ ហ៊ាង នៅសល់សមាជិក៦នាក់តែប៉ុណ្ណោះ ដែលបានវិលត្រឡប់មករស់នៅទីក្រុងភ្នំពេញសាជាថ្មីម្តងទៀត ។ ឪពុកនិងប្អូនប្រុសពៅរបស់បងស្រី ខ្លៃ ហ៊ាង ត្រូវស្លាប់ដោយសារកង្វះអាហារនិងឈឺគ្មានថ្នាំព្យាបាល ។ ចំណែកប្អូនស្រីទី២ បាត់ខ្លួនតាំងពីពេលដែលកម្មាភិបាលខ្មែរក្រហមបានបញ្ជូនទៅព្យាបាលជំងឺនៅមន្ទីរពេទ្យកំពង់ចាមក្នុងឆ្នាំ១៩៧៥មកម្ល៉េះ ។

បងស្រី ខ្លៃ ហ៊ាង បានរៀបរាប់ពីដំណើរជីវិតក្នុងក្រុមគ្រួសាររបស់គាត់ ដូចខាងក្រោមនេះ ÷

មុនឆ្នាំ១៩៧៥ ខ្ញុំរស់នៅម្តុំផ្សារគីឡូម៉ែត្រលេខ៦ ។ នៅពេលខ្មែរក្រហមរំដោះបានភ្នំពេញទាំងស្រុងនាថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ គ្រួសាររបស់ខ្ញុំត្រូវបានជម្លៀសឲ្យទៅរស់នៅក្នុងភូមិបល្ល័ង្ក ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ បន្ទាប់ពីរស់នៅទីនោះបានមួយរយៈពេលខ្លី អង្គការបានជម្លៀសឲ្យគ្រួសារខ្ញុំទៅនៅភូមិអូរលើ ឃុំមេសរជ្រៃ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។ ម្តាយខ្ញុំបានជួលរទេះគោអ្នកស្រុកចំនួនពីរដើម្បីធ្វើដំណើរទៅខេត្តកំពង់ចាម ។ ការធ្វើដំណើរចេញពីខេត្តកំពង់ធំឆ្ពោះទៅកាន់ខេត្តកំពង់ចាមត្រូវចំណាយពេលចំនួនបួនថ្ងៃ ។ ទៅដល់ទីនោះភ្លាម ម្តាយខ្ញុំបានរូតរះទៅភូមិស្រែវាល សួររកប្អូនស្រីបង្កើតរបស់គាត់ ។ គាត់មានប្អូនស្រីម្នាក់រស់នៅទីនោះ ។ អ្នកភូមិដែលរស់នៅម្តុំនោះបានប្រាប់ថា ប្អូនស្រីរបស់ម្តាយខ្ញុំត្រូវអង្គការជម្លៀសទាំងគ្រួសារទៅនៅភូមិសន្ទិច ឃុំដងក្តារ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាមបាត់ទៅហើយ ។

ក្រោយពីរកប្អូនស្រីមិនជួប ម្តាយខ្ញុំក៏បានទៅសុំផ្ទះអ្នកភូមិអូរលើដើម្បីស្នាក់នៅបណ្តោះអាសន្ន ។ នៅភូមិអូរលើនេះជីវភាពក្នុងគ្រួសាររបស់ខ្ញុំមានការលំបាកជាខ្លាំង ។ ពេលខ្វះក្រុមគ្រួសាររបស់ខ្ញុំគ្មានបាយហូបទេ មានតែមើមដំឡូង ស្លឹកដំឡូងគល់ចេក និងគល់ល្ហុង យកមកហូបជំនួសបាយ ។ ពេលនោះហើយដែលខ្ញុំបានស្គាល់ពីរសជាតិនៃសេចក្តីអត់ឃ្លាន ។ ដោយសារការហូបមិនគ្រប់គ្រាន់ខ្វះជីវជាតិបណ្តាលឲ្យប៉ារបស់ខ្ញុំធ្លាក់ខ្លួនមានជំងឺហើម ។ ជើងទាំងពីររបស់ប៉ាខ្ញុំហើមធំដើរមិនរួច ហើយប្រេះនិងមានទឹករងៃហូរចេញទៀតផង ។ ស្ថិតក្នុងស្ថានភាពនេះ ម្តាយរបស់ខ្ញុំបាននាំប៉ាខ្ញុំទៅមន្ទីរពេទ្យស្រុក ។ ជំងឺហើមរបស់ប៉ាខ្ញុំ


ខ្លៃ ហ៊ាង

មានសភាពធ្ងន់ធ្ងរពេក មន្ទីរពេទ្យស្រុកមិនបានទទួលប៉ាខ្ញុំឲ្យនៅសម្រាកព្យាបាលជំងឺទេ ពីព្រោះទីនោះគ្មានថ្នាំព្យាបាល ។

កម្មាភិបាលពេទ្យបានបញ្ជូនប៉ាខ្ញុំបន្តទៅមន្ទីរពេទ្យខេត្តកំពង់ចាម ។ ការបញ្ជូនប៉ារបស់ខ្ញុំទៅមន្ទីរពេទ្យខេត្តកំពង់ចាមនេះ កម្មាភិបាលពេទ្យមិនអនុញ្ញាតឲ្យនរណាម្នាក់ក្នុងគ្រួសាររបស់ខ្ញុំទៅជាមួយដើម្បីកំដរប៉ារបស់ខ្ញុំទេ ។ ទោះបីជាម្តាយរបស់ខ្ញុំខំអង្វរករយ៉ាងណាក៏ដោយ ក៏កម្មាភិបាលពេទ្យខ្មែរក្រហមទាំងនោះមិនអើពើអ្វីទាំងអស់ ហើយថែមទាំងនិយាយថា “មីងមិនមែនជាពេទ្យទេ មិនចាំបាច់ទៅទេនាំតែអស់បាយពេទ្យ” ។ ម្តាយរបស់ខ្ញុំឈឺចាប់ខ្លាំងណាស់នៅពេលឮសម្តីដ៏អមនុស្សធម៌របស់កម្មាភិបាលពេទ្យទាំងនោះ ក៏ប៉ុន្តែមិនដឹងធ្វើដូចម្តេច ។ ទឹកមុខម្តាយរបស់ខ្ញុំក្រៀមក្រំដោយបង្កប់នូវទុក្ខព្រួយនិងក្តីបារម្ភចំពោះសុខទុក្ខរបស់ប៉ាខ្ញុំ មិនដឹងជាបានអ្នកណាមើលការខុសត្រូវពេលប៉ាខ្ញុំត្រូវការទឹកក្តៅ ទឹកត្រជាក់ ។ ថ្ងៃមួយ គ្រួសាររបស់ខ្ញុំបានទទួលដំណឹងដ៏ក្រៀមក្រំមួយពីអ្នកភូមិថា ប៉ារបស់ខ្ញុំបានស្លាប់បាត់ទៅហើយ នៅក្នុងមន្ទីរពេទ្យខេត្តកំពង់ចាម ។

ប៉ាស្លាប់នៅស្រុកគេតែម្នាក់ឯង សូម្បីតែម្តាយនិងបងប្អូនរបស់ខ្ញុំទាំងអស់ក៏មិនបានទៅឃើញមុខប៉ាជាចុងក្រោយដែរ ។ យើងមិនអាចរៀបចំធ្វើបុណ្យឲ្យបានសមរម្យទេ ។ អ្វីដែលយើងអាចធ្វើបាននៅពេលនោះគឺកោរសក់ក្នុងន័យបញ្ជាក់អំពីទឹកចិត្តរបស់កូនៗ ដើម្បីគោរពវិញ្ញាណក្ខន្ធលោកប៉ានិងសូមឧទ្ទិសកុសលជូនដល់ព្រលឹងលោកប៉ាឲ្យបានទៅសុគតិភព ។ យើងទាំងអស់គ្នាមិនដឹងថាសាកសពលោកប៉ាត្រូវកម្មាភិបាលពេទ្យខ្មែរក្រហមយកទៅណាទេ ។ ម្នាក់ៗបានត្រឹមតែអង្គុយយំដោយក្តីសោកស្តាយ ។

មរណភាពរបស់ប៉ាខ្ញុំ ធ្វើឲ្យម្តាយរបស់ខ្ញុំកើតទុក្ខជាខ្លាំងរហូតវង្វេងស្មារតីអស់ជាច្រើនខែ ។ ក្រោយពីប៉ារបស់ខ្ញុំស្លាប់មិនយូរប៉ុន្មានផង ប្អូនប្រុសពៅរបស់ខ្ញុំ ក៏ត្រូវធ្លាក់ខ្លួនមានជំងឺរហូតដល់ស្លាប់ដោយសារកង្វះអាហារនិងគ្មានថ្នាំសង្កូវព្យាបាល ។ ប្អូនប្រុសពៅរបស់ខ្ញុំបានស្លាប់នៅមន្ទីរពេទ្យឃុំមេសរជ្រៃ ក្នុងរង្វង់ដៃរបស់ម្តាយខ្ញុំនៅវេលាម៉ោង៤ៈ៣០នាទីទៀបភ្លឺ ។ លុះភ្លឺឡើងកម្មាភិបាលពេទ្យខ្មែរក្រហមបានយកសាកសពប្អូនរបស់ខ្ញុំរុំនឹងកន្ទេលកញ្ចាស់តូចមួយ ចងផ្តោបនឹងរានកង់ខាងក្រោយដឹកយកទៅកប់នៅវាលកប់ខ្មោចដោយមិនអនុញ្ញាតឲ្យម្តាយរបស់ខ្ញុំទៅជាមួយទេ ។

នៅចុងឆ្នាំ១៩៧៥ បន្ទាប់ពីប្អូនប្រុសរបស់ខ្ញុំស្លាប់បានប្រមាណមួយខែ ប្អូនស្រីទីពីររបស់ខ្ញុំក៏ធ្លាក់ខ្លួនឈឺ ហើយត្រូវបានអង្គការបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យខេត្តកំពង់ចាម ។ ចាប់តាំងពីប្អូនស្រីម្នាក់នេះទៅព្យាបាលជំងឺនៅខេត្តកំពង់ចាមរហូតមកទល់បច្ចុប្បន្ន គឺបាត់ខ្លួនរហូតមិនដឹងថាស្លាប់ឬរស់ទេ ។

បន្ទាប់មកទៀត គ្រួសារខ្ញុំត្រូវបានអង្គការបញ្ជូនទៅរស់នៅភូមិមួយទៀត គឺ“ភូមិចាម” ដែលស្ថិតនៅក្នុងឃុំ ស្រុក និងខេត្តដដែល ។ ភូមិចាមនេះពីមុនមកប្រហែលជាគ្មានមនុស្សរស់នៅទេ ពីព្រោះនៅក្នុងភូមិទាំងមូលមានតែប្រជាជន “១៧មេសា” ដែលអង្គការបញ្ជូនមកពីតំបន់ផ្សេងៗឲ្យមករស់នៅផ្តុំគ្នាក្នុងភូមិនេះ ។ គ្រួសារនីមួយៗទើបតែបានចូលមករស់នៅទីនេះដូចគ្រួសាររបស់ខ្ញុំដែរ ។

សហករណ៍ត្រូវបានបង្កើតឡើងបន្ទាប់ពីមានប្រជាជនមករស់នៅក្នុងភូមិចាមនេះ ។ ប្រជាជនចាប់ផ្តើមធ្វើការរួមហូបរួម ដីស្រែចម្ការ សម្ភារប្រើប្រាស់ទាំងប៉ុន្មាននៅក្នុងផ្ទះ ត្រូវអង្គការរឹបអូសយកទៅដាក់ជាទ្រព្យសម្បត្តិរួម ។ ប្រជាជនទាំងអស់ត្រូវបានបែងចែកទៅតាមវ័យ ដើម្បីធ្វើការបម្រើសមូហភាពនិងអង្គការ ។ ម្តាយខ្ញុំត្រូវដើរទៅធ្វើការនៅកន្លែងឆ្ងាយៗពីផ្ទះ លុះដល់ពេលល្ងាចទើបបានត្រឡប់មកផ្ទះវិញ ។ ចំណែកប្អូនរបស់ខ្ញុំបីនាក់ទៀតនៅតូចៗនៅឡើយ ត្រូវអង្គការបញ្ជូនឲ្យទៅនៅកងកុមារ ហើយបង្ខំឲ្យធ្វើការដូចជា ដើររើសអាចម៍គោ អាចម៍ក្របី កាប់ដើមទន្ទ្រានខែត្រយកមកធ្វើជីដាក់ស្រែ និងដើររើសគួរស្រូវដោយដាក់កំហិតក្នុងម្នាក់រកឲ្យបានមួយល្អីទើបបានសម្រាក ។

នៅក្នុងរបបខ្មែរក្រហម គ្មាននរណាមួយរស់បានដោយមិនបញ្ចេញកម្លាំងពលកម្មទេ លើកលែងតែកុមារតូចៗដែលមិនទាន់ចេះនិយាយទើបអាចគេចផុត ។ ប៉ុន្តែកុមារតូចៗទាំងនោះក៏គ្មានឱកាសបានទទួលការបីបាច់ថែរក្សានិងរស់នៅក្បែរម្តាយរបស់ខ្លួនដែរ ពីព្រោះម្តាយរបស់កុមារតូចៗទាំងនោះត្រូវ

ចេញទៅធ្វើការងាររបួរយករបបបបររាវ១៣វែកហូបដើម្បីរស់ និងដើម្បីធ្វើការបម្រើអង្គការនៅថ្ងៃស្អែកទៀត ។ ចំណែកកុមារដែលមានអាយុចាប់ពី៧ឆ្នាំឡើងទៅ ត្រូវអង្គការប្រើឲ្យធ្វើនេះធ្វើនោះ មិនឲ្យកុមារបានចូលសាលារៀនទេ ។

ខ្ញុំ បងប្រុស និងប្អូនប្រុសបន្ទាប់ខ្ញុំ ស្ថិតនៅក្នុងវ័យយុវជន និងយុវនារី ត្រូវអង្គការបំបែកចេញពីឪពុកម្តាយឲ្យទៅនៅក្នុងកងចល័តនៅស្រុកឆ្ងាយ ។ ការងារជាប្រចាំថ្ងៃរបស់ខ្ញុំ គឺលើកទំនប់ ជីកប្រឡាយ និងធ្វើស្រែចម្ការ ។ យូរៗម្តងទើបគណៈកងអនុញ្ញាតឲ្យមកលេងផ្ទះបានមួយថ្ងៃ ។ រយៈពេលជាង៣ឆ្នាំ ខ្ញុំបានមកលេងផ្ទះតែបីដងប៉ុណ្ណោះ ។

រៀងរាល់ព្រឹកនៅម៉ោង៤ទៀបភ្លឺ ស្នូរសម្លេងកញ្ចែរបស់គណៈកង បានដាស់យុវនារីគ្រប់រូបដែលកំពុងតែលង់លក់ក្នុងដំណេកយ៉ាងស្កប់ស្កល់ឲ្យភ្ញាក់ក្រញាងឡើង ម្នីម្នារៀបចំខ្លួនចេញទៅតម្រង់ជួរ សូម្បីមុខមាត់ក៏មិនបានលុបលាងផង ។ ប្រសិនបើនរណាម្នាក់ដំអែងអក់ ស្ពឹកស្រពន់ យឺតយ៉ាវនោះប្រាកដជាត្រូវរំពាត់របស់គណៈកងជាមិនខាន ។ ចំណែកឯខាងយុវជនវិញក៏មិនខុសគ្នាដែរ នៅពេលគណៈកងផ្លុំកញ្ចែ ទាំងអស់គ្នាត្រូវរូតរះទៅតម្រង់ជួរដើម្បីរាប់ចំនួនមនុស្សមុនពេលចេញដំណើរទៅធ្វើការនៅតាមការដ្ឋាន ។

នៅក្នុងរបបខ្មែរក្រហម រវាងប្រុសនិងស្រីមិនអាចមានទំនាក់ទំនងគ្នាទេ សូម្បីតែបងប្អូនបង្កើតក៏ដោយ ពីព្រោះអង្គការបានចាត់ទុកថា ទំនាក់ទំនងរវាងប្រុសនិងស្រីគឺជាអំពើមួយ"ខុសសីលធម៌" ហើយជា "សត្រូវរបស់អង្គការ" ។ ដូច្នេះ អ្នកដែលមានសេចក្តីស្នេហា និងអ្នកដែលបានប្រព្រឹត្តខុសសីលធម៌ គឺត្រូវតែ "កម្ទេច" ។ ពាក្យថា "រៀនសូត្រ" ខ្ញុំមិនដឹងថាមានអត្ថន័យយ៉ាងម៉េចទេ ខ្ញុំគ្រាន់តែដឹងថា ពេលនរណាម្នាក់ត្រូវបានអង្គការស្នើសុំឲ្យទៅរៀនសូត្រ មិនដែលឃើញត្រឡប់មកវិញឡើយ គឺត្រូវបាត់ខ្លួនរហូត ។ យុវជននិងយុវនារីត្រូវអង្គការបំបែកឲ្យនៅកន្លែងផ្សេងពីគ្នា បង្ខំឲ្យធ្វើការជាទម្ងន់ និងផ្តល់អាហារមិនគ្រប់គ្រាន់ ។ ហេតុនេះ ឆ្លៀតពេលសម្រាកពីការងារទាំងអស់គ្នាត្រូវលួចចេញទៅបេះបោចផ្លែឈើ មើមឈើ និងរបស់ផ្សេងៗទៀតដែលអាចហូបបានមកចម្អិតក្រពះដើម្បីកាត់បន្ថយការស្រេកឃ្លាន ។ ប្រសិនបើគណៈកងដឹងថា មានអ្នកណាម្នាក់ហ៊ានទៅលួចរបស់របរហូប នឹងត្រូវទទួលទណ្ឌកម្មដោយចោទថា "ក្បត់សមូហភាព" ។

បច្ចុប្បន្ននេះ ថ្វីដ្បិតតែបងស្រី ឡៃ ហ៊ាង បានរួចជីវិតពីសេចក្តីស្លាប់ក៏ដោយ ក៏គាត់មិនអាចបំភ្លេចបានទេនូវព្រឹត្តការណ៍គួរឲ្យរន្ធត់ឈឺចាប់ដែលខ្មែរក្រហមបានប្រព្រឹត្តមកលើរូបគាត់គ្រួសាររបស់គាត់ និងប្រជាជនកម្ពុជាទូទៅ ។ ទោះបីរបបខ្មែរក្រហមបានដួលរលំទៅអស់ជាងម្ភៃឆ្នាំហើយក៏ដោយ ក៏ប៉ុន្តែសេចក្តីឈឺចាប់ដែលក្រុមគ្រួសាររបស់គាត់បានទទួលរងពីរបបខ្មែរក្រហមនៅតែដិតជាប់ក្នុងអារម្មណ៍របស់គាត់ជានិច្ច ។

បងស្រី ឡៃ ហ៊ាង បានលើកឡើងនូវសំណូមពរដ៏ទទូចចំពោះរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ត្រូវតែបង្កើតតុលាការឯករាជ្យឲ្យខាងតែបាន ដើម្បីជំនុំជម្រះទោសមេដឹកនាំខ្មែរក្រហម រកយុត្តិធម៌ជូនដល់វិញ្ញាណក្ខន្ធឪពុកនិងប្អូនរបស់គាត់ ក៏ដូចជាប្រជាជនកម្ពុជាស្លូតត្រង់ជិត២លាននាក់ ដែលបានស្លាប់បាត់បង់ជីវិតក្រោមរបបផ្តាច់ការនេះ ។ **ឆេង ម៉េង**

## ពាក្យស្លោកខ្មែរក្រហម

◆ **ត្រូវអនុវត្តប្រជាធិបតេយ្យនិងប្រមូលផ្តុំរួមគ្នាតាមគោល-ការណ៍សមូហភាពដឹកនាំ ម៉ត់ចត់ និងបុគ្គលទទួលខុសត្រូវដោយឡែកសកម្មប្រយុទ្ធ។**

◆ **ដឹកនាំត្រូវធ្វើគំរូមហាជនលើជំហរនយោបាយ សតិអារម្មណ៍ចាត់តាំងការងារ ការរស់នៅ សីលធម៌ និងសាមគ្គីភាព ឯកភាពតាមមាគ៌ារបស់បក្ស។**

◆ **បដិសេធនិងកម្ចាត់ជាច់ខាតការដឹកនាំធ្វើការងារតាមបុគ្គលដើរឧបាយកលអូសទាញមហាជនតាមមនោសញ្ចេតនាផ្ទាល់និងតាមសម្ភារៈ សម្រាប់បម្រើបុគ្គល ឬក៏តាមអាជ្ញាបង្ខិតបង្ខំគំរាមមហាជនឱ្យខ្លាចខ្លួន។**

◆ **សំរិតសំរាំងនិងកម្ចាត់ខ្មាំងស៊ីរូងផ្ទៃក្នុងដែលបន្លំធ្វើជាកម្មា-ភិបាលតាមថ្នាក់ផ្សេងៗនិងតាមអង្គភាពផ្សេងៗ។**

(ឯកសារលេខ D១៣៧៩៧)

ប្រលោមលោកបដិវត្ត

# ពលិកម្មម៉ែៗយើង

**(តចប់)**

ចំនួន៦ខែក្រោយមក ពួកអាទាហាននោះពុំដឹងជាវាគិតឃើញយ៉ាងដូចម្តេចវាក៏លែងម៉ែខ្ញុំមកផ្ទះវិញ ។ ម៉ែដេកព្យាបាលរបួសនិងជំងឺអស់៣ខែទើបបានធូរគ្រាន់ ។



ដើមឆ្នាំ១៩៦៨ បដិវត្តន៍យើងត្រូវផ្ទុះអាវុធ ។ ពូនឿនបានមកស្នើបងឲ្យចូលយោធា ។ ម៉ែអរកខិបកខុប រៀបចំខោអាវកញ្ចាស់ៗបានពីរសម្រាប់ឲ្យបង ។ មុននឹងចេញដំណើរ ម៉ែបានហៅបងមករំពុកថា "កុំភ្លេចឲ្យសោះ ឈាមបងប្អូនក្រីក្រយើង ឈាមពុកកូន ត្រូវសងវិញឲ្យបានដាច់ខាត!" ។

បងទៅធ្វើយោធាអស់២ឆ្នាំហើយ ។ ម៉ែនិងខ្ញុំឥតបានទទួលដំណឹងអ្វីបន្តិចបន្តួចសោះពីបង ។ ម៉ែខ្ញុំតែកាលណាឮបងប្អូនយើងដំណាលពីជ័យជំនះរបស់កងទ័ពបដិវត្តន៍យើងនៅសមរភូមិណាក៏ដោយ គាត់តែងសន្មតថាបងខ្ញុំបានចូលរួមប្រយុទ្ធដែរ ។ ម៉ែជឿជាក់ទៀតថា ឲ្យតែមានសមរភូមិនៅទីណា នៅទីនោះ ប្រាកដជាមានបងហើយ ។ ម៉ែនិយាយនឹងខ្ញុំថា "បងកូនឯងត្រូវតែហ៊ានបូជាជីវិតដើម្បីបដិវត្តន៍យើងនិងប្រជាជនក្រីក្រយើង! បងកូនឯងត្រូវតែដាច់ខាតដូចពុកកូនឯងអ៊ីចឹង!" ។

ពេលពូនឿន មកលេងផ្ទះយើងម្តងៗ ម៉ែតែងតែសួរសុខទុក្ខពីបងជានិច្ច ។ ឯពូនឿន តែងឆ្លើយប្រាប់ថា គាត់សុខសប្បាយជាទេ តែក្រោយមកទើបគាត់ប្រាប់រឿងពិតដល់យើង ។ បងពលីជីវិតតាំងពីបែកពីម៉ែនិងខ្ញុំបានមួយឆ្នាំម៉្លេះ ក្នុងពេលប្រយុទ្ធជាមួយខ្មាំងដណ្តើមអាវុធពីវា ។ ម៉ែបន្ទោស ពូនឿន ថាមិនស្គាល់ចិត្តម៉ែទេ ។ ដឹងថាបងពលីក្នុងសមរភូមិដ៏រុងរឿងដូច្នេះ ម៉ែរំភើបញាប់ញ័រក្រៃលែង ។ ម៉ែប្រាប់ពូនឿនថា ម៉ែស្រឡាញ់កូនមែន តែស្រឡាញ់តែកូនដែលបម្រើបដិវត្តន៍ បម្រើប្រជាជនក្រីក្រ ។ ម៉ែប្រកាសប្រាប់ពូនឿនថា "រឿងដែលកូនខ្ញុំស្លាប់ ខ្ញុំឥតតូចចិត្តតូចថ្លើមនឹងអង្គការអ្វីបន្តិចបន្តួចទេ ។ ធ្វើបដិវត្តន៍តែងតែមានពលិកម្មជាការធម្មតា ចង់រំដោះខ្លួនត្រូវតែហ៊ានលះបង់ ។ បើអង្គការពុំយល់ទាស់ទេ ខ្ញុំនឹងបញ្ជូនកូនស្រីឲ្យទៅបម្រើបដិវត្តន៍ទៀត" ។

ក្រោយរដ្ឋប្រហារថ្ងៃ១៨ មីនា ១៩៧០ ពូនឿន ក៏សុខចិត្តឲ្យខ្ញុំចូលកងទ័ពបដិវត្ត ។ ថ្ងៃដែលខ្ញុំបែកពីម៉ែគឺជាថ្ងៃដែលខ្ញុំ

ដិតជាប់ក្នុងចិត្តអស់មួយជីវិត ។ ម៉ែជូនដំណើរខ្ញុំរហូតដល់មាត់របងផ្ទះ ។ ខ្ញុំចង់ឱបម៉ែឲ្យណែនក្នុងដៃនៅទីចុងបំផុតនេះ ។ តែម៉ែក៏ទាញខ្ញុំមកឱបយ៉ាងណែនដៃ រួចចាប់ទាញស្មាខ្ញុំឲ្យឃ្លាតពីទ្រូងគាត់បន្តិច ។ ម៉ែសម្លឹងមុខខ្ញុំមិនព្រិចភ្នែកឡើយ ។ ភ្នែកម៉ែឡើងរលីងរលោងដែរ តែម៉ែញញឹមស្រទន់មករកខ្ញុំ ។ ម៉ែទូន្មានខ្ញុំចុងក្រោយថា "កូនស្រីជាកូនម៉ែ ជាកូនរបស់ប្រជាជនក្រីក្រ កូនត្រូវបំពេញភារកិច្ចជូនបដិវត្តន៍ដាច់ខាត និងរក្សាគោលជំហររបស់កូនឲ្យក្រហមឆ្អិនឆ្អៅជានិច្ច បន្តប្រពៃណីប្រយុទ្ធដ៏អង់អាចក្លាហានរបស់ពុកកូន និងបងកូន..." ។ នៅពេលដែលខ្ញុំចូលប្រយុទ្ធជាមួយនឹងខ្មាំងម្តងៗ សំឡេងនេះតែងតែដុតភ្លើងកំហឹងជាតិនិងវណ្ណៈរបស់ខ្ញុំឲ្យឆេះឆំជាប់ជានិច្ចចំពោះខ្មាំងសត្រូវ ។ ខ្ញុំចេះតែបានទទួលសំបុត្រពីម៉ែមិនដាច់ដែរ ។ ក្នុងសំបុត្រនោះម៉ែតែងតែក្រើនរំឭកដាក់តឿនខ្ញុំកុំឲ្យធ្វេសប្រហែស ឲ្យប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ជានិច្ច ឲ្យដាច់ខាតក្នុងការកំទេចខ្មាំង ហើយកុំគិតគូរដល់គាត់អី គាត់សុខសប្បាយទេ ។

ថ្ងៃ១៧ មេសា ១៩៧៥ ប្រទេសកម្ពុជាត្រូវបានរំដោះទាំងស្រុង ។ ខ្ញុំសុំច្បាប់លោកតា មកលេងជាមួយម៉ែ ។ ខ្ញុំឃើញលោកតាហាក់ដូចជាពរែក ។ ក្រោយពីគិតមួយសន្ទុះមកគាត់ក៏អនុញ្ញាតតាមការស្នើ ។ ខ្ញុំរីករាយក្នុងចិត្តពន់ពេក ។ ខ្ញុំត្រៀមការសួរសុខទុក្ខម៉ែខ្ញុំច្រើនណាស់រាប់មិនអស់ទេ ។ មកដល់ភូមិកំណើតខ្ញុំ ខ្ញុំខំបោះជំហានយ៉ាងវែងៗសំដៅផ្ទះ ។ ខ្ញុំបែកពីភូមិ៥ឆ្នាំហើយ ។ ឥឡូវនេះភូមិខ្ញុំល្អជាងមុន ។ បងប្អូនរស់នៅធ្វើការងារជាសមូហភាពក្នុងសហករណ៍អស់ទៅហើយ ។ ទៅដល់មុខផ្ទះខ្ញុំ ខ្ញុំរត់សឹងតែផ្លោះរបង ។ ឡើងផ្ទះ ខ្ញុំហក់ឡើងជណ្តើរម្តងពីរកាំ ដើម្បីឲ្យឆាប់ដល់លើ ស្រាប់តែជួបវាក់នឹងមីងក្រឹម ប្រពន្ធពូត្រានៅជាមួយចៅៗគាត់៣នាក់លើផ្ទះខ្ញុំ ។ ខ្ញុំរំពៃរកម៉ែតែពុំឃើញសោះ ។ មីងក្រឹមលាន់មាត់ថា "យី! ក្មួយស្រីមីងទេតើ!" ហើយគាត់ស្ទុះមកឱបខ្ញុំទាំងទឹកភ្នែក ។ ខ្ញុំសួរមីងក្រឹមថា "ឯណាម៉ែខ្ញុំ?" ។ មីងនិយាយថា "អង្គុយឲ្យបាត់ហត់សិនទៅក្មួយ! ហូបទឹកសិនទៅក្មួយ!" ។ "ទេ! ខ្ញុំអត់ហត់ អត់ស្រេកអ្វីទាំងអស់ ឲ្យតែបានជួបមុខម៉ែខ្ញុំ ខ្ញុំឆ្អែតហើយ!" ។ មីងបន្ទឺសម្តីថា "លោកតាអត់ប្រាប់ក្មួយឯងទេ? ម្តាយក្មួយឯងស្លាប់៣ឆ្នាំទៅហើយណា៎ គឺគាត់ស្លាប់២ឆ្នាំក្រោយពីក្មួយឯងបែកពីគាត់ទៅ" ។ ឮថាម៉ែខ្ញុំស្លាប់ដូច្នេះភ្លាម ខ្ញុំចង់រលំដួលនិងទ្រហោយំយ៉ាងខ្លាំង ។ តែការនេះវាក្លាយទៅជាទម្លាប់ខ្ញុំទៅហើយ ខ្ញុំប្រឹងឃាត់ទឹកភ្នែកខ្ញុំបាន ។ នេះក៏ម៉ែបង្រៀនខ្ញុំដែរ ។

ខ្ញុំឈរនៅមុខផ្នូរម៉ែ ។ ខ្ញុំទើបតែយល់ថា ក្រោយពីខ្ញុំបែកពីម៉ែបាន២ឆ្នាំ ម៉ែធ្លាក់ខ្លួនឈឺជាទម្ងន់ ។ ម៉ែដឹងខ្លួនច្បាស់ថា ពុំអាចរស់ឃើញជ័យជំនះទីអវសានរបស់បដិវត្តន៍ឡើយ ឃើញមុខកូនស្រីម៉ែវិញឡើយ ។ តែម៉ែជឿជាក់ឥតស្រពេចស្រពិលទេលើជ័យជំនះទីអវសាននៃចលនាបដិវត្តន៍ប្រាកដណាស់ ។ ម៉ែក៏សរសេរសំបុត្រមួយចំនួនដាស់តឿនខ្ញុំផង ជូនពរសព្ទសាធុការដល់យុទ្ធជន-យុទ្ធនារីដែលតស៊ូនៅសមរភូមិមុខផង ។ ម៉ែផ្ញើសំបុត្រទាំងនោះទុកនៅនឹងលោកតាឲ្យលែលកយ៉ាងម៉េចផ្ញើឲ្យខ្ញុំម្តងមួយៗរហូតមក ដើម្បីកុំឲ្យខ្ញុំគិតគូរមកផ្ទះ មកម៉ែ ។ ការនេះធ្វើឲ្យខ្ញុំនឹកស្មានថា ម៉ែនៅមានជីវិតរស់នៅរហូតដល់សព្វថ្ងៃ ។

ម៉ែខ្ញុំស្លាប់ទៅមែន ប្រជាជនយើងរាប់ម៉ឺនរាប់សែននាក់ក៏បានធ្វើពលិកម្មទៅហើយដែរ តែម៉ែនិងប្រជាជនយើងបានបន្សល់ទុកឲ្យខ្ញុំនូវកេរមរតកដ៏ឧត្តុង្គឧត្តមណាស់ គឺគោលជំហរវីរភាពបដិវត្តខ្ពង់ខ្ពស់ក្រៃលែង ជំហរលះបង់ដោយឥតល័ក្ខខ័ណ្ឌដើម្បីបដិវត្តន៍ ដើម្បីប្រជាជនក្រីក្រ និងជំហរប្រយុទ្ធប្តូរផ្តាច់ដែលជាប្រពៃណីដ៏រុងរឿងរបស់កសិករក្រីក្រយើងតាំងតែពីដើមរៀងមក ។ ក្នុងការតស៊ូបដិវត្តន៍២៨ឆ្នាំកន្លងទៅនេះ ម៉ែយើងរាប់ម៉ឺនរាប់សែននាក់បានធ្វើពលិកម្មគ្រប់បែបយ៉ាងយ៉ាងអង់អាចក្លាហានបំផុត គ្មានដែលត្អូញត្អែរ គ្មានដែលថ្ងូរមួយអឺះសោះឡើយ ។

យើងខ្ញុំយុវជន-យុវនារីបដិវត្ត ដែលជាកូនចៅម៉ែៗប្តេជ្ញាបន្តលើកស្ទួយប្រពៃណីដ៏រុងរឿងនេះឲ្យកាន់តែខ្ពស់ត្រដែតត្រដឹមថែមទៀត ដើម្បីវាយសម្រុកឲ្យខ្លាំងក្លាបំផុតនិងក្តៅគគុកជាប់ជានិច្ចក្នុងចលនាតស៊ូបដិវត្តន៍ថ្មី គឺការពារប្រទេសនិងកសាងប្រទេសឲ្យបានខ្លាំងពូកែនិងសំបូរសប្បាយរុងរឿងថ្កើងថ្កានយ៉ាងឆាប់រហ័សបំផុត ។ គ្មានអ្វីអាចរាំងស្កាត់ទប់ដំណើរយើងបានឡើយ ។

**ចប់ដោយបរិបូរណ៍**

## លិខិតមកពីអនុវិទ្យាល័យបែកចាន ស្រុកអង្គស្នួល ខេត្តកណ្ដាល

**កម្មវត្ថុៈ** *សេចក្ដីថ្លែងអំណរគុណចំពោះការដែលបានទទួលអំណោយទស្សនាវដ្ដី«ស្វែងរកការពិត» ។*

*សេចក្ដីដូចបានចុះក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមជម្រាបលោកនាយកថា កាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០១ តាមរយៈលោក ឃួយ វិសាលមុន្នី បុគ្គលិកនៃមជ្ឈមណ្ឌលឯកសារកម្ពុជា សាលាយើងខ្ញុំបានទទួលទស្សនាវដ្ដី«ស្វែងរកការពិត» លេខ២៣ ខែវិច្ឆិកា ឆ្នាំ២០០១ ចំនួន០២ច្បាប់ ។*

*ក្រោយពីបានអាន យើងខ្ញុំកត់សម្គាល់ឃើញថា ទស្សនាវដ្ដីនេះមានខ្លឹមសារនិងអត្ថន័យយ៉ាងល្អប្រសើរ ជាពិសេសក្នុងនោះបានធ្វើឲ្យអ្នកដែលឆ្លងកាត់របបប្រល័យពូជសាសន៍ ប៉ុល ពត នឹកឃើញឡើងវិញនូវអ្វីដែលឃោរឃៅ អមនុស្សធម៌ ព្រៃផ្សៃ ពាលសាមាន្យ ។ល។ ដែលប្រត្យក្សនៅពេលនោះ ។ ចំពោះអនុជនស្រករក្រោយនឹកហួសចិត្ត ហើយគិតថា ប្រហែលជារឿងប្រឌិត តែនេះជាព្រឹត្តិការណ៍ពិត ។*

*ដូចនេះ ទស្សនាវដ្ដី«ស្វែងរកការពិត»មានតម្លៃជាឯកសារប្រវត្តិសាស្ត្រផង ច្បាប់ផង និងការអប់រំផង ។ ចំពោះពិរុទ្ធជនគប្បីទទួលការផ្ដន្ទាទោសឲ្យស័ក្ដិសមជាទីបំផុត សម្រាប់ទុកជាគំរូដល់គ្រប់ជនជំនាន់ក្រោយអរិយធម៌មនុស្សជាតិដែលត្រូវវិវត្តតរៀងទៅ ។*

*បើមិនយល់ទាស់ទេ សូមលោកនាយកមេត្តាផ្ដល់សាលាយើងខ្ញុំនូវទស្សនាវដ្ដី«ស្វែងរកការពិត»នេះឲ្យបានគ្រប់លេខ ដើម្បីតម្កល់ទុកជូនសាធារណជនអាននៅបណ្ណាល័យយើងខ្ញុំដោយអនុគ្រោះផង ។*

*សូមលោកនាយកមេត្តាទទួលនូវសេចក្ដីគោរពនិងអំណរគុណដ៏ជ្រាលជ្រៅពីខ្ញុំបាទ និងសូមឲ្យបេសកកម្មស្វែងរកការពិតលោកទទួលបានជោគជ័យដូចបំណង ។*

***បែកចាន ថ្ងៃទី៩ ខែមករា ឆ្នាំ២០០២***

***ញឹប លី***

## លិខិតពីសហរដ្ឋអាមេរិក ថ្ងៃទី១០ ខែមេសា ឆ្នាំ២០០២

*ឯកឧត្ដមជាទីរាប់អាន!*

*ខ្ញុំមានសេចក្ដីរំភើបអបអរជាអតិបរមា បន្ទាប់ពីបានទទួលសេចក្ដីរាយការណ៍មកពីមាតុភូមិថា បញ្ហាអដ្ឋិធាតុរបស់ប្រជាពលរដ្ឋដែលបានស្លាប់បាត់បង់ជីវិតនៅក្រោមរបបខ្មែរក្រហមត្រូវបានគេគោរពនិងយកចិត្តទុកដាក់ ។*

*ក្នុងពេលថ្មីៗនេះ ដែនទីដែលធ្វើពីឆ្អឹងលលាដ៍ក្បាលតម្កល់ទុកក្នុងសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ត្រូវបានអ្នកចាត់ការនិងបុគ្គលិកធ្វើការនៅទីនោះរុះរើចេញ ហើយនិងធ្វើពិធីបង្សុកូលជូនដល់វិញ្ញាណក្ខ័ន្ធអ្នកដែលត្រូវបានគេសម្លាប់ ។ ទង្វើដ៏សែនល្អប្រពៃនេះ ប្រកបដោយសកម្មភាពស្នេហាជាតិពិតប្រាកដនិងត្រឹមត្រូវឥតខ្ចោះ ។*

*ដូចឯកឧត្ដមធ្លាប់បានជ្រាបស្រាប់ហើយថា ព្រះករុណាជាអង្គម្ចាស់នៃយើងក្ដី រូបខ្ញុំផ្ទាល់ក្ដី សុទ្ធតែប្រាថ្នាចង់បាន ចង់ឃើញនូវសកម្មភាពខាងលើនេះ មិនតែប៉ុណ្ណោះយើងធ្លាប់បានសរសេរសំបុត្រ ស្នើសុំដល់រាជរដ្ឋាភិបាលកម្ពុជាជាញឹកញាប់ផងដែរ ។*

*ខ្ញុំសង្ឃឹមថា តទៅមុខទៀត រាជរដ្ឋាភិបាលពិតជាមិនព្រងើយកន្ដើយបណ្ដែតបណ្ដោយឲ្យអដ្ឋិធាតុនៅរាយប៉ាយពាសពេញប្រទេសកម្ពុជាតទៅទៀតទេ ។*

*សូមឯកឧត្ដមទទួលនូវសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។*

***ប៉ាង ស្នួន ប្រធានគណៈកម្មាធិការគាំទ្រព្រះមហាក្សត្រដើម្បីកម្ពុជា***

កំណាព្យ

# សោកនាដកម្មស្រុកមោងឬស្សី

១) ព្រែកជីកព្រែកកម្មចិញ្ច្រាំជីវិត ខ្លាចអម្ពរខក្រិដ្ឋមហាឃាតករ
ស្រែបួរទួលធំផ្តុំជាគំនរ ឆ្អឹងខ្មែរសល្អធ្លាក់ក្នុងហ្វូងក្អែក ។

២) អូរបរជីវីព្រៃដុះជុំជិត ពេលយប់ងងឹតឮសូរសម្រែក
អង្គរលន់តួគួរឲ្យសង្វេគ ព្រឹកស្អែកឃើញសពហៅសែនអនិច្ចា ។

៣) តាម៉ុកស្រែអូរឈាមហូរពេញដី សម្លាប់ខ្មែរប្រុសស្រីឥតក្តីមេត្តា
កាត់ផ្តាច់ជីវិតគ្មានសិទ្ធិតវ៉ា ចងដៃប្រហារខ្មែរគ្មានកំហុស ។

៤) ខ្មែរឈឺពឹងពេទ្យភូមិក្ជួយជីកដី ពួកពេទ្យអប្រិយ៍គ្មានក្តីសន្តោស
បង្អត់អាហារកប់មនុស្សទាំងរស់ រាស្ត្រខ្មែរស្រីប្រុសស្លាប់ទាំងវេទនា ។

៥) អាពាហ៍ពិពាហ៍ឥតមានខាន់ស្លា ចាប់ដៃបេដ្ជាតាមបទបញ្ជា
ភាពប្តីប្រពន្ធមិនទុកចិត្តគ្នា ខិតខំការពារជីវិតរៀងខ្លួន ។

៦) ធ្វើការហត់នឿយល្ហើយទាំងយប់ថ្ងៃ ម្ហូបបាយចំណីឆីមិនជាប់ជួន
រាងកាយស្លេកស្លាំងស្គាំងស្គមមិនមួន ហូបចុកគេងពួនខ្លួនដូចសត្វម្រឹគ ។

៧) ខ្នងដេកផ្ទាល់ដីយកព្រៃធ្វើផ្ទះ ខោមួយបន្ទាស់ប៉ូវប៉ះល្ងាចព្រឹក
ធ្លាក់ខ្យល់រងានាខែកត្តិក ខ្លួនញ័រគគ្រឹកដេកឱបភ្នក់ភ្លើង ។

៨) បបរមួយវែកវែកដីមួយថ្ងៃ ញ័រសព្វសរសៃទន់អស់ដៃជើង
ដើមឈើតូចធំខិតខំរំលើង ទាំងគេទាំងយើងគ្មានសិទ្ធិតវ៉ា ។

៩) បើហ៊ានចេញស្តីពាក្យអ្វីមិនសម ត្រូវគេបង្ខំយកទៅប្រហារ
ធ្វើខុសតែម្នាក់ស្លាប់ទាំងគ្រួសារ អំណាចផ្តាច់ការគ្មានត្រាប្រណី ។

១០) វាកាប់សម្លាប់មិនស្តាយជីវិត សាស្ត្រាចារ្យប្រាជ្ញព្រឹទ្ធបណ្ឌិតកវី
មិនថាទារកម្តាយបីក្នុងដៃ ទោះនៅក្នុងផ្ទៃត្រូវក្ស័យដូចគ្នា ។

១១) រស់នៅបីឆ្នាំនៅមោងឬស្សី ជីវិតភិតភ័យគ្រប់ពេលវេលា
បានរស់មួយថ្ងៃរួចខ្លួនមួយគ្រា ពេលយប់និទ្រាគិតព្រួយថ្ងៃស្អែក ។

១២) តើថ្ងៃណាទៅទើបខ្មែរបានសុខ ចាកផុតពីទុក្ខជនល្មោភអំណាច
សម្លាប់ជាតិឯងខំជ្រែងពុះញែក ដើម្បីអំណាចនិងរូបអាត្ម័ន ។

**មោងឬស្សី ឆ្នាំ១៩៧៨, អ៊ុង ស៊ីណាន**

ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ ជារៀងរាល់លេខនីងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះ ទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

A magazine of the Documentation Center of Cambodia: Searching for the truth. Number 29, May 2002.
Funded by the Royal Ministry of Foreign Affairs, Oslo, Norway, Section for the Human Rights and Humanitarian Assistance; Canadian International Development Agency (CIDA) through the Civil Society Fund; the Royal Danish Government; Swedish International Development Co-operation Agency (Sida); and the Royal Netherlands Government, *The Hague*.